## សំណួរ-ចម្លើយ

# ភាសាខ្មែរ



បគ្រប់មេរៀន
ាករណ៍
ន និង សំណេរ

៩

ស្របតាមកម្មវិធីសិក្សាថ្មី

# អារម្ភកថា

សៀវភៅ សំណួរ-ចម្លើយ ភាសាខ្មែរថ្នាក់ទី៩ រួមមាន១០ មេរៀន ដែលស្របតាមកម្មវិធីសិក្សាថ្មី នៃក្រសួងអប់រំយុវជន និងកីឡា។ សៀវភៅនេះនឹងចូលរួមផ្តល់ជាពន្លឺជំនួយស្មារតី ក្នុង*ការអាន និយាយ ស្តាប់ និងសរសេរ* ដើម្បីត្រៀម ក្នុងការប្រឡងបឋមភូមិ។ យើងមានចម្លើយគ្រប់មេរៀនទាំងអស់ដែលក្នុងសៀវភៅនេះវាមានធាតុសំខាន់ៗ ដូចជា*ផ្នែកវេយ្យាករណ៍ ផ្នែកអក្សរសិល្ប៍ (ក្នុងប្រទេស និងក្រៅប្រទេស) ផ្នែកវប្បធម៌អរិយធម៌ ការតែងនិពន្ធ និងផ្នែកកិច្ចការរដ្ឋបាល* មួយចំនួន។ ធាតុសំខាន់ៗទាំងនេះ ប្អូននឹងទទួលបាន ចំណេះយ៉ាងពិតប្រាកដបូកបន្ថែមនូវអ្វីដែលប្អូនមានដើម្បីជាពុទ្ធិ ឈានទៅរកការជោគជ័យ ក្នុងការប្រឡងប្រជែងនានា នៅក្នុងស្ថាប័នរដ្ឋនិងឯកជន។

យើងខ្ញុំរង់ចាំទទួលនូវការរិះគន់កែលំអ ក្នុងន័យស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ សិស្សនិស្សិតដោយក្តីរីករាយ។

សូមឱ្យការប្រឡងរបស់ប្អូនទទួលជោគជ័យជានិច្ច។

ភ្នំពេញថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១១


អ្នករៀបរៀង: **ស៊ុន ឡូរី**

**តឺង សុភាព**

អ្នកវាយអត្ថបទ: **នាង សុភារិទ្ធិ**

# បញ្ជីអត្ថបទ

១. តម្លៃសោភ័ណ...................................................១
២. មោទនភាពជាតិ..............................................១៧
៣. ការទទួលស្គាល់ការពិត....................................៣៦
៤. មិត្តភាព.........................................................៥៩
៥. ការកំណត់គោលដៅ...........................................៧៥
៦. ស្មារតីទទួលខុសត្រូវ........................................៩២
៧. ការជឿជាក់...................................................១០៦
៨. សេចក្តីព្យាយាម...............................................១២២
៩. ជោគជ័យនៃជីវិត..............................................១៣២
១០. ពលរដ្ឋល្អ.....................................................១៤៨

## មេរៀនទី១ តម្លៃសោភ័ណ

# វេយ្យាករណ៍ នាមជីវចល និង នាមអជីវចល

### លំហាត់

១. ពាក្យ មីងសំ តាសុខ ពាណិជ្ជករ មេឃ ដី ស្ទឹង បងប្រុស។ តើពាក្យណាខ្លះជានាមជីវចល ? ណាខ្លះជានាមអជីវចល ?

២. ចូរស្រង់នាមជីវចល ដែលមាននៅក្នុងអត្ថបទខាងក្រោម។

៣. ចូរស្រង់នាមអជីវចល ដែលមាននៅក្នុងអត្ថបទខាងក្រោម។

### ចម្លើយ

១.

| នាមជីវចល | នាមអជីវចល |
|---|---|
| *មីងសំ តាសុខ ពាណិជ្ជករ បងប្រុស* | *មេឃ ដី ស្ទឹង* |

២. **ស្រង់នាមជីវចលមាន** : សុត្តន្តប្រីជាឥន្ទ ម៉ុំ បញ្ញាកែវ ព្រះអាចារ្យពេជ្រ ព្រះពុទ្ធឃោសាចារ្យ អាចារ្យសុក ភិក្ខុ-ព្រះយ៉ាក់ថាចនញ៉ុញ ភរិយា បុត្រ។

៣. **ស្រង់នាមអជីវចលមាន** : គតិលោក នគរវត្ត បណ្ណាល័យ ក្រុងប៉ារីស ភាសាបារាំង រចនាបថ ធម៌ ឥណ្ឌា ថៃ ស្រីហិតោបទេស វប្បធម៌ខ្មែរ វប្បធម៌ខ្មែរ-បរទេស។

# អំណាន ជីវប្រវត្តិអ្នកព្រះតិរម្យតាសាអ៊ូ

## សំណួរ

១. តើលោក អ៊ុក-អ៊ូកើត នៅឆ្នាំណា ? ទីកន្លែងកំណើតនៅឯណា? ឪពុកម្តាយលោកឈ្មោះអ្វី ?

២. ក្រោយសឹកពីផ្នួសតើលោក អ៊ុក-អ៊ូ បានធ្វើអ្វីខ្លះ ? បានទទួលងារជាអ្វី ? នរណាជាអ្នកផ្តល់ជូនគាត់ ?

៣. ចូរស្រង់ពាក្យពហុព្យាង្គពីអត្ថបទឱ្យបាន ៥ ពាក្យ រួចធ្វើការញែកព្យាង្គ ដើម្បីពន្យល់ន័យពាក្យទាំងនោះ។

៤. ចូរបង្ហាញទឹកចិត្តអ្នកស្រី ស៊ូសានកាពេលេស ចំពោះលោក អ៊ុក-អ៊ូ។

៥. ចូរសង្ខេបជីវប្រវត្តិលោក អ៊ុក-អ៊ូ។

"...លោកអ៊ុក-អ៊ូ មានវោហារខ្លាំងនិងល្បិចលើកកំណាព្យភ្លាមៗច្រៀងព្រមជាមួយនឹងសំនៀងសាដៀវយ៉ាងពីរោះ។ គាត់ចេះដឹងខាងធម៌អាថ៌យ៉ាងខ្ពង់ខ្ពស់ដែលធ្វើឱ្យអ្នកស្រុកចាត់ទុកជាអ្នកប្រាជ្ញក្នុងភូមិស្រុក ហើយពួកគេហៅគាត់ថា "តិរម្យង៉ុយ"។ បន្ទាប់មករដ្ឋអំណាចបានតាំងលោកថា "ក្រម" (ក្រមង៉ុយ) គឺជាភារផនដែលធ្វើទំនាក់ទំនងរវាងរាជរដ្ឋាភិបាលនិងប្រជាជនក្នុងឃុំ..."។

## ចម្លើយ

១. លោក អ៊ុក-អ៊ូ *កើតឆ្នាំ១៨៦៥*។ នៅឃុំកំបូល ស្រុកភ្នំពេញ(អង្គស្នួល) ខេត្តកណ្តាល។ ឪពុក ឈ្មោះ**អ៊ុក** ម្តាយលោកឈ្មោះ**អៀង** ដែលត្រូវជាបងប្អូនជីទួតមួយនឹងគ្នា។

**២. ក្រោយសឹកពីផ្នួសលោក អ៊ុក-អ៊ូបាន ៖**

-រៀបអាពាហ៍ពិពាហ៍ជាមួយភរិយារបស់គាត់ ឈ្មោះអ៊ិន ប្រកបរបរជាកសិករ មានកូន៦នាក់។

-ពេលទំនេរលោកច្រៀងចម្រៀង សូត្រកំណាព្យ បន្ទរដោយសំនៀងសាដៀវដើម្បីអប់រំយាយតាកូនចៅរបស់គាត់។

-វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានឱ្យលោកច្រៀងរួចពួកគេចងក្រងជាសៀវភៅ។

**លោកបានទទួលងារជាដូចជា :** *ភិរម្យង៉ុយ*(ទទួលពីប្រជាកសិករ) *ក្រម*(ទទួលងារពី រដ្ឋអំណាចបានតាំង) *ព្រះភិរម្យភាសាអ៊ូ* (ទទួលងារពីព្រះមហាក្សត្រ)។

**៣. ស្រង់ពាក្យពហុព្យាង្គពីអត្ថបទឱ្យបាន ៥ ពាក្យ រួចធ្វើការញែកព្យាង្គ ដើម្បីពន្យល់ន័យពាក្យ :**

-ចាកសិក្ខាបទ : ចាក(លា)+សិក្ខា(សិក្សា ឬរៀន) +បទ(*ពាក្យបន្ថែមចុង*)= សឹកពីបួស លាព្រះផ្នួស លាពីការសិក្សា។

-អាពាហ៍ពិពាហ៍ : អាពាហ៍(នាំកូនស្រីមកផ្ទះខាងប្រុស)+ ពិអាហ៍(នាំកូនប្រុសត្រឡប់ទៅផ្ទះកូនស្រី)= ការរៀបចំមង្គលការ។

-ប្រជាប្រិយភាព : ប្រជាប្រិយ(និយមចូលចិត្តរបស់ប្រជាជន ) + ភាព(*ពាក្យបន្ថែមចុង*)= ភាពនិយមចូលចិត្តរបស់ប្រជាជន។

-រដ្ឋអំណាច : រដ្ឋ(ដែនដី ប្រទេស ប្រជាជន)+អំណាច (អានុភាព) = អំណាចនៃអ្នកដឹកនាំប្រទេស។

-ភារជន : ភារ(កិច្ចការ)+ជន(មនុស្ស) = មនុស្សដែលមានភារកិច្ច។

**៤. ទឹកចិត្តអ្នកស្រី ស៊ូសានកាពេលេស ចំពោះលោក អ៊ុក-អ៊ូ** គឺក្រោយពីលោកស្សីដែសនាំលោក អ៊ុក-អ៊ូ ទៅជួបហើយបង្ហាញពីគុណសម្បត្តិរបស់លោក អ៊ុក-អ៊ូ ភ្លាម លោកស្រីបានចាប់អារម្មណ៍យ៉ាងខ្លាំង ហើយមានគំនិតអាណិតអាសូរចង់ បន្សល់កេរ្តិ៍ឈ្មោះនិងស្នាដៃរបស់លោក អ៊ុក-អ៊ូ មិនឱ្យបាត់បង់ ទើបឱ្យអ្នកប្រាជ្ញគេកត់ត្រានូវចម្រៀងរបស់គាត់ដាក់ក្នុងសៀវភៅ តែគួរឱ្យសោកស្ដាយដែលអ្នកស្រីឱ្យប្រាក់មួយរៀលទៅលោក អ៊ុក-អ៊ូ វាជាតម្លៃថោកខ្លាំងណាស់ សម្រាប់ស្នាដៃដ៏ពិសិដ្ឋរបស់អ្នកប្រាជ្ញមួយរូបនេះ។

**៥. សង្ខេបជីវប្រវត្តិលោក អ៊ុក-អ៊ូ**

លោក *អ៊ុក-អ៊ូ* ហៅង៉ុយកើតនៅឆ្នាំ១៨៦៥នៅខេត្តកណ្ដាល ឪពុកឈ្មោះ *អ៊ុក* ម្ដាយឈ្មោះ*អៀង* ប្រពន្ធឈ្មោះ*អ៊ិន* និងមានកូន ៦នាក់ ។ លោកបានបួសរៀនជាភិក្ខុ ហើយបានចូលរួមប្រែព្រះត្រៃបិតក បន្ទាប់មកក៏បានលាចាកសិក្ខាបទមកវិញ។ លោកបានរៀបអាពាហ៍ពិពាហ៍ ហើយប្រកបរបរជាអ្នកធ្វើស្រែចម្ការជាធម្មតា។

"...លោកអ៊ុក-អ៊ូ មានវោហារខ្លាំងនិងល្បិចលើកកំណាព្យភ្លាមៗច្រៀងព្រមជាមួយនឹងសំនៀងសាដៀវយ៉ាងពីរោះ។ គាត់ចេះដឹងខាងធម៌អាថ៌យ៉ាងខ្ពង់ខ្ពស់ ដែលធ្វើឱ្យអ្នកស្រុកចាត់ទុកជាអ្នកប្រាជ្ញក្នុងភូមិស្រុក ហើយពួកគេហៅគាត់ថា "ភិរម្យង៉ុយ"។ បន្ទាប់មករដ្ឋអំណាចបានតាំងលោកថា "ក្រម" (ក្រមង៉ុយ) គឺជាភារជនដែលធ្វើទំនាក់ទំនង រវាងរាជរដ្ឋាភិបាលនិងប្រជាជនក្នុងឃុំ..."។

លោកច្រៀង និងសូត្រកំណាព្យអប់រំដល់ប្រជាពលរដ្ឋដោយមានសំនៀងសាដៀវ បន្ទរបានឮល្បីសុសសាយរហូតដល់ព្រះមហាក្សត្រដាក់ងារថា ព្រះភិរម្យភាសាអ៊ូ។ នៅឆ្នាំ១៩៣០គាត់បានច្រៀងចម្រៀងឱ្យពុទ្ធសាសនបណ្ឌិត្យ កត់ត្រាជាសៀវភៅ។ គាត់ស្លាប់ក្នុងឆ្នាំ១៩៣៩ អាយុ៧១ឆ្នាំ បានបន្សល់ទុកស្នាដៃជាច្រើនដូចជា សេចក្ដីរំលឹកដាសតឿន ច្បាប់កេរកាលថ្មី ច្បាប់ប្រដៅជនប្រុសស្រី និងមណ្ដាំក្រមង៉ុយ។

# វេយ្យាករណ៍ ការសំគាល់ពាក្យបាលីសំស្ក្រឹត

## លំហាត់

១. ចូរអ្នកពិនិត្យមើលជីវប្រវត្តិអ្នកស្រី សិទ្ធិ រួចជ្រើសរើសពាក្យបាលីសំស្ក្រឹត ដែលមានសំណេរខុសពីសំណេរនិងពាក្យដែលមានប្រើសញ្ញា "ំ"

២. ចូររកពាក្យបាលីសំស្ក្រឹតដែលមានប្រើ៖

- សញ្ញាទណ្ឌឃាត "៍"
- សញ្ញារបាទ "៌"
- ព្យញ្ជនៈប្រកប "ក ខ ថ ធ ណ"
- ព្យញ្ជនៈប្រកបមានស្រៈ "ិ" នៅខាងចុងដែលមានសញ្ញានីមួយៗឱ្យបានបីពាក្យ។

៣. ចូរអានព្រះរាជជីវប្រវត្តិសម្ដេចព្រះមហាសុមេធាធិបតី **ជួន ណាត** ហើយស្រង់ពាក្យកំចីបាលីសំស្ក្រឹតទាំងអស់ដែលមាននៅក្នុងអត្ថបទខាងក្រោម។

## ចម្លើយ

**១. ពាក្យបាលីសំស្ក្រឹត**

**+សំណេរខុសពីសំណេរ** : មិគសិរ បិតា មាតា ។

**+ពាក្យដែលមានប្រើសញ្ញា "ំ"** : យុត្តិធម៌ ។

**២. ចូររកពាក្យបាលីសំស្ក្រឹតដែលមានប្រើ៖**

- **សញ្ញាទណ្ឌឃាត "៍ : ប្រយោជន៍ ព្រាហ្មណ៍ អាពាហ៍ពិពាហ៍**

- **សញ្ញារបាទ "៌ : ពណ៌ សីលធម៌ ពណ៌នា។**

- ព្យញ្ជនៈប្រកប "ក ខ ថ ធ ណ" :មត៌ក បិតក ចតុមុខ ប្រមាថ គុណ ពុធ ក្រេវក្រោធ។

- **ព្យញ្ជនៈប្រកបមានស្រៈ ិ នៅខាងចុង : ជាតិ កុដិ ត្រុដិ កោដិ**

៣. ពាក្យបាលី សំស្ក្រឹតដែលមាននៅក្នុងជីវប្រវត្តិ ជួន ណាត : *ប្រសូត អង្គារ ភូមិ ខេត្ត ព្រះបិតានាម មាតា បុត្រ កាល កុមារ សិក្សា អក្សរ លេខ សាមណេរ ពិសាខ សំរឹទ្ធិស័ក ឧសភា វត្តពោធិព្រឹក្ស ព្រះបរិយត្តិធម៌ ភិក្ខុ ឧបសម្បទា ជេដ្ឋ មិថុនា ឆស័ក និមន្តព្រះតេជព្រះគុណ ព្រះពុទ្ធឃោសាចារ្យ សុវណ្ណប្បញ្ញោ អធិការ ឧបជ្ឈាយ៍ សុភមង្គល ករុណា អត្ថបទ ទស្សនាវដ្ដី ពន្លឺពុទ្ធចក្រ កម្ពុជវដ្ឋ និពន្ធ កក្កដា បុណ្យ ...។*

## វេយ្យាករណ៍ សញ្ញារបាទ(ពី)

### សំណួរ

១.តើសញ្ញារបាទមានទ្រង់ទ្រាយដូចម្ដេច?

២. គេប្រើសញ្ញារបាទយ៉ាងដូចម្ដេច?

### ចម្លើយ

**១.សញ្ញារបាទមានទ្រង់ទ្រាយដូចជា** : យើងទាញកោងជាដងធ្មុ (ស្ដាំមកឆ្វេង)ផ្ដេករួច វាត់ទៅលើកោងស្របគ្នានឹងធ្នូចាស់បញ្ចប់ដោយ ញែកពីគ្នាពីចំណុចចាប់ផ្ដើមវិញ (*សញ្ញាជើងវា*)។

**២. គេប្រើសញ្ញារបាទ** ដើម្បីជំនួសអក្សរ នៅខាងលើព្យញ្ជនៈ ពេលខ្លះវានៅខាងចុងព្យញ្ជនៈ និងកណ្ដាលព្យញ្ជនៈ ជួនកាលវាបង្កើតខ្យល់ (អ៊ឺរ) នៅពេលដែលពាក្យនោះមានមួយព្យាង្គ។ របាទប្រើនៅលើតួព្យញ្ជនៈខាងចុង ពុំបញ្ចេញសូរព្យញ្ជនៈ "រ" ទេ (មាគ៌ា) របាទប្រើលើព្យញ្ជនៈកណ្ដាលនៃពាក្យមានសូរព្យញ្ជនៈ "រ" (មត៌ក)។

### លំហាត់

១. ចូររកពាក្យដែលប្រើសញ្ញារបាទ "៌"ឱ្យបាន ៥ ពាក្យដោយប្រាប់សូររបស់ពាក្យនីមួយៗ។

២. ចូរតែងល្បះដែលប្រើសញ្ញារបាទ "៌" ឱ្យបាន៥ល្បះ។

### ចម្លើយ

**១. ពាក្យដែលប្រើសញ្ញារបាទ "ំ" ឱ្យបាន ៥ ពាក្យមាន :**

ពណ៌(ព័រ) ធម៌(ធ័រ) មត៌ក(មរៈដក់) ពណ៌នា(ព័រណៈនា) ព័ត៌មាន(ព័តម៉ាន) ទុគ៌ត(ទុរៈគត់) បព៌ត(បរ៉ៈពត់)។

**២. តែងឈ្មោះដែលប្រើសញ្ញារបាទ "ំ" ឱ្យបាន៥ឈ្មោះ**

១. ម្សិលមិញអ្នកគ្រូបានឱ្យខ្ញុំពិពណ៌នាអំពីប្រាសាទព្រះវិហារ។

២. សម្រស់ធម្មជាតិពណ៌បៃតងនៅលើភ្នំ។

៣. ម្ដាយដែលមានគភ៌គួរតែទៅពិនិត្យផ្ទៃពោះឱ្យបានទៀងទាត់។

៤. ខ្ញុំចូលចិត្តមើលខែពេញបូណ៌មី។

៥. ព្រះរតនត្រៃមានបីគឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។

## អំណាន ពុទ្ធប្រវត្តិសង្ខេប

### សំណួរ

១. តើព្រះពុទ្ធប្រសូត្រនៅឯណា? ព្រះមាតាបិតាព្រះអង្គព្រះនាមអ្វី?

២. ចូរស្រង់កាលបរិច្ឆេទប្រវត្តិព្រះពុទ្ធសំខាន់ៗដាក់តាមលំដាប់។

៣. តើព្រាហ្មណ៍ហោរា ៨ នាក់បានទស្សន៍ទាយលក្ខណៈសម្បត្តិរបស់ព្រះសិទ្ធត្ថយ៉ាងដូចម្ដេចខ្លះ?

៤. ចូររកពាក្យដែលប្រើសញ្ញារបាទ "ំ" នៅក្នុងអត្ថបទខាងលើ។

៥. ចូរស្រង់ពាក្យសំគាល់បាលីសំស្ក្រឹត ក្នុងវគ្គខាងក្រោមនេះចំនួនបីពាក្យ រួចប្រាប់ពីលក្ខណៈសំគាល់ផង៖

"...ព្រះសិទ្ធត្ថមានព្រះជន្ម៧ថ្ងៃ ព្រះមាតាសិរិមហាមាយាសោយទីវង្គត។ ព្រះបាទសិរិសុទ្ធោទនៈបានជ្រើសរើសព្រះនាងគោតមីមើលបីបាច់ថែរក្សាព្រះរាជឱរស តរៀងមក..."

៦. ហេតុអ្វីបានជាព្រះជាម្ចាស់ជ្រើសរើសព្រះធរណីធ្វើជាសាក្សីនៅពេលដែលពួកស្តេចមារផ្ចាញ់ព្រះអង្គ?

៧. តើគំនិតសំខាន់នៃអត្ថបទនេះនិយាយពីអ្វីខ្លះ ?

## ចម្លើយ

**១. ព្រះពុទ្ធប្រសូត្រនៅ** ព្រំប្រទល់នគរពីរគឺកបិលព័ស្តុនិងទេវទហៈនៃព្រៃលម្ពិនីក្រោមដើមសាលព្រឹក្សមួយដើម។

**ព្រះមាតាព្រះនាម*សិរិមហាមាយា*** **បិតាព្រះអង្គព្រះនាមព្រះ*បាទសិរិសុទ្ធោទនៈ*។**

**២. កាលបរិច្ឆេទប្រវត្តិព្រះពុទ្ធសំខាន់ៗដាក់តាមលំដាប់មាន ៖**

-ព្រះពុទ្ធប្រសូតនៅថ្ងៃសុក្រ ពេញបូណ៌មី ខែពិសាខ ឆ្នាំច ៦២៣មុន គ.ស។

-ព្រះអង្គអភិសេកជាមួយព្រះនាងពិម្ពាយសោធរា នៅថ្ងៃសៅរ៍ពេញបូណ៌មី ខែអាសាឍ ឆ្នាំឆ្លូវ៦០៧មុនគ.ស។

-ព្រះអង្គចេញសាងផ្នួសនៅថ្ងៃព្រហស្បតិ៍ ពេញបូណ៌មី ខែអាសាឍ ឆ្នាំថោះ ព្រះជន២៩វស្សា។

-ត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធនៅថ្ងៃពុធ ពេញបូណ៌មី ខែពិសាខ ឆ្នាំរកា៥៨៨មុនគ.ស។

-អាយុសង្ខា ថ្ងៃអាទិត្យ ពេញបូណ៌មី ខែមាឃ ឆ្នាំម្សាញ់។

-ចូលបរិនិពាន្តនៅថ្ងៃអង្គារ ពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់ ៥៤៣មុនគ.ស។

៣. ព្រាហ្មណ៍ហោរា ៨ នាក់បានទស្សន៍ទាយលក្ខណៈសម្បត្តិរបស់ព្រះសិទ្ធត្ថដូចតទៅ : ព្រាហ្មទី១ ដល់ទី៧ សុទ្ធតែទាយថា "*ព្រះមហាបុរសបើ នៅជាឃរាវាសនឹងបានឡើងសោយរាជ្យសម្បត្តិជាស្តេចចក្រពត្តិ បើបានបួសនឹងបានត្រាស់ជាព្រះពុទ្ធ* ចំណែកឯកោណ្ឌញ្ញ ព្រាហ្មណ៍ក្មេងបានទាយថា "*ព្រះមហាបុរសនឹងបានត្រាស់ជាព្រះពុទ្ធពិតមែន*"។

៤. ប្រើសញ្ញារបាទ "ំ" មាន : ពេញបូណ៌មី ធម៌ ទិសបូព៌ា ទិសបូព៌

៥. ពាក្យសំគាល់បាលីសំស្ក្រឹត លក្ខណៈសំគាល់ផងមាន៖

- មិនប្រើបន្តក់ *ឧទាហរណ៍* : ទិវង្គត
- ប្រើស្រះពេញតួ *ឧទាហរណ៍* : ឱរស
- ប្រើព្យញ្ជនៈប្រកប *ឧទាហរណ៍* : រាជ

៦. បានជាព្រះជាម្ចាស់ជ្រើសរើសព្រះធរណីធ្វើជាសាក្សី នៅពេលដែលពួកស្តេចមារផ្ចាញ់ព្រះអង្គព្រះអង្គជឿលើភាពបរិសុទ្ធរបស់ព្រះ

**ធរណី ហើយនិងភាពបរិសុទ្ធរបស់ព្រះអង្គដោយមិនលំអៀងព្រោះ** បល្ល័ង្កផុសឡើងចេញពីការព្យាយាមរបស់ព្រះអង្គ ដូចនេះមានតែព្រះធរណីទេ ដែលជាសាក្សី អាចបង្ហាញពីភាពបរិសុទ្ធរបស់ព្រះអង្គ ម្ល៉ោះហើយទើបបានព្រះធរណីកំរើកឡើងហាក់ដូចជាទទួលធ្វើជាសាក្សីមែន។

**៧. គំនិតសំខាន់នៃអត្ថបទនេះនិយាយពី** : ដំណើរជីវិតព្រះសម្មាសម្ពុទ្ធតាំងពីពេលកើត ពេលរៀនសូត្រ ពេលអភិសេក ពេលគ្រងរាជ ចេញសាងផ្នួស ផ្ចាញ់មារ ពេលត្រាស់ដឹង ពេលដាក់ អាយុសង្ខា និងសោយទិវង្គត។

## ការស្តាប់ រឿង ព្រះនាងឥន្ទ្រទេវី

### សំណួរ

១. ព្រះនាងឥន្ទ្រទេវីទ្រង់ប្រសូតឡើងក្នុងត្រកូលណា? ស្ថានភាពក្នុងគ្រួសារយ៉ាងដូចម្តេច?

២. តើព្រះនាងបំពេញបេសកម្មអ្វីខ្លះ ជាប្រយោជន៍គ្រួសារនិងប្រទេសជាតិ?

៣. ចូរស្រង់ពាក្យបាលីសំស្ក្រឹតឱ្យបាន ៥ ពាក្យ។

៤. តើព្រះនាងឥន្ទ្រទេវីបានលើកកម្ពស់សិទ្ធិនារីដូចម្តេចខ្លះ?

៥. ចូរបង្ហាញតម្លៃអប់រំនៃអត្ថបទនេះ។

៦. ចូរសង្ខេបអត្ថបទឡើងវិញ។

# ការនិយាយ ជីវប្រវត្តិផ្ទាល់ខ្លួន

## សំណួរ

១. តើសិស្សថ្មីផ្ទេរការសិក្សាថ្នាក់ទី ៩ "ក" ឈ្មោះអ្វី? មកពីសាលាណា?

២. ឪពុកម្តាយនាងឈ្មោះអ្វី? ប្រកបរបរកស៊ីអ្វី?

៣. តើជីវភាពគ្រួសារនាងស្ថិតក្នុងស្ថានភាពណា?

៤. តើកត្តាអ្វីជំរុញឱ្យនាងខិតខំរៀន?

៥. តើឪពុកម្តាយនាងបានប្តេជ្ញាចិត្តដូចម្តេច? ហេតុអ្វី?

៦. តើអ្នកយល់ដូចម្តចចំពោះជីវប្រវត្តិសិស្សថ្មី?

## ចម្លើយ

១. សិស្សថ្មីផ្ទេរការសិក្សាថ្នាក់ទី ៩ "ក" ឈ្មោះ *មុតសុភក្ត្រ* មកពីសាលា អនុវិទ្យាល័យ "*គោ* ខេត្តកោះកុង។

២. ឪពុកនាងឈ្មោះ *មុតសុខុម* ប្រកបរបរកស៊ីជាកម្មករនេសាទ។ ម្តាយឈ្មោះ ***គីមស៊ីម*** មេផ្ទះ។

៣. ជីវភាពគ្រួសារនាងស្ថិតក្នុងស្ថានភាពជីវភាពមធ្យម តែនឿយហត់ខ្លាំងណាស់។

៤. កត្តាជំរុញឱ្យនាងខិតខំរៀនគឺ ដោយឃើញពីជីវភាពក្រីក្រលំបាកពេក ឪពុកម្តាយធ្វើការទាំងឈឺទាំងជា ប្រថុយនឹងគ្រោះថ្នាក់ព្យុះសមុទ្រគ្មានថ្ងៃទំនេរ។

៥. ឪពុកម្តាយនាងបានប្តេជ្ញាចិត្តថា *"គាត់មានកម្លាំងចិត្តខិតខំធ្វើការគ្រប់បែបយ៉ាងដើម្បីកូនៗទាំងអស់គ្នារៀនសូត្រ រហូតបានជោគជ័យក្នុងជីវិត"*។ ព្រោះគាត់ឃើញកូនស្រីរបស់គាត់រៀនបានពូកែ ហើយមិនចង់ឱ្យកូនៗរបស់គាត់លំបាកដូចគាត់ទៀត។

៦. ខ្ញុំចំពោះជីវប្រវត្តិសិស្សថ្មីពិតជាកំសត់ ហើយមានគំនិតសុទិដ្ឋិនិយម ចេះតស៊ូ រៀនសូត្រ អនាគតនឹងទទួលបានជោគជ័យ។ ក្នុងនាមយើងជាសិស្ស ត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានពូកែដូចនាងមុតសុភក្រ្ត។

# សំណេរ ជីវប្រវត្តិ

## សំណួរ

១. តើសំណេរជីវប្រវត្តិខាងលើនេះប្រាប់ពីព័ត៌មានអ្វីខ្លះ?

២. តើការសរសេរជីវប្រវត្តិផ្ទាល់ខ្លួនមានអត្ថប្រយោជន៍ដូចម្តេច?

៣. តើការក្លែងបន្លំជីវប្រវត្តិមានទោសឬទេ? ព្រោះអ្វី?

## ចម្លើយ

១. សំណេរជីវប្រវត្តិខាងលើនេះប្រាប់ពីព័ត៌មានពី គោត្តនាម អាស័យដ្ឋាន ឈ្មោះឪពុកម្តាយ ទីកន្លែងកំណើត ថ្ងៃខែឆ្នាំកំណើត បងប្អូនបង្កើត ប្រវត្តិនៃការសិក្សា ចំណង់ចំណូលចិត្ត និងជំនាញពិសេសរបស់នាងមុត សុភក្រ្ត។

២. ការសរសេរជីវប្រវត្តិផ្ទាល់ខ្លួនមានអត្ថប្រយោជន៍ អាចឱ្យគេស្គាល់ និងជឿទុកចិត្តបានអំពីអត្តសញ្ញាណរបស់យើងក្នុងគោលបំណងធ្វើកិច្ចសន្យា ឬធ្វើលិខិតស្នាមផ្សេងៗ ជាពិសេសគឺការដាក់ពាក្យធ្វើការងារ។

៣. ការក្លែងបន្លំជីវប្រវត្តិពិតជា មានទោសព្រោះធ្វើឱ្យគេយល់ច្រឡំ ពីអត្តសញ្ញាណរបស់យើង ហើយគេអាចយកទៅប្រើប្រាស់ខុសឆ្គង ខាតផលប្រយោជន៍ដល់អ្នកដទៃ និងប្រទេសជាតិទាំងមូល។

## លំហាត់

ចូរអ្នកសរសេរជីវប្រវត្តិផ្ទាល់របស់អ្នកដោយអនុវត្តតាមលំនាំខាងលើ។

## ចម្លើយ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ជីវប្រវត្តិរូបសង្ខេប

-គោត្តនាម : ហេង សុភី អាយុ១៤ឆ្នាំ ភេទស្រី សញ្ជាតិខ្មែរ។

-អាស័យដ្ឋានបច្ចុប្បន្ន : ផ្ទះលេខ៥៧ភូមិត្រពាំងឈូក សង្កាត់/ឃុំទឹកថ្លា ស្រុក/ខណ្ឌ សែនសុខ ភ្នំពេញ។

-ឪពុកឈ្មោះ : ហេង សុភា មុខរបរ គ្រូបង្រៀន។

-ម្តាយឈ្មោះ : ហង្ស សុជាតា មុខរបរ មេផ្ទះ ។

-ទីកន្លែងកំណើត : ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ភ្នំពេញ។

-ថ្ងៃខែឆ្នាំកំណើត : ២២ មិថុនា ១៩៩៦

-បងប្អូនបង្កើត : មាន១នាក់

ឈ្មោះហេង សុជា ភេទស្រី អាយុ១១ឆ្នាំ ត្រូវជាប្អូនបង្កើត។

-ការសិក្សាអប់រំ : ឆ្នាំ២០០៩-២០១០ថ្នាក់ទី៩ សាលា ក

ឆ្នាំ២០០៨-២០០៩ថ្នាក់ទី ៨ សាលា គ

ឆ្នាំ២០០៧-២០០៨ ថ្នាក់ទី៧ សាលា គ

-ចំណងចំណូលចិត្ត : អានសៀវភៅ ធ្វើលំហាត់។

-ជំនាញពិសេស : សរសេរកំណាព្យ

# មេរៀនទី២ មោទនភាពជាតិ

## វេយ្យាករណ៍ នាមរូបី នាមអរូបី

### លំហាត់

ចូរអ្នករកនាមរូបី និងនាមអរូបីក្នុងល្បះនិងកថាខណ្ឌខាងក្រោម

១. ក្រដាស ប្រាសាទ អ្នកលក់ដូរ ស្លាបព្រា ការអនុវត្ត ទីក្រុងកេប៉ិច ប្រទេសកាណាដា បេតិកភណ្ឌ ប្រជាជន សិល្បករ អ្នកដកស្ទូង

២. សំដីមាស តម្លៃ សៀវភៅ បញ្ជី ខេមរៈបុត្រ វត្តអារាម នាយកសលា ភាពក្លាហាន មោទនភាព

៣. "សត្វកណ្ដៀរពាំនាំជញ្ជូនដីបន្តិចម្ដងៗក៏គង់កើតជាដំបូកធំ" សម្រាប់ស្នាក់អាស្រ័យនៅ។ រីឯមនុស្សដែលប្រកាន់សេចក្ដីព្យាយាម រមែងសម្រេចតាមបំណងប្រាថ្នា។

៤. លោកអធិបតីចូលមក "សូជាត បន្ទប់នេះគឺបន្ទប់ឯង ការរចនាបានរុងរឿងស្រេចលើចិត្តបាស្រាប់ អញរៀបចំប្រុងប្រដាប់ឱ្យឯងស្រួលបួលនេះ គឺអញមានសេចក្ដីសង្ឃឹមថាឯងគង់តែនឹងបានរៀនសូត្រកើនទៅមុខពុំខាន"។

## ចម្លើយ

១. +នាមរូបី : *ក្រដាស ប្រាសាទ អ្នកលក់ដូរ ស្ថាបត្យកម្ម ទីក្រុងកេបិច ប្រទេសកាណាដា ប្រជាជន សិល្បករ អ្នកស្ទួង។*

+នាមអរូបី : *ការអនុវត្ត បេតិកភណ្ឌ។*

២. +នាមរូបី : *សៀវភៅ បញ្ជី ខេមរបុត្រ វត្តអារាម នាយកសាលា។*

+នាមអរូបី : *សំដីមាស តម្លៃ សេចក្តីក្លាហាន មោទនភាព។*

៣.+នាមរូបី : *សត្វកណ្តៀរ ដី ដំបូក មនុស្ស ។*

+នាមអរូបី : *សេចក្តីក្លាហាន សេចក្តីព្យាយាម បំណងប្រាថ្នា។*

៤. +នាមរូបី : *លោកអធិបតី ស្ទូងាត បន្ទប់ ឯង បា អញ ប្រដាប់។*

+នាមអរូបី : *ការរចនា ចិត្ត សេចក្តីសង្ឃឹម ។*

# អំណាន មោទនភាពជាតិខ្មែរ

## សំណួរ

១. តើប្រាសាទព្រះវិហារ បានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នៅថ្ងៃណា? ខែណា? ឆ្នាំណា? នៅប្រទេសណា?

២. តើប្រាសាទអង្គរវត្ត បានបញ្ចូលក្នុងពិធីបេតិកភណ្ឌពិភពលោក ពីឆ្នាំដែរ?

៣. តើអ្នកយល់ដូចម្តេច ចំពោះការដាក់បញ្ចូល ឬចុះបញ្ជីប្រាសាទ ទាំងនេះជាបេតិកភណ្ឌពិភពលោក?

៤. តើអត្ថបទខាងលើបង្កប់តម្លៃអប់រំដូចម្តេច?

៥. តើអ្នកគួរធ្វើ ឬត្រូវធ្វើអ្វីខ្លះដើម្បីសម្តែងនូវឆន្ទៈនិងមោទនភាពចំពោះជាតិ?

៦. សម្រាប់ប្រទេសកម្ពុជាការដាក់បញ្ចូលក្នុងពិធីបេតិកភណ្ឌពិភពលោកសំខាន់ៗទាំង ៤ លើកមានអ្វីខ្លះ? ចូររៀបរាប់។

៧. ចូរស្រង់នាមរូបី ក្នុងអត្ថបទខាងលើឱ្យបានចំនួន ៣និងនាមអរូបីឱ្យបានចំនួន ៣។

## ចម្លើយ

១. ប្រាសាទព្រះវិហារបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅ *ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨* នៅប្រទេសកាណាដា ទីក្រុងកេបិច។

២. ប្រាសាទអង្គរវត្ត បានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកពីឆ្នាំ១៩៩២។

៣. ខ្ញុំយល់ថា ការបញ្ចូលព្រះវិហារ និងអង្គរវត្តទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក គឺជានយោបាយដ៏ឈ្លាសវៃរបស់អ្នកដឹកនាំរបស់ប្រទេសយើង ព្រោះវាបានបង្ហាញពីស្នាដៃដែលជាតម្លៃវប្បធម៌រូបីទៅដល់ពិភពលោក ឱ្យគេបានស្គាល់ និងជួយថែរក្សាមត៌កវប្បធម៌នេះ ឱ្យមានអាយុយូរអង្វែងតទៅ ទុកជាសម្បត្តិរួមរបស់ពិភពលោក។

៤. អត្ថបទខាងលើបង្កប់តម្លៃអប់រំដល់យើងដូចជា៖

-ឱ្យស្គាល់ពីតម្លៃវប្បធម៌របស់ខ្មែរ

-ឱ្យយើងចេះស្រឡាញ់ និងថែរក្សាមត៌កវប្បធម៌ជាតិ

-ឱ្យយើងស្គាល់ពីបេតិកភណ្ឌជាតិ និងកាលបរិច្ឆេទការចុះបញ្ជីរបស់ពួកវានីមួយៗទៅក្នុងបេតិកភណ្ឌពិភពលោក។

-យើងត្រូវមានមោទនភាព និងចេះឈឺឆ្អាលជួយលើកកេរ្តិ៍ឈ្មោះជាតិមាតុភូមិ។

៥. ដើម្បីសម្តែងនូវឆន្ទៈនិងមោទនភាពចំពោះជាតិខ្ញុំត្រូវ៖

-ចូលរួមយ៉ាងសកម្ម គាំទ្រជាមួយនឹងនយោបាយការដាក់ប្រាសាទខ្មែរជាបេតិកភណ្ឌពិភពលោក។

-ចូលរួមថែរក្សាសម្បត្តិនេះឱ្យសមជាទ្រព្យរបស់សកលលោក។

-បណ្តុះក្មេងជំនាន់ក្រោយឱ្យចូលរួមសប្បាយជាមួយយើងដែរ។

-ផ្សព្វផ្សាយពីកេរ្តិ៍ឈ្មោះនេះឱ្យបានទូលាយ។

-បង្កើតពិធីបុណ្យផ្សេងៗទាក់ទងជាមួយការចុះបញ្ជីប្រាសាទនិងសម្បត្តិផ្សេងៗទៀត។

៦. សម្រាប់ប្រទេសកម្ពុជាការដាក់បញ្ចូលក្នុងពិធីបេតិកភណ្ឌពិភពលោកសំខាន់ៗទាំង ៤នោះមាន៖

-អង្គរវត្ត១៤ ១២ ១៩៩២។ -ព្រះវិហារ០៧ ០៧ ២០០៨

-របាំក្បាច់បុរាណខ្មែរ(អប្សរា) ០៧ ១១ ២០០៣

-ល្ខោនស្បែក ២៥ ១១២០០៥។

៧.+**ស្រង់នាមរូបី** :សម្ដេច ហ៊ុន សែន ប្រាសាទព្រះវិហារ អង្គរវត្ត

+**នាមអរូបី** : បូរណភាព អធិបតេយ្យភាព គោលបំណង សំណើ

## បំណិន បំរៀបន័យ ឬមេតាផរ

លំហាត់

១. ចូរអានអត្ថបទដកស្រង់ខាងក្រោមហើយគូសបន្ទាត់ពីក្រោមពាក្យដែលបញ្ជាក់ពី "មេតាផរ"។

រថភ្លើងបោលលឿនដូចព្យុះកាត់ព្រៃថ្លុង រត់កាត់អូរហើយពុះជ្រែកជើងភ្នំដោយបញ្ចេញសន្ទឹកខ្ទរំពងធ្វើឱ្យរញ្ជួយផែនពសុធា។ បើគេសម្លឹងតាមបង្អួចនៃទូរថភ្លើងណាមួយ គេនឹងបានឃើញកម្រាលព្រំបៃតងលាតសន្ធឹងដាច់កន្ទុយភ្នែកនារដូវវស្សា។

២. ចូរអ្នកជ្រើសរើសពាក្យ ឬឃ្លាខាងក្រោមដែលបញ្ជាក់មេតាផរ

ភ្នែកខ្មៅរលោង សដូចសំឡី ក្បាលជ្រោយ សមុទ្រមេឃាម្រាមដូចបន្លាក្រូច ចិត្តស្រាលដូចស័ឡី ចង្កេះភ្នំ មាត់កំភ្លាញស្ទឹងឈាម ជើងជណ្ដើរ សមុទ្រទុក្ខ។

៣. ចូរអ្នកតែងកថាខណ្ឌមួយ ដែលរៀបរាប់ពីសម្រស់ធម្មជាតិដោយប្រើប្រាស់មេតាផរ ឬបំរៀបន័យអោយបាន៥ទៅ៧ពាក្យ។

# ចម្លើយ

១. គូសបន្ទាត់ពីក្រោមពាក្យដែលបញ្ជាក់ពី "មេតាផរ"

រថភ្លើងបោលលឿនដូចព្យុះកាត់ព្រៃថ្លង រត់កាត់អូរហើយពុះជ្រែក<u>ជើងភ្នំ</u>ដោយបញ្ចេញសន្ធឹកខ្ទ័ររំពងធ្វើឱ្យរញ្ជួយផែនពសុធា។ បើគេសម្លឹងតាមបង្អួចនៃទូរថភ្លើងណាមួយ គេនឹងបានឃើញកម្រាលព្រំបៃតងលាតសន្ធឹងដាច់<u>កន្ទុយភ្នែក</u>នារដូវវស្សា។

២. ពាក្យ ឬឃ្លាខាងក្រោមដែលបញ្ជាក់មេតាផរគឺ៖

*ក្បាលជ្រោយ សមុទ្រមេឃា ចង្កេះភ្នំ មាត់កំភ្លាញ ស្មឹងឈាម ជើងដណ្ដើរ សមុទ្រទុក្ខ។*

៣. តែងកថាខណ្ឌមួយដែលរៀបរាប់ពីសម្រស់ធម្មជាតិ ដោយប្រើប្រាស់មេតាផរ ឬបំរៀបន័យអោយបាន៥ទៅ៧ពាក្យ៖

គឺម្ហរដូវចូលមកដល់ហើយ *ជំនោរស្នេហ* ពីជើងក៏ចាប់ផ្ដើមអណ្ដែតខ្លួននាំអាកាសធាតុត្រជាក់ភ្ជាប់មកជាមួយ នូវក្លិនក្រអូបពិដោរនៃក្លិនស្រូវដ៏ប្រហើរ។ វាលស្រែ*ពណ៌មាស* ជាកម្រាលព្រំលាតសន្ធឹងដាច់*កន្ទុយភ្នែក* ទៅដល់*ជើងមេឃ*។ បក្សីចាបចៀបហិចហើរពាសពេញ ក្រោម*មេឃស្រករនាគ* ដោយបញ្ចេញសំឡេងគ្រលួច ហាក់ដូចជួប*សមុទ្រទុក្ខ* មិនអាចដោះស្រាយបានទោះបីជារដូវនេះស្រូវសំបូរហូរហៀរយ៉ាងណាក៏ដោយ...។

# វិលើកបញ្ញត្តិ  : ជួន ផ្ទួន រណ្តំ

## លំហាត់

១. ចូររកព្យាង្គជួនក្នុងវគ្គខាងក្រោម៖

ឱបករណ៍ភ្លេងខ្មែរមានច្រើនមុខ រៀបចំដាក់ទុកប្រមូលផ្តុំ
ច្រៀងរ៉ាំដេញដំគោះកូតផ្លុំ  គឺយើងចេះផ្សំទើបពីរោះ។

២.ចូររកព្យាង្គផ្ទួនក្នុងវគ្គខាងក្រោម៖

កំពឹសតោងរឹសកំពីងពួយ  កំពតស្ទុះស្ទួយពីចម្ងាយ
ពើបពះពានលើកំពូលបាយ  កំពុងវាត់វាយកំពឹសពង។

៣.ចូររកព្យាង្គរណ្តំក្នុងវគ្គខាងក្រោម៖

កញ្ចុះស្ទុះចឹកកញ្ចាក់ស្លា  ត្រីឆ្លាំងហែលឆ្លារាត់ឆ្ងាយ
អណ្តែងអណ្តើកអណ្តែតកាយ  ក្លាំងហាយហែលលាយនឹងក្លាំងហាត

## ចម្លើយ

**១. ព្យាង្គជួនក្នុងវគ្គខាងក្រោម ៖**

-ព្យាង្គទី៧(*មុខ*)នៃឃ្លាទី១ចួននឹងព្យាង្គទី៤*(ទុក)* នៃឃ្លាទី២។

-ព្យាង្គទី៧(*ផ្តុំ*)នៃឃ្លាទី២ចួននឹងព្យាង្គទី៧*(ផ្លុំ)*នៃឃ្លាទី៣  ចួនព្យាង្គទី៤ (*ផ្សំ*)នៃឃ្លាទី៤។

**២. ព្យាង្គផ្ទួន**

-ផ្ទួនព្យាង្គ "*កំ ស្ទ*" នៅក្នុងវគ្គលើពាក្យ(*កំពឹស កំពីងពួយ កំពត កំពូល បាយ កំពុង,ស្ទុះស្ទួយស្ទាក់*)

**៣. ព្យាង្គរណ្តំ**

-រណ្ដំព្យញ្ជនៈ "ក ស ឆ ណ អ ហ រ ជ" ក្នុងវគ្គដែលមានពាក្យ(*កញ្ចុះ ចឹក កញ្ជាក់ ឆ្លាំង ឆ្លា ឆ្ងាយ រា រក់ ស្ទុះ ស្លា អណ្ដែង អណ្ដើក អណ្ដែត ត្រាំងហាយ ត្រាំងហាត លាយ ហែល*)

-រណ្ដំស្រៈ នៅលើពាក្យ (*កញ្ចុះ ស្ទុះ កញ្ជាក់ ស្លា រា ឆ្ងាយ អណ្ដែង អណ្ដែត ត្រាំងហាយ ត្រាំងហាត លាយ* )។

# រលឹកបញ្ញត្តិ កាព្យមាត្រ

## លំហាត់

ចូររាប់ចំនួនព្យាង្គនៅក្នុងឃ្លា និងចំនួនឃ្លានៅក្នុងវគ្គនៃអត្ថបទដកស្រង់ខាងក្រោម។

## ចម្លើយ

១. បទពាក្យ៧ ក្នុងមួយវគ្គ៤ឃ្លា។ ក្នុងមួយឃ្លាមាន៤ព្យាង្គគ្រប់ឃ្លាទាំងអស់។

២. បទពុំនោល ក្នុងមួយវគ្គមាន៤ឃ្លា។ ឃ្លាទី១ និងឃ្លាទី៣មាន៤ព្យាង្គ ឯឃ្លាទី២និងទី៤មាន៦ព្យាង្គ។

៣. បទភុជង្គលីលា ក្នុងមួយវគ្គមាន៣ឃ្លា។ ឃ្លាទី១មាន៦ព្យាង្គ ចំណែកឃ្លាទី២និងទី៣ មាន៤ព្យាង្គ។

៤. បទព្រហ្មគិតិ ក្នុងមួយវគ្គមាន៤ឃ្លា។ ឃ្លាទី១និងទី៣មាន៥ព្យាង្គ ចំណែកឃ្លាទី២ និងទី៤មាន៦ព្យាង្គ។

៥. បទកាកគតិ ក្នុងមួយវគ្គមាន៧ឃ្លា។ ក្នុងមួយឃ្លាមាន៤ព្យាង្គគ្រប់ឃ្លាទាំងអស់។

## អំណាន ឧត្តមទាពជាតិខ្ញុំ

### សំណួរ

១. តើអត្ថបទកំណាព្យខាងលើនេះនិយាយពីអ្វី? ជាបទអ្វី?

២. ចូរបង្ហាញចំណាប់ចួនក្នុងវគ្គទី ១និងទី ២ខាងលើ។

៣. ចូរគូសចំណាប់ចួននិងបង្ហាញពីកាព្យមាត្រក្នុងវគ្គទី១ និងវគ្គទី២។

៤. ចូរពន្យល់ន័យនៃពាក្យ "លូកដៃ" "លេប" ក្នុងអត្ថបទកាព្យ។

៥. ចូររកមេតាផរក្នុងអត្ថបទកំណាព្យខាងលើ។

៦. ចូរពន្យល់ពាក្យស្លោក "ការពារប្រសើរជាងព្យាបាល"

៧. តើអ្នកមានចំណាប់អារម្មណ៍ដូចម្ដេច ចំពោះអត្ថបទខាងលើនេះ?

៨. តើអត្ថបទកំណាព្យខាងលើនេះមានតម្លៃអប់រំដូចម្ដេចខ្លះ?

### ចម្លើយ

១. អត្ថបទកំណាព្យខាងលើនេះនិយាយពីវិសាលភាពទឹកដីរបស់ខ្មែរដ៏សែនធំធេង កាលពីសម័យជ័យវរ្ម័នទី៧ តែក្រោយមកត្រូវ

ចោរសៀមលេបយកបន្តិចម្តងៗ  រហូតដល់ឈ្លានពានយកព្រះវិហារតែមិនបានសម្រេច។ ជាបទពាក្យ៧។

២.ចំណាប់ចួនក្នុងវគ្គទី ១និងទី២គឺ :

**+ចួនក្នុងវគ្គ(វគ្គទី១) :**

-ព្យាង្គទី៧(***ល្វើយ***)ឃ្លាទី១វគ្គទី១ ចួននឹងព្យាង្គទី៤ (***អើយ***) ឃ្លាទី២ វគ្គទី១។

-ព្យាង្គទី៧(***ខ្លា***)ឃ្លាទី២វគ្គទី១ ចួននឹងព្យាង្គទី៧(***គណនា***) ឃ្លាទី៣ វគ្គទី១ ចួននឹងព្យាង្គទី៤(***ណា***) ឃ្លាទី៤វគ្គទី១។

**+ចួនឆ្លងវគ្គ** : ព្យាង្គទី៧(***រាជា***) ឃ្លាទី៤ វគ្គទី១ ចួននឹងព្យាង្គទី៧ (***ភូមា***) ឃ្លាទី២ វគ្គទី២។

**+ចួនក្នុងវគ្គ(វគ្គទី២) :**

-ព្យាង្គទី៧(***ចាម***)ឃ្លាទី១វគ្គទី២ ចួននឹងព្យាង្គទី៤(***សៀម***) ឃ្លាទី២ វគ្គទី២។

-ព្យាង្គទី៧(***ភូមា***)ឃ្លាទី២វគ្គទី២ ចួននឹងព្យាង្គទី៧(***ភ្វា***)ឃ្លាទី៣ វគ្គទី២ ចួននឹងព្យាង្គទី៤(***សោភា***) ឃ្លាទី៤វគ្គទី២។

៣.គូសចំណាប់ចួននិងបង្ហាញពីកាព្យមាត្រក្នុងវគ្គទី ១និងវគ្គទី ២

កាលណោះដីខ្មែរធំល្វឹងល្វើយ   កូនខ្មែរអើយកុំខ្ជីខ្លា
ស្តេចខ្មែរខ្លាំងណាស់ឥតគណនា   កម្រជាតិណាផ្ទឹមរាជា។
ខាងកើតដីខ្មែរទល់ស្រុកចាម   ខាងលិចហួសសៀមទល់ភូមា
ខាងជើងទល់ចិនណាបុត្រភ្វា   ខាងត្បូងសោភាទល់សមុទ្រ។

+កាព្យមាត្រ : ក្នុងមួយល្បះមាន៤ឃ្លា ឃ្លានីមួយៗមាន៧ព្យាង្គ គ្រប់ព្យាង្គទាំងអស់។

៤. ពន្យល់ន័យនៃពាក្យ

- "*លូកដៃ*":មានន័យថា ការជ្រៀតជ្រែកចូលក្នុងកិច្ចការរាជការ។

- "*លេប*": មានន័យថា កាត់យកទឹកដីខ្មែរ។

៥. មេតាផរគឺ ពាក្យ*ហុតទឹកសំឡឹងកាក* : ខ្លួនចង់បានកាកតែធ្វើដូចជាចង់បានទឹក។

៦. ពាក្យស្លោក "*ការពារប្រសើរជាងព្យាបាល*" មានន័យថា ការទប់ស្កាត់រារាំងនៃហេតុការណ៍អាក្រក់ដែលអាចកើតមានមកលើយើង កុំទុកឱ្យវាជ្រៀតជ្រែកចូលមកបានរួចបាននាំគ្នារកវិធីទប់ស្កាត់ព្រោះវានាំឱ្យបាត់បង់ប្រយោជន៍។

៧. ខ្ញុំមានចំណាប់អារម្មណ៍ថាពិតជាបានបណ្តុះបណ្តាលទឹកចិត្តឱ្យចេះស្នេហាជាតិ មោទនភាពជាតិ ហើយនឹងជាតិនិយម។

៨. អត្ថបទកំណាព្យខាងលើនេះមានតម្លៃអប់រំដូចតទៅ ៖

-ស្គាល់ពីវិសាលភាពទឹកដី និងវីរៈក្សត្ររបស់ខ្មែរ

-បណ្តុះទឹកចិត្តស្នេហាជាតិ និងជាតិនិយម

-ការពារទប់ស្កាត់ទឹកដីកុំឱ្យបាត់បង់។

# អំណាន កម្ពុជាមាតុភូមិជាទីស្នេហា

## សំណួរ

១. ពាក្យ "**យើង**" ក្នុងអត្ថបទសំដៅទៅលើនរណា?

២. ចូរចែកអត្ថបទជាផ្នែកៗទៅតាមគោលគំនិត ហើយរកគំនិតសំខាន់នៃផ្នែកនីមួយៗ។

៣. ចូររកល្បះដែលបង្ហាញពីឆន្ទៈនិងការប្តេជ្ញាចិត្តយ៉ាងមោះមុត។ តើអ្នកមានគំនិតស្របជាមួយអ្នកនិពន្ធលើចំណុចសំខាន់ណាខ្លះ? ហេតុអ្វី?

៤. ក្នុងនាមជាសិស្ស តើសកម្មភាពអ្វីដែលកំណត់បានថាស្រឡាញ់ជាតិមាតុភូមិ? ហេតុអ្វី?

៥. ចូរកំណត់ន័យដូចនឹងពាក្យ ល្បីល្បាញ ពិសិដ្ឋ ស្នេហា ផ្តល់ថ្លៃថ្នូរ។

៦. ចូររកពាក្យផ្ទុយនិងពាក្យ រស់ ល្អ បុរាណ ច្រើន ស្ពឹមស្ពែ រុងរឿង។

## ចម្លើយ

១. ពាក្យ "យើង" ក្នុងអត្ថបទសំដៅទៅលើខេមរជនទាំងអស់ ពោលគឺកូនចៅខ្មែរគ្រប់រូប។

២. ចែកអត្ថបទជា៤ផ្នែកទៅតាមគោលគំនិត។

-ផ្នែកទី១ចាប់ពី "ចាប់ផ្ដើម....ព្រះរាជាអច្ឆរិយៈ" *និយាយអំពីប្រាង្គប្រាសាទខ្មែរ។*

- ផ្នែកទី២ចាប់ពី "ក្រៅពី...ធរណី" *និយាយពីសម្បត្តិធម្មជាតិ។*

-ផ្នែកទី៣ចាប់ពី "វត្តអារាម...គ្រប់ៗគ្នា" *និយាយពី មត៌កពុទ្ធសាសនា។*

-ផ្នែកទី៤ ចាប់ពី " យើងជាកូន...បានឡើយ" *និយាយពី ការស្ញប់ស្ញែង និងមានមោទនភាពទៅលើសម្បត្តិទាំងនោះពីសំណាក់កូនខ្មែរ។*

៣.ល្បះដែលបង្ហាញពីឆន្ទៈនិងការប្ដេជ្ញាចិត្តយ៉ាងមោះមុតគឺ "*យើងសូមទទួលមត៌កដ៏ឧត្តុង្គឧត្តមនេះ ដោយទឹកចិត្តស្ងើចសរសើរ និងគោរពដោយស្មោះ ហើយសូមប្ដេជ្ញាចិត្ត ដើរតាមវីរភាពរបស់លោក និងបន្តកសាងស្នាដៃថ្មីៗសម្រាប់ជាកេរមត៌កដល់អ្នកជំនាន់ក្រោយយើងផងដែរ។ ទឹកចិត្តស្នេហារបស់យើងចំពោះមាតុភូមិ ពុំអាចមានឥទ្ធិពលអ្វីមករង្គោះរង្គើបានឡើយ*"។

+គំនិតស្របតាមអ្នកនិពន្ធមាន៖

- យើងសូមទទួលមត៌កដ៏ឧត្តុង្គឧត្តមនេះ

-ប្ដេជ្ញាចិត្ត ដើរតាមវីរភាពរបស់លោក និងបន្តកសាងស្នាដៃថ្មីៗសម្រាប់ជាកេរមត៌កដល់អ្នកជំនាន់ក្រោយយើងផងដែរ។ ព្រោះរបស់ដែលលោកកសាងយើងគួរតែនាំគ្នាយកមកថែរក្សាឱ្យបានល្អ

ហើយកិច្ចការមួយទៀតរបស់មនុស្សគឺ ត្រូវទុកស្នាដៃល្អៗសម្រាប់មនុស្សជំនាន់ក្រោយផងដែរ។

៤. ក្នុងនាមជាសិស្ស សកម្មភាពដែលកំណត់បានថាស្រឡាញ់ជាតិមាតុភូមិគឺត្រូវតែខិតខំរៀនសូត្រឱ្យបានពូកែចប់ចុងចប់ដើម។ ព្រោះមានតែការរៀនសូត្រទេ ដែលអាចឱ្យយើងជួយខ្លួនឯង និងប្រទេសជាតិយើងបានទៅអនាគត។

៥. កំណត់ន័យដូចនឹងពាក្យ៖

- **ល្បីល្បាញ** : *កេរ្តិ៍ឈ្មោះល្បីសុសសាយ លាន់លឺសុសសាយ។*
- **ពិសិដ្ឋ** : *ដ៏ល្អអស្ចារ្យ ដ៏ប្រសើរឧត្តុង្គឧត្តម ប្រសើរដាច់គេ ។*
- **ស្នេហា** : *សេចក្តីស្រឡាញ់ ការចូលចិត្ត ។*
- **ផ្តល់** : *ឱ្យ ប្រគល់ឱ្យ ឧបត្ថម្ភ ជូន។*
- **ថ្លៃថ្នូរ** : *ប្រសើរ ខ្ពង់ខ្ពស់ ឧត្តុង្គឧត្តម។*

៦. ពាក្យផ្ទុយនិងពាក្យ ៖

***រស់*** ផ្ទុយ ***ស្លាប់***។ ***ល្អ*** ផ្ទុយ ***អាក្រក់***។ ***បុរាណ*** ផ្ទុយ ***សម័យ***។ ***ច្រើន*** ផ្ទុយ ***តិច***។ ***ស្គមស្គៃ*** ផ្ទុយ ***តូចទាប***។ ***រុងរឿង*** ផ្ទុយ ***អន់ថយ***។

# ការស្តាប់ ចម្រៀងប្រជាប្រិយ

## សំណួរ

១. តើចម្រៀងនេះនិយាយពីអ្វី?

២. តើចម្រៀងនេះមានអត្ថន័យនិងតម្លៃអប់រំដូចម្ដេច?

៣. តើនៅក្នុងបទចម្រៀងនេះមានបង្ហាញលក្ខណៈនៃកំណាព្យត្រង់ចំណុចណាខ្លះ?

៤. តើអ្នកយល់ថាអត្ថន័យនៃបទចម្រៀងនេះស្ដែងចេញនូវមោទនភាពជាតិដូចម្ដេចខ្លះ?

## ការនិយាយ បកស្រាយអត្ថន័យសុភាសិត

### លំហាត់

ចូរប្អូនចាប់ដៃគូរក្នុងក្រុមពីរៗនាក់ រួចជ្រើសរើសប្រធានបទនៃសុភាសិតដុចខាងក្រោមណាមួយដែលក្រុមពេញចិត្ត ហើយឡើងនិយាយបកស្រាយម្ដងមួយក្រុមៗបង្ហាញគ្នាទៅវិញទៅមក៖

១. តក់ៗ ពេញបំពង់ ឆុងៗកន្លះក្រហែត។

២. ចង្កឹះមួយបាច់កាច់មិនបាក់។

៣. ចេះដប់មិនស្មើនឹងប្រសប់មួយ។

៤. អូសទុកកុំឱ្យល្អាន ចាប់ត្រីបានកុំឱ្យល្អទឹក។

៥. ធ្វើស្រែចម្ការឱ្យមើលស្មៅ ទុកដាក់កូនចៅមើលទៅសណ្ដាន

៦. ធ្វើទីលំនៅ មើលភូមិស្ថាន បរិភោគប្រមាណមើលអាហារ។

៧. សន្សឹមៗកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា។

៨. វិជ្ជានិងវ័យមនុស្ស មិនគួរឱ្យខុសជំនាន់គ្នា
វ័យច្រើនត្រូវចេះចម្រើនវិជ្ជា ទាំងពីរស្មើគ្នាទើបប្រពៃ។

៩. វែងផុតត្រឹមពាក្យសំដី ខ្លីផុតត្រឹមមិននិយាយ។

១០. ទោះយល់ឆ្ងាយកុំណាយខំ ទោះយល់ជិតកុំណាយខំ

មិនជាក់មើលឱ្យចំ ក្រែងច្រឡំសជាខ្មៅ។

**ចម្លើយ**

និយាយបកស្រាយម្តងមួយក្រុមៗបង្ហាញគ្នាទៅវិញទៅមក៖

១. តក់ៗ ពេញបំពង់ ឆុងៗកន្លះក្រហែត(*ន័យចំ ទឹកធ្លាក់មួយតំណក់ៗអាចពេញបំពង់ តែបើប្រហែសឱ្យធ្លាំងភ្លាត់នឹងកំពប់ចោល។ ន័យធៀប ធ្វើការអ្វីត្រូវតែសន្សំបន្តិចម្តងៗកុំអាលឆេវឆាវយូរឆាប់នឹងបានសម្រេចបំណង។*

២. ចង្កឹះមួយបាច់កាច់មិនបាក់(*ន័យចំ ចង្កឹះមួយផុយស្រួយស្រួលកាច់ តែចង្កឹះមួយបាច់កាច់មិនបាក់ទេ។ ន័យធៀប កម្លាំងនៃសាមគ្គីគ្នាអាចទទួលជោគជ័យរាល់ភារកិច្ចលើខ្មាំងសត្រូវ)*។

៣. ចេះដប់មិនស្មើនឹងប្រសប់មួយ(*មានន័យថា ធម្មតាអ្នកចេះតែងដើរតាមក្បួន តែសភាពការពិតវាប្រែប្រួលទៅតាមកាលៈទេសៈ មនុស្សដែលចេះបត់បែន នោះគឺជាមនុស្សប្រសប់ ប្រសើរជាងអ្នកដែលចេះតែក្បួនទៅទៀត ព្រោះព្រឹត្តិការណ៍ក្នុងលោកវាតែងតែប្រែប្រួលពីក្បួនខ្លះ*។

៤. អួសទុកកុំឱ្យល្ហាន ចាប់ត្រីបានកុំឱ្យល្អក់ទឹក(*ន័យចំ ទាញទូកមិនត្រូវឱ្យសល់ដានជិតជាប់នៅលើដី ចំណែកការចាប់ត្រីវិញ ត្រូវ*

តែទុកទឹកឱ្យថ្លាងាយស្រួលនឹងមើលឃើញត្រី។ ន័យធៀប ធ្វើកិច្ចការអ្វីមិនត្រូវបន្សល់ស្លាកស្នាម ឬរឿងសៅហ្មងដែលដិតដាមនៅក្នុងចិត្ត ដែលជាត្រណោត ដោតកដោយខ្លួនឯងនោះទេ)។

៥. ធ្វើស្រែចម្ការឱ្យមើលស្មៅ ទុកដាក់កូនចៅមើលទៅសណ្ដាន (ន័យគឺកន្លែងណាដែលមានស្មៅដុះ គឺជាប្រភពនៃជីវជាតិ និងសំណើមនៃទឹក ស្រូវក៏ប្រភេទនៃស្មៅមួយដែរ បើយកដីនោះប្តូរពីស្មៅដាក់ស្រូវប្រាកដ ជាបានផលច្រើន ចំណែកការរើសគូរស្រករឱ្យកូនប្រុសស្រី ក៏គួរតែស៊ើបសួរអំពីប្រវត្តិពូជពង្សរបស់គេឱ្យច្បាស់ដែរ ព្រោះជីវិតមនុស្សរៀបការបានតែម្ដងទេ សម្រាប់ភាពបរិសុទ្ធ បើខុសហើយគ្មានអ្វីជួសជុលបាន)។

៦. ធ្វើទីលំនៅ មើលភូមិស្ថាន បរិភោគប្រមាណមើលអាហារ (ន័យចំ ធ្វើផ្ទះត្រូវនៅជាមួយអ្នកភូមិ ចំណែកញ៉ាំអាហារត្រូវចេះប៉ាន់ប្រមាណគួរ ឬមិនគួរក្រែងវាគ្រោះដល់សុខភាព។ ន័យធៀប ធ្វើអ្វីត្រូវឱ្យស្របទៅតាមកាលវេលា និងស្របទៅតាមគេឯង ត្រូវគុណគួរឱ្យបានម៉តច៉ត់កុំធ្វើអ្វីតាមតែចិត្តឯង ហើយខុសគេ ត្រូវចេះប៉ាន់ប្រមាណមើលសមត្ថភាពនិងលទ្ធភាពខ្លួនផង)។

៧. សន្សឹមៗកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា(ន័យចំពេលបរទេះគោក្របីជំរើសះ បំបោលរត់ខ្លាំងអាចធ្លោះធ្លោយកណ្ដាលផ្លូវ។ន័យធៀប កិច្ចការងារត្រូវធ្វើសន្សឹមបន្តិចម្ដងៗ មើលកាលៈ-

*ទេសៈ និងសភាពការណ៍ ប្រមាណសមត្ថភាព និងលទ្ធភាពទើបទទួលជោគជ័យ)។*

៨. វិជ្ជានិងវ័យមនុស្ស មិនគួរឱ្យខុសជំនាន់គ្នា
វ័យច្រើនត្រូវចេះចម្រើនវិជ្ជា ទាំងពីរស្មើគ្នាទើបប្រពៃ។

*(ន័យ មនុស្សមិនត្រូវបណ្ដោយពេលឱ្យផុតទៅ ដោយឥតប្រយោជន៍នោះទេ ត្រូវរកវិជ្ជាមកដាក់ខ្លួនឱ្យទាន់កាលវេលា។ ក្មេងត្រូវប្រឹងរៀន វ័យកណ្ដាលប្រឹងធ្វើការ ចាស់កាលណាស្រណុកដូចនេះជីវិតគឺជាការសិក្សារៀនសូត្រគ្មានទីបញ្ចប់)។*

៩. វែងផុតត្រឹមពាក្យសំដី ខ្លីផុតត្រឹមមិននិយាយ

*(អណ្ដាតជាមធ្យោបាយ ហើយក៏ជាអាវុធដ៏គួរឱ្យខ្លាច។ បើគង់តែនិយាយគួរប្រើសំដីមាស ដើម្បីស្រាយបញ្ហា បើគិតថាគ្មានផលទេ សូមបិទមាត់កុំនិយាយអ្វីទាំងអស់។ មួយវិញទៀត រឿងល្អ ឬរឿងអាក្រក់នឹងត្រូវគេលើកមកនិយាយគ្មានពេលដាច់ តែបើយើងមិនបានធ្វើអ្វីខុស អ្វីគ្រប់យ៉ាងត្រូវចប់ដ៏ល្អ)។*

១០. ទោះយល់ឆ្ងាយកុំណាយខំ ទោះយល់ជិតកុំណាយខំ
មិនជាក់មើលឱ្យចំ ក្រែងប្រឡំសជាខ្មៅ។

*(មិនត្រូវមើលងាយស្ថានការណ៍ជាដាច់ខាត ហើយព្យាយាមស្វែងយល់ស្ថានការណ៍ឱ្យជាក់ច្បាស់ សុំលើកយកមកបរិយាយ)។*

# សំណេរ អត្ថបទកំណាព្យ

## លំហាត់

១. ចូរប្អូនតែងអត្ថបទកំណាព្យបទពាក្យ ៧ឱ្យបានចំនួន ៥វគ្គ ដែលទាក់ទងប្រធានបទ "មោទនភាពជាតិខ្មែរ"

ចម្លើយ (st)

- ដីខ្មែរសំបូរដោយភោគទ្រព្យ សម្បត្តិល្អគាប់ឥតគណនា
  ព្រៃព្រឹក្សភ្នំខ្យល់ដីគង្គារ ប្រជាគ្រប់គ្នាចាយពុំអស់។
- ក្រោមដីមានរ៉ែពីធម្មជាតិ ផ្តល់ផលឥតឃ្លាតមិនចេះខ្សោះ
  ប្រេងថ្មដែកប្រាក់គ្រប់កៀនកោះ ត្បូងពេជ្រល្អខ្វោះនៅក្រោមដី។
- ប្រាសាទបុរាណឈរត្រៀបត្រា ទេសចរណ៍ខ្មៀវខ្វាមានប្រុសស្រី
  យកប្រាក់ឱ្យខ្មែររៀងរាល់ថ្ងៃ ជីវិតថ្លាថ្លៃព្រោះទ្រព្យា។
- បឹងទន្លេសាបសម្បូរត្រី មេគង្គផ្តល់ដីជីជាតិជា
  កសិករធ្វើស្រែបានគ្រប់គ្នា ព្រោះព្រះគង្គាររារគ្រប់ស្ថាន។
- ព្រៃឈើក្រាលគ្របពាសពេញដី ជម្រកសត្វព្រៃរស់សុខសាន្ត
  មិនឱ្យព្យុះភ្លៀងជំនន់បាន ខ្មែរជួបសាន្តគ្រានតទៅអើយ។

# មេរៀនទី៣ ការទទួលស្គាល់ការពិត

## បំណិន ទម្រង់និងធាតុសំខាន់ៗនៃរឿង

លំហាត់

ចូរអ្នកអានរឿងខាងក្រោម រួចបង្ហាញពីការផ្ដើមរឿង តួរឿងឬដំណើររឿង និងការបញ្ចប់រឿងរបស់រឿងនេះ។

ចម្លើយ

*រឿងភ្នំសំពៅ*

**ក. ផ្ដើមរឿង**

កាលពីព្រេងនាយមានព្រះមហាក្សត្រមួយអង្គព្រះនាម រាជកុល...។

**ខ. តួរឿង ឬដំណើររឿង**

-***តួអង្គ*** : វាជារឿងព្រេងបុរាណបែបប្រឌិតកថា ដូច្នេះឈ្មោះតួអង្គមានលក្ខណៈចំលែកៗដូចជា *ព្រះបាទរាជ កុល*សោយរាជ្យនៅប្រទេសកម្ពុជា។ នាង *សុវណ្ណ មូសា ក្រពើអាធន* ជាកូនចិញ្ចឹមរបស់នាង *នាងរំសាយសក់ ព្រះឥន្ទ្រ និងសេនា* ព្រមទាំង *រាជបរិពា* និង *ជ្រកមាន់ ទា*របស់ស្ដេច *រាជ កុល*។

-***ទីកន្លែង*** : កើតឡើងនៅក្នុងប្រទេសកម្ពុជាដែលមានឈ្មោះកន្លែងមួយចំនួនរហូតមកដល់សព្វថ្ងៃនេះមានដូចជា *ភ្នំដងរែក ភ្នំសំពៅ*

*ភ្នំក្រពើ ភ្នំក្តោងសំពៅ ភ្នំទ្រង់មាន់ ទ្រង់ទា ភ្នំនាងរំសាយសក់ ភ្នំក្រឆាយនាង ភ្នំសងក្បាល វាលចិញ្ចាំពស់ បឹងកន្ទុយក្រពើ បឹងច្រមុះក្រពើ។*

-***បញ្ហាចោទ*** : កើតឡើងដោយសារព្រះរាជ កុលក្បតចិត្តនាងសុវណ្ណមូសា ទៅយកនាងរំសាយសក់។ ក្រពើអាធន ក៏បានទៅសងសឹកជំនួយមាតាធ្វើកល្បបង្កភាពហ៊ឹកវរនៅកណ្តាលសមុទ្រ។

-***ដំណោះស្រាយ*** : នាងរំសាយសក់បានច្បូតសក់ធ្វើឱ្យទឹកសមុទ្ររីងខះជួយសង្គ្រោះក្រុម ព្រះបាទរាជ កុល។

-***ឧត្តមគតិរឿង*** : ខ្លឹមសារនៃរឿងនេះអប់រំឱ្យយើងកុំមានស្នេហាត្រីកោណ កុំបង្កផលលំបាកដល់អ្នកដទៃ កុំគុំគួនដល់អ្នកដទៃ នាំឱ្យអន្តរាយខ្លួនឯងដូចក្រពើអាធន។

**គ. បញ្ចប់រឿង**

បញ្ចប់ដោយឱ្យតួអង្គព្រះបាទកុល រាជបាននាងរំសាយសក់ជាព្រះមហេសីរស់នៅក្នុងនគរយ៉ាងសុខសាន្ត។

## អំណាន រឿង ទ្និសុពណ៌កាលី

### សំណួរ

១. តើរឿងនេះមានតួអង្គណាខ្លះ? តើតួអង្គទាំងនោះធ្វើសកម្មភាពអ្វីខ្លះ?

២. ចូរបង្ហាញតួអង្គឯក និងតួអង្គរងដោយបញ្ជាក់អំណះអំណាងឱ្យបានច្បាស់លាស់។

៣. ចូរបង្ហាញពីការផ្តើមរឿង តួរឿង និងការបញ្ចប់រឿង។

៤. តើរឿងនេះមានខ្លឹមសារសំខាន់ៗដូចម្តេចខ្លះ?

៥. ចូរធ្វើការសិក្សាអំពីកាលអាកាសនៃរឿង។

៦. ចូរបង្ហាញពីបញ្ហាចោទនិងដំណោះស្រាយរឿង។

៧. ចូរបកស្រាយពីអត្ថន័យនៃរឿងឱ្យបានក្បោះក្បាយ។

**ចម្លើយ**

១. រឿងនេះមានតួអង្គដូចជា ៖

**-ក្រពើសុពណ៌កាលី** : អាស្រ័យក្នុងអន្លង់មួយឈ្មោះអន្លង់សាលី ត្រូវស្លាប់ដោយសារចាញ់ក្រពើនាងឱរ៉ែ។

**-ក្រពើនាងឱរ៉ែ** : ជូនលោកនេន ឆ្លងទៅកាន់ត្រើយជារៀងរាល់ថ្ងៃ ទទួលជោគជ័យលើក្រពើសុពណ៌កាលី ហើយនឹងក្រពើបច្ចាមិត្តមួយទៀត តែនៅពេលដែលប្រកួតជាមួយក្រពើបច្ចាមិត្តបានលេបលោកនេនទុកក្នុងពោះ បន្ទាប់មកបានខ្ជាក់លោកនេនមកក្រៅ តែលោកនេនបានសុគតទៅហើយ ក្នុងពេលធ្វើបុណ្យក្រពើនាងឱរ៉ែបានទៅដេកលើភ្នក់ភ្លើងស្លាប់ទៅ។

**-យាយតា** : បានចម្លងក្រពើនាងឱរ៉ែទៅកន្លែងក្រពើសុពណ៌កាលី។

**-លោកនេន** ៖ តែងតែជិះនាងឱរ៉េជារៀងរាល់ថ្ងៃ ចុងបញ្ចប់សង្ឃនេះបានសុគតក្នុងពោះនាងឱរ៉េ។

**-ហ្វូងមនុស្ស** ៖ ឈរមើលការប្រយុទ្ធ រវាងសុពណ៌កាលី និងនាង ឱរ៉េ។

២. ***តួអង្គឯក*** ៖ គឺ***ក្រពើនាងឱរ៉េ*** ព្រោះក្រពើនេះមានសកម្មភាពច្រើនជាងគេនៅក្នុងរឿង ចាប់ពីដើមរហូតដល់ចប់ ជាតួអង្គបង្ហាញពីឧត្តមគតិរបស់អ្នកនិពន្ធ។

***តួអង្គរង*** ៖ ***ក្រពើសុពណ៌កាលី លោកនេន យាយតានិងប្រជាជន*** ព្រោះតួអង្គទាំងនេះមានសកម្មភាពតិចតួចនៅក្នុងរឿង ចេញមកគឺដើម្បីឱ្យខ្សែរឿងមានភាពសម្បូរបែប ជាខ្សែដែលទាក់ទងឱ្យយើងដឹងពីតួអង្គឯកតែប៉ុណ្ណោះ។

៣. បង្ហាញការផ្ដើមរឿង តួរឿង និងការបញ្ចប់រឿង

**ក-ការផ្ដើមរឿង**

កាលពីព្រេងនាយមានក្រពើមួយឈ្មោះសុពណ៌កាលី...។

**ខ-តួរឿង**:ដំណើររឿងច្រើនលើកពីប្រវត្តិភូមិស្រុក ទីកន្លែងនានាប្រពៃណីទំនាស់ វិបត្តិផ្សេងៗ នៅក្នុងសង្គមដូចជា ភ្នំសុពណ៌កាលី ទឹកដីខេត្តកំពង់ចាមជាដើម។ ការបង្ហាញឈ្មោះតួអង្គចម្លែកៗ ហើយវាជាបាតុភូតនៃរបបគំហើញមួយដែលចាស់បុរាណប្រឌិតរឿងទៅតាមអ្វីដែលគាត់បានមើលឃើញ។

**គ. បញ្ចប់រឿង**

អ្នកនិពន្ធបញ្ចប់ ដោយបង្ហាញសមិទ្ធិផលប្រាប់មូលហេតុនៃកំណើតភ្នំសុពណ៌កាលី។ ប្រាប់ពីការស្លាប់(ភ្លើងក៏ឆេះក្រពើ...ជាមួយលោកនេនទៅ)

**៤. ខ្លឹមសារសំខាន់ៗមាន៖**

-នាងឱរ៉ៃច្រណែននិងចង់សាកល្បងជាមួយសុពណ៌កាលី

- ការប្រកួតនិងទទួលជ័យជំនះលើក្រពើសុពណ៌កាលី

- លាក់លោកនេនក្នុងពោះដើម្បីប្រកួតជាមួយបច្ចាមិត្ត

-លោកនេនត្រូវស្លាប់ក្នុងពោះក្រពើនាងឱរ៉ៃ

-នាងឱរ៉ៃរត់ទៅដេកលើភ្នក់ភ្លើងស្លាប់ទៅតាមលោកនេន។

**៥. កាលអាកាសនៃរឿង៖**

**-កាលកើតឡើងកាលពីព្រេងនាយ** : *កាលពីព្រេងនាយ ក្នុងសម័យជាមួយគ្នានោះ ថ្ងៃមួយ កាលបើមានជ័យជំនះហើយ ចំនួនកន្លះថ្ងៃ ចំណេរកាលក្រោយមក ថ្ងៃមួយ...។*

**-អាកាស** : *អន្លង់សាលី ឃុំមហាលាភ ស្រុកកោះសុទិន ខេត្តកំពង់ចាម ត្រើយ ត្រើយខាងស្តាំ ចិញ្ចើមច្រាំង បង្គោល ភ្នំសុពណ៌កាលី ។*

**៦. បញ្ហាចោទនិងដំណោះស្រាយរឿង៖**

**-បញ្ហាចោទ** :

*គ្រាន់តែឮសំដីប្រជាជននាងឱរ៉ៃចង់យកឈ្នះក្រពើសុពណ៌កាលី , ជួបក្រពើបច្ចាមិត្ររកកន្លែងលាក់លោកនេនមិនបាន, តូចចិត្តនឹងការស្លាប់របស់លោកនេន។*

**-ដំណោះស្រាយ**

*ទៅប្រគួតយកជ័យជំនះលើសុពណ៌កាលី, លាក់លោកនេននៅក្នុងពោះយកជ័យជំនះលើបច្ចាមិត្ត, ស៊ូស្លាប់ទៅតាមលោកនេន*

**៧. អត្ថន័យនៃរឿង៖** (រៀបរាប់អំពីដំណើរជីវិតរបស់ក្រពើនាងឱរ៉ៃដែលមានគំនិតចក្រពត្តិនិយមចុងបញ្ចប់មានតែការវិនាសខ្លួនឯងពោលគឺកម្មនាងបានសាងសម្លាប់ក្រពើសុពណ៌កាលី)។

**មូលបញ្ហា** គឺបណ្តាលមកពីនាងឱរ៉ៃមានចរឹកមានះមិនចាញ់អ្នកណាទាំងអស់។

**ឧត្តមគតិ** កុំឱ្យយើងមានគំនិតច្រណែនឈ្នានីសត្រូវចេះដឹងគុណនិងការពារទៅលើចៅហ្វាយនាយ។

# វេយ្យាករណ៍ កំណើតនាមករណ៍ឬករណៈនាម និងនាមការក៍ឬការកៈនាម

## លំហាត់

១. ចូរស្រង់នាមករណ៍ពីប្រអប់ខាងក្រោម។

សំដី ពពក កំណើត អ្នកចម្រៀង ទំនប់ ល្បឿន សេចក្ដីចម្រើន ទំនុក សៀវភៅ អ្នកច្បាំង ទន្លេ ភាពរីករាយ វាលស្រែ ដំណោក ប្រទេស ចំណុះ សាលារៀន ការការពារ ចំណែក ចងចាំ បំណែក ផ្ទះ ដំណាំ សេចក្ដីថ្លៃថ្នូរ អ្នកនេសាទ ដើមឈើ ពីរោះ ជម្ពុះ សំណើម ការលំបាក។

២. ចូរធ្វើកម្លាយពាក្យខាងក្រោមឱ្យទៅជានាមករណ៍។

| ពាក្យឫស | នាមករណ៍ |
|---|---|
| កាន់ | |
| សើម | |
| បាក់ | |
| ចែក | |
| កាច | |
| រុងរឿង | |
| ដាំ | |

| | |
|---|---|
| ខុស | |

៣. ចូរតែងល្បះដោយប្រើនាមករណ៍ឱ្យបានប្រាំល្បះ។

៤. ចូរស្រង់នាមការក៍ពីប្រអប់ខាងក្រោម។

អ្នកលេង អាកាស អ្នកទេសចរ អ្នកខ្លាំង បិសាច កម្រៃ ចំណូល អ្នកតស៊ូ សមុទ្រ ដក អ្នកនយោបាយ ថ្មើរព្រៃ ស្នូម ចំណាក អ្នកស្រុក ការរីកដុះដាល ឆ្នាំ អ្នកការពារ ណាមរា ការសិក្សា អ្នកភូមិ អ្នកលឿង អ្នកនិពន្ធ តំបន់ អ្នកយាម ដើមស្វាយ អ្នកទាប កម្មករ

៥. ចូរធ្វើកម្លាយពាក្យខាងក្រោមឱ្យជានាមការក៍។

| ពាក្យកម្លាយ | នាមការក៍ |
|---|---|
| កាន់ | |
| សើច | |
| ស្លូត | |
| ភ្នំ | |
| ចាញ់ | |
| ខុស | |
| ទោស | |
| ខ្លាំង | |
| ខ្វាត់ | |
| ចង | |

| | |
|---|---|
| ធ្ងន់ | |
| ច្រូត | |
| ពោល | |
| កាច | |
| ផឹក | |
| កើត | |

៦. ចូរតែងល្បះដោយប្រើនាមការក៍ឱ្យបានប្រាំល្បះ។

**ចម្លើយ**

១. ស្រង់នាមករណ៍ពីប្រអប់ខាងក្រោម : *សំដី កំណើត ទំនុក ភាពរីករាយ ដំណោក ចំណុះ ការការពារ ចំណែក បំណែក ដំណាំ សេចក្តីថ្លៃថ្នូរ ជម្នះ សំណើម ការលំបាក។*

២. ធ្វើកម្លាយពាក្យខាងក្រោមឱ្យទៅជានាមករណ៍៖

| ពាក្យឫស | នាមករណ៍ |
|---|---|
| កាន់ | កំណាន់ |
| សើម | សំណើម |
| បាក់ | ការបាក់ កំបាក់ |
| ចែក | ចំណែក |
| កាច | កំណាច |
| រុងរឿង | ភាពរុងរឿង |

| | |
|---|---|
| ដាំ | ដំណាំ |
| ខុស | កំហុស |

៣. ល្បះដោយប្រើនាមករណ៍ឱ្យបានប្រាំល្បះ៖

- *ជំនោរ* បក់បោកលើវាលស្រែពណ៌មាស។
- *ល្បើក* អង្គរវត្តជាស្នាដៃរបស់ អ្នកប៉ាង។
- *ទំនាប* បឹងទន្លេសាប ដីមានជីជាតិច្រើនណាស់។
- នារី ធ្វើ *ការគោរព* ជីដូនជីតា។
- ប្រទេសកម្ពុជាមាន *កំណើន*សេដ្ឋកិច្ចពីរភាគរយ។

៤. ស្រង់នាមការក៏ពីប្រអប់ខាងក្រោម : *អ្នកលេង អ្នកទេសចរ អ្នកខ្លាំថ អ្នកតា អ្នកតស៊ូ អ្នកនយោបាយ ថ្មើរព្រៃ ស្នូម អ្នកស្រុក អ្នកក្រីក្រ ឆ្មាំ អ្នកការពារ អ្នកភូមិ អ្នកលឿន អ្នកនិពន្ធ អ្នកយាម អ្នកទាប។*

៥. ចូរធ្វើកម្លាយពាក្យខាងក្រោមឱ្យជានាមការក៏៖

| ពាក្យកម្លាយ | នាមការក៏ |
|---|---|
| កាន់ | ខ្មាន់ |
| សើច | អ្នកសើច |
| ស្លូត | អ្នកស្លូត |
| ភ្នំ | អ្នកភ្នំ |
| ចាញ់ | អ្នកចាញ់ |
| ខុស | អ្នកខុស |

| | |
|---|---|
| ទោស | អ្នកទោស |
| ខ្លាំង | អ្នកខ្លាំង |
| ខ្វាត់ | អ្នកខ្វាត់ |
| ចង | អ្នកចង |
| ធ្ងន់ | អ្នកធ្ងន់ |
| ច្រូត | អ្នកច្រូត |
| ពោល | អ្នកពោល |
| កាច | អ្នកកាច |
| ជិក | អ្នកជិក |
| កើត | ខ្មើត,ខ្មើត អ្នកកើត |

៦. តែងល្បះដោយប្រើនាមការក៏ឱ្យបានប្រាំល្បះ៖

- *ឆ្មាំ* ព្រះវិហារការពារទឹកដីខ្មែរជានិច្ច។
- *អ្នកស្រែ* ច្រូតស្រូវ។
- *ល្មូន* យក្ខបានស្លាប់ផុតពូជទៅហើយ។
- *អ្នកក្រ* ទួញសោករាល់ថ្ងៃ ឃ្លានអាហារ។
- *ឈ្មួញ* ចិននិងឥណ្ឌា ចូលមកស្រុកខ្មែរមុនគេ។

# វេយ្យាករណ៍ អព្ភន្តរសញ្ញាឬសញ្ញាក្បៀសបើកបិទ

«...»ឬ "..."

## លំហាត់

១. ចូរប្រើសញ្ញាក្បៀសបើកបិទនៅក្នុងល្បះខាងក្រោមឱ្យបានត្រឹមត្រូវតាមកន្លែង។

- អ្នកគ្រូនិយាយទៅកាន់សិស្សពេលទៅដល់ផ្ទះអ្នកត្រូវជំរាបសួរអ្នកមានគុណ។

- អណ្តាតជាអាទ៍កន្លងបានសុខទុក្ខផងពីព្រោះតែអណ្តាតជាសុភាសិតខ្មែរ។

- នៅក្នុងរឿងកូលាបប៉ៃលិន តាចឹមបានផ្តាំចៅចិត្រ ខ្លួនទីពឹងខ្លួន។

- រឿងនេះដកស្រង់ចេញពីគតិលោកភាគទី១។

- សុភាសិតខ្មែរចែងថា ព្យាយាមគង់បានសម្រេច។

២. ចូរតែងល្បះដោយប្រើអព្ភន្តរសញ្ញាឱ្យបានប្រាំល្បះ។

## ចម្លើយ

១. ប្រើសញ្ញាក្បៀសបើកបិទ៖

- អ្នកគ្រូនិយាយទៅកាន់សិស្ស៖ "ពេលទៅដល់ផ្ទះអ្នកត្រូវជំរាបសួរអ្នកមានគុណ"។

- «អណ្តាតជាអាទ៍កន្លងបានសុខទុក្ខផងពីព្រោះតែអណ្តាត» ជាសុភាសិតខ្មែរ។

- នៅក្នុងរឿងកូលាបប៉ៃលិន តាចឹមបានផ្តាំចៅចិត្រ "ខ្លួនទីពឹងខ្លួន"។

- រឿងនេះដកស្រង់ចេញពី "គតិលោកភាគទី១"។

- សុភាសិតខ្មែរចែងថា «ព្យាយាមគង់បានសម្រេច»។

២. តែងល្បះដោយប្រើអព្ភរន្តសញ្ញាឱ្យបានប្រាំល្បះ៖

- ថ្ងៃនេះយើងសិក្សាអំពី "ភាសាខ្មែរ"។
- លោកតាខ្ញុំផ្តាំថា៖ "ក្មេងៗមិនគួរលេងទឹកទេ"។
- «ដើយស្តុកឱនដាក់គ្រាប់» ជាសុភាសិត។
- មេរៀននេះស្រង់ពី "រឿងព្រេងខ្មែរភាគ១"។
- ព្រះរាជសម្ភាបានលើកឡើងថា "ផ្ទះធំស្រណុកត្បិតភរិយាជា"

# វិលើកបញ្ញត្តិ ការប្រើពាក្យ រាជសព្ទ និងសង្ឃសព្ទ

## លំហាត់

១. ចូរស្រង់រាជសព្ទពីក្នុងរឿង "ក្រុងឧដុង្គ"។

២. ចូររកពាក្យមកបំពេញតារាងខាងក្រោម។

| ពាក្យសាមញ្ញ | សង្ឃសព្ទ | រាជសព្ទ |
|---|---|---|
| .............................. | ខមាលទោស | .............................. |
| ស្នាក់នៅ | .............................. | .............................. |

| | | |
|---|---|---|
| ........................ | អាពាធ | ........................ |
| ដៃ | ........................ | ........................ |
| ........................ | ដោះទុក្ខសត្វ | ........................ |
| ........................ | ........................ | គាល់ |
| ........................ | កុដិ | ........................ |
| ........................ | ........................ | ព្រះនេត្រ |
| ជើង | ........................ | ........................ |
| ឡាន | ........................ | ........................ |
| ........................ | ........................ | ប្រសូត |
| កូន | ........................ | ........................ |
| ........................ | ចង្ហាន់ | ........................ |
| ........................ | ........................ | បុត្រី |
| ........................ | និមន្ត | ........................ |
| គោ | ........................ | ........................ |
| ........................ | ........................ | មាតា |
| ........................ | ញោមប្រុស | ........................ |
| ........................ | ........................ | ព្រះរៀម |
| ........................ | ........................ | ព្រះអយ្យកោ |
| ........................ | ព្រះឱស | ........................ |

## ចម្លើយ

១. ស្រង់រាជសព្ទពីក្នុងរឿង "ក្រុងឧដុង្គ"មាន : គង់ អគ្គមហេសី ព្រះអង្គ ប្រថាប់ ទត ព្រះទ័យ តម្រាស់ ទ្រង់ជ្រាប យាង រាជបរិពារ ក្រាបទូល ទូលបង្គំ ...។

២. ពាក្យមកបំពេញតារាងខាងក្រោម

| ពាក្យសាមញ្ញ | សង្ឃសព្ទ | រាជសព្ទ |
|---|---|---|
| .....*សុំទោស*.... | ខមាលទោស | *រាជទានទោស* |
| ស្នាក់នៅ | *គង់* | *គង់* |
| *ឈឺ* | អាពាធ | *ប្រឈួន* |
| ដៃ | *ព្រះហត្ថ* | *ព្រះហត្ថ* |
| *បត់ជើង* | ដោះទុក្ខសត្វ | *ទ្រង់ចូលព្រះបង្គន់ធំ* |
| *ប្រាប់* | *ទូលពិត* | គាល់ |
| *ផ្ទះ* | កុដិ | *ព្រះទីនាំងតំណាក់* |
| ជើង | *ព្រះបាត* | *ព្រះបាត* |
| ឡាន | *យានជំនិះ* | *ព្រះទីនាំង* |
| *ភ្នែក* | *ព្រះនេត្រ* | ព្រះនេត្រ |
| កូន | *កុលបុត្ត* | *បុត្រ* |
| *កើតកូន* | *ប្រសូត* | ប្រសូត |
| *ចំនីអាហារ* | ចង្ហាន់ | *ក្រយា* |

| | | |
|---|---|---|
| *កូនស្រី* | | បុត្រី |
| *អញ្ជើញ* | និមន្ត | *យាង* |
| គោ | | *ព្រះទីន័ងឧសភរាជ* |
| ម្ដាយ | *ញោមស្រី* | មាតា |
| *ឪពុក* | ញោមប្រុស | *បិតា* |
| *បង* | | ព្រះរៀម |
| *តា* | | ព្រះអយ្យកោ |
| *មាត់* | ព្រះឱស | *ព្រះឱស* |

# អំណាន រឿង កំណើករាជធានីភ្នំពេញ

## សំណួរ

១. តើរឿងនេះមានតួអង្គណាខ្លះ? តើតួអង្គទាំងនោះធ្វើសកម្មភាពអ្វីខ្លះ?

២. ចូរបង្ហាញតួអង្គឯកនិងតួអង្គរងដោយបញ្ជាក់អំណះអំណាងឱ្យបានច្បាស់លាស់។

៣. ចូរបង្ហាញពីការផ្ដើមរឿង តួរឿង និងការបញ្ចប់រឿង។

៤. ចូរធ្វើការសិក្សាអំពីកាលអាកាសនៃរឿង។

៥. ចូរបង្ហាញពីបញ្ហាចោទនិងដំណោះស្រាយនៃរឿង។

៦.ចូរបកស្រាយពីអត្ថន័យនៃរឿងឱ្យបានក្បោះក្បាយ។

## ចម្លើយ

១. រឿងនេះមានតួអង្គដូចជា ៖

**-ដូនពេញ** : ស្រង់ព្រះពុទ្ធរូប និងនាំប្រជាជនលើកភ្នំធ្វើវិហារដាក់ព្រះពុទ្ធរូប។

**-អ្នកជិតខាង** : ជួយដូនពេញស្រង់ព្រះរូប និងលើកភ្នំដាក់ព្រះពុទ្ធរូប។

**-ព្រះសង្ឃ** : គង់នៅលើជើងភ្នំនោះ។

**-ព្រះពញាយ៉ាត** : សោយរាជ្យនៅអង្គរ រួចយាងមកសាងរាជធានីនៅស្រីសឈរ បន្ទាប់មកយាងមកនៅភ្នំពេញ។

**-ឧកញ៉ាហោរាធិបតីខៀវ** : ជាអ្នកទស្សទាយថាទីកដីអាគ្នេយ៍នៃភ្នំដូនពេញល្អសម្រាប់សាងរាជធានី។

**-ឧកញ៉ាតេជោស្រី** : អ្នកកាន់ការលើកដីចាក់លុបបំពេញទីក្រុងថ្មីព្រមទាំងលើកដីចាក់បន្ថែមទីក្រុងដូនពេញ។

២. បង្ហាញតួអង្គឯកនិងតួអង្គរង៖

**-តួអង្គឯក** : *យាយពេញ* ព្រោះមានសកម្មភាពច្រើនជាងគេ ហើយជាអ្នក ដែលអ្នកនិពន្ធ បានដំណាលលេចធ្លោជាងគេពីកំណើតរាជធានីភ្នំពេញ។

**-តួអង្គរង**មានដូចជា : *ព្រះពញាយ៉ាត លោកសង្ឃ អ្នកជិតខាង ឧកញ៉ាខៀវ ឧកញ៉ាស្រី* ជាតួអង្គបំពេញបន្ថែមនៅក្នុង

ដំណើររឿង ចេញមកដើម្បីជួយបំពេញនៅខ្សែនៃរឿងឱ្យជាប់ទាក់ទិនជាមួយតួអង្គឯកយាយពេញ ដែលស្តែងពីប្រវត្តិនៃរាជធានីថ្មីនេះ។

៣. បង្ហាញពីការផ្តើមរឿង តួរឿង និងការបញ្ចប់រឿង៖

**ក. ផ្តើមរឿង** : ក្នុងចលនាខេមរនិយមការផ្តើមរឿងមិនទៀងទាត់ដូចជាក្នុងកាលកន្លងទៅហើយនៅគ.ស១៣៧២ជូនចាស់ម្នាក់ឈ្មោះម្នាក់ឈ្មោះ ពេញ...។

**ខ. តួរឿង** : ជារឿងបែបប្រវត្តិសាស្ត្រតួអង្គទីកន្លែងគឺជាបញ្ហាពិតប្រាកដដូចជា យាយពេញព្រះពញាយ៉ាត ឧកញ៉ាខៀវ ឧកញ៉ាស្រី។ ភ្នំដូនពេញ ទន្លេច្រាបឈាម អង្គរ ស្រីសឈរជាដើម។ ឧត្តមគតិ បង្ហាញឱ្យយើងស្គាល់ពីប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងដើមកំណើតទីក្រុងភ្នំពេញ។

**គ. បញ្ចប់រឿង** : ដោយបង្ហាញពីភាពជោគជ័យ នៃការបង្កើត រាជធានីថ្មីនេះ(...ព្រះអង្គបានសាងក្រុងនេះជាលើកទីពីររហូតបានក្លាយជារាជធានីភ្នំពេញរហូតមកដល់សព្វថ្ងៃនេះ។)

៤. ធ្វើការសិក្សាអំពីកាលអាកាសនៃរឿង៖

-កាល : *រវាងគ.ស១៣៧២គឺក្នុងរជ្ជកាលព្រះបាទពញាយ៉ាត*

-អាកាស : *ក្នុងទឹកដីប្រទេសកម្ពុជាមានទឹកដីអង្គរ ស្រីសឈរ ភ្នំដូនពេញ ស្រុកឡាវ ទន្លេច្រាបឈាមជាដើម*។

៥. បង្ហាញពីបញ្ហាចោទនិងដំណោះស្រាយនៃរឿង៖

*-បញ្ហាចោទ* ៖ នៅក្នុងសម័យនោះមានទឹកជំនន់ជន់ជោរតាមដងទន្លេមេគង្គ។ ម្យ៉ាងទៀតថៃឈ្លានពានខ្មែរ ធ្វើឱ្យព្រះពញាយ៉ាតសម្រេចចាកចោលក្រុងអង្គរមកនៅស្រីសឈរ ចំណែកស្រីសឈរក៏លេចទឹកទៀត ទើបធ្វើឱ្យព្រះអង្គសម្រេចចិត្តមកតាំងរាជធានីថ្មី។

*-ដំណោះស្រាយ* ៖ ទាញយកព្រះពុទ្ធរូប និងសាងសង់ព្រះ-វិហារសម្រាប់តម្កល់។ មួយវិញទៀតព្រះពញាយ៉ាតចាកចេញក្រុងអង្គរមកតាំងរាជធានីនៅភ្នំពេញ។

៦.បកស្រាយពីអត្ថន័យនៃរឿង *"និយាយអំពីបុព្វហេតុនៃការកកើតរាជធានីនៅក្រុងភ្នំពេញ ដែលបញ្ហាដំបូងគឺដោយសារតែការជៀតជ្រែកពីសំណាក់បច្ចាមិត្រ ទើបធ្វើឱ្យព្រះបាទពញាយ៉ាតស្វែងរករាជធានីថ្មី។ ស្របពេលដែលឃើញតំបន់ភ្នំពេញជាតំបន់ល្អ ហើយយាយពេញបានស្ថាបនាទីសក្ការបូជាមួយផងនោះ ទើបទីនោះក្លាយជាទីក្រុងរហូតដល់សព្វថ្ងៃនេះ។*

# ការស្តាប់ ធនញ្ជ័យផ្ចាញ់អ្នកប្រាជ្ញចិន

## សំណួរ

១. តើអត្ថបទនេះដកស្រង់ចេញពីប្រភពណា?

២. តើក្នុងអត្ថបទដកស្រង់នេះមានតួអង្គប៉ុន្មាននាក់? តើតួអង្គនីមួយៗបានធ្វើអ្វីខ្លះ?

៣. ចូរអ្នកសិក្សាពីកាលអាកាសនៃអត្ថបទ។

៤. ចូរបង្ហាញពីបញ្ហាចោទនិងដំណោះស្រាយនៅក្នុងអត្ថបទ។

៥. ចូរបកស្រាយពីអត្ថន័យនៃអត្ថបទដកស្រង់ឱ្យបានក្បោះក្បាយ

៦. តើមានរាជសព្ទនិងសង្ឃសព្ទអ្វីខ្លះនៅក្នុងអត្ថបទនេះ?

## ការនិយាយ ការប្រើរាជសព្ទ

### សំណួរ

១. តើតួអង្គសន្ទនាមានដើមកំណើតនៅក្នុងវង្សត្រកូលអ្វី?

២. តើពួកគេសន្ទនាគ្នាអំពីអ្វី?

៣. តើក្នុងខ្លឹមសារសន្ទនា គេប្រើសំនួនពាក្យដូចម្ដេចខ្លះ?

៤. តើគេបានប្រើរាជសព្ទអ្វីខ្លះនៅក្នុងការសន្ទនានោះ?

### ចម្លើយ

១. តួអង្គសន្ទនាមានដើមកំណើតនៅក្នុង*វង្សត្រកូលក្សត្រ*។

២. ពួកគេសន្ទនាគ្នាអំពី "*សុខទុក្ខមាតាបិតារបស់ព្រះអង្គម្ចាស់*"។

៣. ក្នុងខ្លឹមសារសន្ទនា គេប្រើសំនួនពាក្យមានដូចជា ព្រះអង្គម្ចាស់!ទូលបង្គំខានចូលគាល់។...យើងអគុណឯងហើយ...។ ...ចុះព្រះអយ្យការ...។ តើពេលណាទើបទ្រង់យាងត្រឡប់មកវិញ? យើងមិនដឹងច្បាស់ដែរ តែ...។ បើដូច្នោះស្រួលហើយ...។ មិនអីទេ...។

៤. គេបានប្រើរាជសព្ទមាន ព្រះអង្គម្ចាស់ គាល់ មាតាបិតា ព្រះរាជសុខភាព ព្រះដំណាក់ ព្រះរាម ព្រះអនុជ អយ្យកា អយ្យកោ អាពាធ យាង ទូលបង្គំ។

# សំណេរ ការប្រើរាជសព្ទ

## សំណួរ

១. តើអ្នកណាជាអ្នកសរសេរសំបុត្រ? តើសរសេរផ្ញើរទៅឱ្យអ្នកណា?

២. តើពួកគេមានពូជពង្សជាអ្វី?

៣. តើសំបុត្រជាប្រភេទសំបុត្រប្រភេទអ្វី? តើសំបុត្រនេះមានទម្រង់ដូចម្ដេច?

៤. តើក្នុងខ្លឹមសារសំបុត្រគេប្រើសំនួនពាក្យដូចម្ដេចខ្លះ?

៥. តើគេប្រើរាជសព្ទអ្វីខ្លះនៅក្នុងសំបុត្រនេះ?

## ចម្លើយ

១. អ្នកដែលសរសេរសំបុត្រគឺ *បុត្រ*។ សរសេរផ្ញើរទៅកាន់មាតាបិតា។

២. ពួកគេមានពូជពង្សជាក្សត្រ។

៣. សំបុត្រជាប្រភេទសំបុត្រប្រភេទសួរសុខទុក្ខ។ សំបុត្រនេះមានទម្រង់ដូចជា មានក្បាលសំបុត្រមាន ទីកន្លែង កាលបរិច្ឆេទ និង

ចំណងជើង។ *តួសំបុត្រ* និយាយខ្លឹមសារសំខាន់ៗ។ *បញ្ចប់* បញ្ជាក់ពីឈ្មោះអ្នកសរសេរ។

៤. ក្នុងខ្លឹមសារសំបុត្រគេប្រើសំនួនពាក្យដូចជា អស់រយៈពេលជាច្រើនខែទៅហើយ ...។ ក្នុងរយៈពេលនេះ...។ ចំណែកការសិក្សាវិញ...។ តាមរយៈចុហ្មាយនេះ...បុត្រសង្ឃឹមថា...។ ដោយសារពេលវេលាមិនអនុគ្រោះ...។ ជាទីបញ្ចប់...។

៥. គេប្រើរាជសព្ទនៅក្នុងសំបុត្រនេះមាន បុត្រ ព្រះមាតាបិតា ទ្រង់ព្រះទ័យ ប្រទាន ព្រះរាជវង្សានុវង្ស។

**លំហាត់**

ចូរអ្នកសរសេរសំបុត្រមួយច្បាប់ ដោយប្រើប្រាស់រាជសព្ទឱ្យបានត្រឹមត្រូវ។

**ចម្លើយ**

កំពង់ធំ, ថ្ងៃទី១៣មីនា ២០១១

ខ្ញុំម្ចាស់សូមក្រាបថ្វាយបង្គំព្រះអង្គជាទីនឹករឭកដ៏ជ្រាលជ្រៅ! អស់រយៈពេលមួយឆ្នាំមកហើយ ដែលខ្ញុំម្ចាស់បានមករស់នៅក្នុងខេត្តកំពង់ធំដើម្បីបំពេញបេសកម្ម។ ក្នុងរយៈពេលនេះខ្ញុំម្ចាស់មានសុខទុក្ខជាធម្មតាទេ ប៉ុន្តែខ្ញុំម្ចាស់មានសេចក្តីនឹករឭកដល់ព្រះអង្គចំពោះព្រះអង្គយ៉ាងជ្រាលជ្រៅពុំមានអ្វីប្រៀបបាន ទឹកចិត្តខ្ញុំម្ចាស់ពុះកញ្ជ្រោលប្រៀបបីដូចជាភ្នំកំពុងផ្ទុះពីស្នាមអនុស្សាវរីយ៍ដែល

យើងបានសាង។ ខ្ញុំម្ចាស់មិនដឹងថាតើព្រះអង្គសុខទុក្ខយ៉ាងណានោះទេ ហើយព្រះអង្គមាននឹកខ្ញុំម្ចាស់ដូចខ្ញុំនឹកព្រះអង្គដែរឬទេ?

ចំណែកឯបេសកម្មវិញ ខ្ញុំម្ចាស់កំពុងយកព្រះទ័យទុកដាក់ចុះសួរសុខទុក្ខផ្ទាល់ទៅដល់ប្រជានុរាស្ត្រក្នុងមូលដ្ឋាន។ ប្រជាជននៅតាមដងស្ទឹងមានជីវភាពធូរធារណាស់។ ស្ទឹងសែនដ៏វែងអន្លាយពុំស្មើទឡើយពីទឹកចិត្តខ្ញុំម្ចាស់។

តាមរយៈចុតហ្មាយនេះដែរ ខ្ញុំម្ចាស់សូមផ្ញើរសេចក្ដីនឹករឭកនិងសាកសួរសុខទុក្ខចំពោះព្រះរាជវង្សានុវង្សជាពិសេសព្រះមាតានិងបិតារបស់ព្រះអង្គ ខ្ញុំម្ចាស់សង្ឃឹមថាទ្រង់បានសុខទាំងអស់គ្នា

ដោយពេលវេលាមិនអាណិតអាសូរ ខ្ញុំម្ចាស់សូមក្រាបថ្វាយបង្គំលាព្រះអង្គដោយក្ដីសង្វេគឥតទីផុត។ ជាទីបញ្ចប់ខ្ញុំម្ចាស់សូមឱ្យបារមីអង្គរជួយថែព្រះអង្គឱ្យមានសេចក្ដីសុខចម្រើនជារៀងរហូត។

ពីខ្ញុំម្ចាស់ *សុភាព*

# មេរៀនទី៤ សាមគ្គីភាព

## បំណិន ការបង្ហាញប្រធានបទនិងចំណងជើងអត្ថបទ

### លំហាត់

ចូរអានអត្ថបទខាងក្រោម ហើយកំណត់ប្រធានបទនិងចំណងជើងអត្ថបទ។

### ចម្លើយ

១-កំណត់ប្រធានកថាខណ្ឌខាងលើគឺ *"ចចកប៉ុនប៉ងសម្លាប់រាជសីហ៍"*។

-ចំណងជើងអត្ថបទ *"មិត្តទ្រុស្តមិត្ត"*

២-កំណត់ប្រធានកថាខណ្ឌខាងលើគឺ *"តម្លៃនៃវប្បធម៌ខ្មែរ"*

-ចំណងជើងអត្ថបទ *"វប្បធម៌ខ្មែរ"*

## អំណាន ខ្ញុំត្រូវគេនិយាយបញ្ចុះបញ្ចូល

### សំណួរ

១.ចូរសង្ខេបអត្ថបទខាងលើ។

២. តើអត្ថបទនេះនិយាយអំពីអ្វី? (ប្រធានបទ)

៣.តើអ្នកបញ្ចុះបញ្ចូលជានរណា?គេបាននិយាយបញ្ចុះបញ្ចូលដូចម្ដេចខ្លះ?

៤. តើអ្នកណាដែលត្រូវគេបញ្ចុះបញ្ចូល? គេបដិសេធការបញ្ចុះបញ្ចូលដោយប្រើពាក្យអ្វីខ្លះ?

៥.តើការបញ្ចុះបញ្ចូលក្នុងអត្ថបទខាងលើនេះបានសម្រេចលទ្ធផលបែបណា? ចូរបង្ហាញ។

៦.តើអត្ថបទខាងលើនេះមានន័យអប់រំដូចម្តេច?

៧. បើអ្នកជាអ្នកផ្សព្វផ្សាយផលិតផលសាប៊ូក្រអូបម៉ាកX តើអ្នកប្រើពាក្យអ្វីដើម្បីបញ្ចុះបញ្ចូលឱ្យអតិជនជឿជាក់លើសាប៊ូនេះ?

## ចម្លើយ

១.សង្ខេបអត្ថបទខាងលើ៖

ឆ្នាំ១៩២៧ក្រុមហ៊ុនអគ្គីសនី MATSUHITA ចាប់ផ្តើមធ្វើជំនួញជាមួយធនាគារ SUMITOMO។ ដំបូងឡើយក្រុមហ៊ុនអគ្គីសនីមានដៃគូធនាគារ YUUGO ទៅហើយ មិនត្រូវការរកអនាគារទី២ មករកស៊ីជាមួយនោះទេប្រការនេះធ្វើឱ្យបុគ្គលិកធនាគារម្នាក់ SUMITOMO មិនបោះបង់សេចក្តីព្យាយាមគាត់ឡើយ គាត់គឺជាមនុស្សពូកែអត់ធ្មត់ជាទីបំផុត ទោះបីជាម្ចាស់ក្រុមហ៊ុនអគ្គីសនីត្រូវបដិសេធ ជាច្រើនដងជាមួយគាត់ប៉ុណ្ណាក៏ដោយពេលខ្លះម្ចាស់ក្រុមហ៊ុនអគ្គីសនី បានប្រើពាក្យដាច់ណាត់ជាមួយគាត់ តែមិនបានធ្វើឱ្យគាត់បាក់ទឹកចិត្តបាត់បង់នូវការព្យាយាមនោះទេ។ បុគ្គលិកធនាគារម្នាក់នេះបានព្យាយាមអស់រយៈពេល១ឆ្នាំ

ដើម្បីបញ្ចុះបញ្ចូលក្រុមហ៊ុនអគ្គីសនី។ ការព្យាយាមនេះ ទោះបីជាដុំករឹងប៉ុណ្ណាក៏ដោយ ក៏គង់តែដោយសារកំដៅ ម្ចាស់ក្រុមហ៊ុនអគ្គីសនីត្រូវគាត់បញ្ចុះបញ្ចូលបាន នេះក៏ដោយសារតែចិត្តធម្មជាតិរបស់មនុស្សត្រូវទន់ដោយសារមនោសញ្ចេតនា ម្យ៉ាងទៀតការរកស៊ីជាមួយនឹងធនាគារSUMITOMO វាគ្មានចំណុចអវិជ្ជមានផងថែមទាំងគាត់បានធានាពីជោគវាសនា របស់ក្រុមហ៊ុនអគ្គីសនីទៅថ្ងៃអនាគត ជាពិសេសគឺយល់ព្រមឱ្យក្រុមហ៊ុនអគ្គីសនីរហូតដល់២ម៉ឺនយ៉េន ទើបធ្វើឱ្យក្រុមហ៊ុនអគ្គីសនីនេះចៀសផុតពីវិបត្តិក្នុងឆ្នាំ១៩២៧។

២. អត្ថបទនេះនិយាយអំពី (ប្រធានបទ) ***សិល្បៈនៃការបញ្ចុះបញ្ចូលមនុស្ស***។

៣.អ្នកបញ្ចុះបញ្ចូលគឺបុគ្គលិកធនាគារSUMITOMO។គេបាននិយាយបញ្ចុះបញ្ចូលដូចតទៅ : ...ខ្ញុំឃើញថាក្រុមហ៊ុន MATSUHITA នឹងរីកចម្រើននៅថ្ងៃអនាគត។ តាមការសង្កេតរបស់ខ្ញុំនឹងដូចអ្វីដែលខ្ញុំបាននិយាយអ៊ីចឹង។ ដូច្នេះប្រសិនបើក្រុមហ៊ុនរបស់លោករីកចម្រើនទៅមុខទៀតនោះ ខ្ញុំគិតថាកាលដែលយើងជ្រើសរើសធនាគារពីរ ជាដៃគូសំខាន់នោះ នឹងមានចំណុចងាយស្រួលជាងការជ្រើសរើសធនាគារYUUGO តែមួយ។ រឿងមានជាឧទាហរណ៍ជាក់ស្តែងច្រើនដែលជាបទពិសោធ។ ហេតុដូច្នេះហើយដើម្បីឱ្យក្រុមហ៊ុន MATSUHITA បានរីកចម្រើនទៅ

មុខថែមទៀតផងនោះ បានជាខ្ញុំបានជំរុញឱ្យធ្វើជំនួញជាមួយធនាគារ SUMITOMO ។ រឿងនេះមិនគ្រាន់តែដើម្បីធនាគារ SUMITOMOប៉ុណ្ណោះទេ តែខ្ញុំគិតថាការចំណេញដ៏ធំនៃក្រុមហ៊ុន MATSUSHITA។

៤. អ្នកដែលត្រូវគេបញ្ចុះបញ្ចូលគឺខាងក្រុមហ៊ុនMATSUSHITA គេបដិសេធការបញ្ចុះបញ្ចូលដោយប្រើពាក្យដូចជា"ខ្ញុំមានការរអាចិត្តយ៉ាងខ្លាំង...។ ប៉ុន្តែដោយសារតែខ្ញុំមានធុរៈដូចនេះសូមអ្នកអភ័យទោសឱ្យខ្ញុំផង"។

៥.ការបញ្ចុះបញ្ចូលក្នុងអត្ថបទខាងលើនេះបានសម្រេចទទួលលទ្ធផលជាផ្លែផ្កា។ ព្រោះមានសំដីបញ្ជាក់ពីភាគីក្រុមហ៊ុនអគ្គិសនីពោលថា ៖ *"ខ្ញុំព្រមចាញ់លោកហើយ យើងចាប់គិតពីការចូលហ៊ុនរកស៊ីទៅ ប៉ុន្តែចំពោះការរកស៊ីខ្ញុំមានសង្ឃឹមចំពោះលក្ខខណ្ឌមួយ។ បើអ្នកអាចទទួលបានយើងនឹងចាប់ផ្តើមរកស៊ីជាមួយគ្នា"* ។

៦. អត្ថបទខាងលើនេះមានន័យអប់រំដូចជា៖

-សេចក្តីព្យាយាមគង់បានសម្រេច

-ធម្មជាតិនៃមនុស្សសោយមនោសញ្ចេតនាដូច្នេះការប្រើអណ្តាតក៏ជាអាវុធមួយដែរ ដើម្បីសំរេចនូវឆន្ទៈរបស់ខ្លួន។

-ត្រូវចេះបញ្ចុះបញ្ចូល បដិសេធពីការបញ្ចុះបញ្ចូល ហើយត្រូវចេះទទួលយកនូវអ្វីដែលផ្តល់ផលប្រយោជន៍ចំពោះខ្លួន។

៧. ប្រសិនបើខ្ញុំផ្សព្វផ្សាយផលិតផលសាប៊ូក្រអូបម៉ាកXខ្ញុំនឹងផ្សព្វផ្សាយដូចជា៖

*«អ្នកដឹងទេផលិតផលនេះទើបតែចេញថ្មី វាមានក្លិនក្រអូបប្រហើរ ២៤ម៉ោង គេផលិតឡើងដើម្បីតំរូវស្បែកជនជាតិអាស៊ីយើងនេះ មានអតិថិជនជាច្រើនបានប្រើវា ហើយកោតសរសើរវាមិនដាច់ពីមាត់ ក្រុមហ៊ុនយើងខ្ញុំលក់វាដាច់ពីស្តុកជាញយ ខ្ញុំហ៊ានធានាថា ប្រសិនបើអ្នកប្រើ អ្នកច្បាស់ជាចង់ប្រើវាម្តងទៀតមិនខាន។ សាកល្បងប្រើវាមួយប្រអប់សិនចុះ ប្រសិនបើមិនបានដូចអ្វីដែលខ្ញុំនិយាយនោះទេ អ្នកអាចយកវាមកដូរយកលុយវិញបានភ្លាមៗ។*

# វេយ្យាករណ៍ នាមការកិ៍ ឬការកនាម

## លំហាត់

១. ចូររកការកនាមក្នុងល្បះខាងក្រោម៖

តំបន់ព្រៃនេះមិនធ្លាប់មានអ្នកស្រែ ឬអ្នកក្រុងណាមកតាំងទីលំនៅនិងប្រកបរបរនៅទីនេះទេ។ អ្នកដែលរស់នៅតំបន់នេះភាគច្រើនជាទ្រមាក់ដំរី និងអ្នកភ្នំនេះតែម្តង។

២. ចូររកកំណើតនាមការក៍ទាំងនេះ៖

លួច អ្នកជំងឺ ខ្ទាន់ អ្នកប្រូត អ្នកទន្លេ។

រយៈពេលដ៏យូរកន្លងផុតទៅ ប្រជាជនស្លូតត្រង់ពុំអាចរកឃើញការពិតក្នុងរឿងសុបិននេះឡើយ។ លុះដល់សម័យ

វិទ្យាសាស្ត្ររីកចម្រើន មានវេជ្ជវិទូ ដ៏ល្បីម្នាក់ឈ្មោះ "ប៉ាប្រូប" បាន ខិតខំស្រាវជ្រាវអស់មួយជីវិត ទើបគាត់បើកអាថ៌កំបាំងនេះដោយ របៀបវិទ្យាសាស្ត្រ។

លោក "ប៉ាប្រូប" បានបកស្រាយអំពីបញ្ហាសុបិនដូច្នេះ៖ ពេល ថ្ងៃមនុស្សប្រកបការងារគ្រប់ប្រភេទ។ ពេលធ្វើការខួរក្បាលយើង បានទទួលប្រតិកម្មផ្សេងៗនាំឱ្យមានចលនារស់រវើក។ លុះពេល សម្រាន្តលក់ ខួរក្បាលយើងស្ថិតនៅក្នុងសភាពស្ងៀមគ្មានទិដ្ឋភាព ក្រៅណាមួយដែលនាំឱ្យមានប្រតិកម្មដល់ខួរក្បាលយើងឡើយ។ ប៉ុន្តែនៅពេលរលីវៗហៀបនឹងលក់ស៊ប់និងមុនពេលភ្ញាក់ពីដេក(តែ យើងមិនទាន់ដឹងខ្លួនមែនទែន) ពេលនោះអាចឱ្យយើងយល់សុបិន ។ សុបិននេះកើតមកពីការហត់នឿយខ្លាំង។សភាពការដែលជួប ប្រទះនាពេលថ្ងៃជះឥទ្ធិពល ឬមានការដិតដាមនៅក្នុងខួរក្បាល ក៏បណ្តាលឱ្យអារម្មណ៍យើងកើតជាសុបិនផ្សេងៗ ។

## សំណួរ

១. តើអត្ថបទខាងលើនេះនិយាយពីអ្វី?

២. ចូរស្រង់នាមការក៏ ឬការកនាមដែលមានក្នុងអត្ថបទខាងលើ រួចរកកំណើតរបស់នាមការក៏នីមួយៗ។

៣. ក្នុងចំណោមពាក្យខាងក្រោមតើពាក្យណាខ្លះជានាមការក៏ ឬ ការកនាម?

ការសង្កេត អ្នកភូមិ [illegible] សេចក្ដីចម្រើន អ្នកតូច ខ្នាន់កាំភ្លើង អ្នកធំ ការអត់ធ្មត់ អ្នកក្លាហាន។

## ចម្លើយ

១. នាមការក៍មាន *អ្នកស្រែ អ្នកក្រុង អ្នកភ្នំ*។

២. កំណើតនាមការក៍៖

លួច < លួច + ផ្នត់ដែក[-ម-]

អ្នកជំងឺ < អ្នក + ជំងឺ (ន)

ខ្នាន់ < កាន់ + ផ្នត់ដែក[-ម-]

អ្នកច្រូត < អ្នក + ច្រូត (កិ)

អ្នកទន្លេ < អ្នក + ទន្លេ (ន)

## ចំលើយសំណួរ

១. អត្ថបទនេះនិយាយអំពី *មូលហេតុដែលនាំឱ្យកើតមានសុបិន្ត*។

២. ស្រង់នាមការក៍និងកំណើតនាមការក៍៖

-វិជ្ជវិទូ < វិជ្ជ +វិទូ

៣. ក្នុងចំណោមពាក្យខាងក្រោមដែលជានាមការក៍ឬការកនាមមាន : *អ្នកភូមិ អ្នកតូច ខ្នាន់កាំភ្លើង អ្នកធំ អ្នកក្លាហាន*។

# អំណាន សាមគ្គីធម៌

## សំណួរ

១. ដូចម្ដេចហៅថាសាមគ្គីធម៌?

២. ចូររកប្រធានបទនៃអត្ថបទខាងលើ?

៣. តើសាមគ្គីធម៌កើតឡើងបានអាស្រ័យទៅលើអ្វី?

៤. តើយើងត្រូវធ្វើដូចម្ដេចដើម្បីរក្សាចំណងសាមគ្គីភាពឱ្យរឹងមាំ?

៥. តើសាមគ្គីធម៌មានផលចម្រើនប៉ុន្មានយ៉ាង? អ្វីខ្លះ? ចូរពន្យល់ និងលើកឧទាហរណ៍។

៦. ចូររកអត្ថប្រយោជន៍នៃសាមគ្គីធម៌?

## ចម្លើយ

១. សាមគ្គីធម៌ គឺសេចក្ដីព្រមព្រៀងដោយស្រុះស្រួល ប្រកបដោយក្ដីស្មោះអស់ពីចិត្តឥតកិច្ចកល ប្រាសចាកសេចក្ដីវង្វៀសឱសស្ថាន រវាងមនុស្សនិងមនុស្សក្នុងសង្គម។

២. ប្រធានបទនៃអត្ថបទនេះគឺ "**ខ្លឹមសារ និងអត្ថប្រយោជន៍នៃសាមគ្គីធម៌**"។

៣. សាមគ្គីធម៌កើតឡើងបានអាស្រ័យទៅលើចិត្តជាកត្តាកំណត់។ ចិត្តសន្ដោសប្រណី ចិត្តសហការគ្នាដោយសុចរិត ចិត្តចេះលើកលែងឱ្យគ្នា ចិត្តចូលរួមយ៉ាងសកម្មដោយមិនប្រកាន់ពូជសាសន៍

ចិត្តគិតប្រយោជន៍រួមជាធំ ចិត្តប្រកបទៅដោយការសហការគ្នានៅក្នុងសហគមន៍ ចិត្តចេះជួយគ្នា។

៤. ដើម្បីរក្សាចំណងសាមគ្គីភាពឱ្យរឹងមាំយើងត្រូវចេះអត់ធន់ព្យុះពារគ្រប់ឧបសគ្គ ការនឿយហត់ ត្រូវមានសេចក្ដីសន្ដោស និងសេចក្ដីស្មោះស្ម័គ្រ មិនត្រូវមើលងាយជាពិសេសគឺស្មោះត្រង់គ្នាទៅវិញទៅមក។

៥. សាមគ្គីធម៌មានផលចម្រើនពីរយ៉ាង។

ក. *ផលចម្រើនល្អ* : ឧទាហរណ៍ បើសិនជាយើងរួបរួមគ្នា កសាងសាលារៀន ជីកប្រឡាយទឹក បង្កើតប្រព័ន្ធធារាសាស្ត្រនោះយើងនឹងទទួលបានប្រយោជន៍ច្រើនដល់សហគមន៍។

ខ. *ចម្រើនខាងអាក្រក់ :* ឧទាហរណ៍ ការសាមគ្គីគ្នានៅសម័យប៉ុលពតរួបរួមគ្នាសម្លាប់មនុស្ស និងបំផ្លាញមត៌កវប្បធម៌ជាតិទាំងនេះវានាំឱ្យខាតបង់ប្រយោជន៍មនុស្សជាតិ។

៦. អត្ថប្រយោជន៍នៃសាមគ្គីធម៌មានដូចជា ៖

-បង្កើតកំលាំងសាមគ្គីមិនឱ្យសត្រូវមើលងាយ

-ជំរុញការងារឱ្យបានជោគជ័យ

-បណ្ដុះគំនិតថែរក្សាទឹកដីកេរដំណែលវប្បធម៌ សម្បត្តិធម្មជាតិ និងជាតិសាសន៍របស់ខ្លួន

-កម្លាំងច្រើនឈ្នះកម្លាំងតិច ផ្ដល់សន្តិភាពក្នុងចិត្តនិងសង្គមជាតិទាំងមូល។

# អំណាន ដើមកំណើតទំនៀមផ្កាស្លាបី

## សំណួរ

១. តើអត្ថបទនេះដកស្រង់ពីសៀវភៅអ្វី?
២. ចូររកប្រធានបទនៅក្នុងអត្ថបទខាងលើ?
៣. តើចៅក្រមបានបញ្ចុះបញ្ចូលដូចម្ដេចខ្លះ? ដើម្បីឱ្យកុមារទាំងបួនយល់ព្រមបញ្ចប់ជម្លោះដោយសន្តិភាព?
៤. តើអ្នកយល់ស្របតាមការកាត់ក្ដីរបស់ចៅក្រមឬទេ? ព្រោះអ្វី?
៥. ចូរសង្ខេបអត្ថបទខាងលើ។
៦. ចូរស្រង់នាមការក៍ឱ្យបានបី ពាក្យពីក្នុងអត្ថបទខាងលើ។
៧. តើទំនៀមទម្លាប់ ផ្កាស្លាបីបង្ហាញពីផ្នត់គំនិតខ្មែរដូចម្ដេចខ្លះ?

## ចម្លើយ

១. អត្ថបទនេះដកស្រង់ពីសៀវភៅ*ប្រជុំរឿងព្រេងខ្មែរភាគ៩ ឆ្នាំ១៩៧៤*។

២. ប្រធានបទនៅក្នុងអត្ថបទខាងលើនេះគឺ *ដើមកំណើតផ្កាស្លាបី ដែលមាននៅក្នុងពិធីមង្គលការរបស់ខ្មែរ*។

៣. ដើម្បីឱ្យកុមារទាំងបួនយល់ព្រមបញ្ចប់ជម្លោះដោយសន្តិភាព ចៅក្រមបានបញ្ចុះបញ្ចូលដូចជា : បុរសជាហោរាដែលចេះទាយត្រូវលើកជាឪពុកនាង បុរសចេះប្រេស់ឱ្យរស់ជាម្ដាយនាង បុរសចេះបាញ់ធ្នូត្រូវទុកជាបងបង្កើតនាង ព្រោះបងត្រូវការពារសង្គ្រោះ

ប្អូនស្រី ។ ចំណែកបុរសចេះមុជទឹកត្រូវទុកជាប្ដីនាង ព្រោះគេបានទៅប៉ះពាល់នាងមុនគេតាំងពីក្នុងទឹកមកម្លេះ។

**៤. ខ្ញុំយល់ថាតាមការកាត់ក្ដីរបស់ចៅក្រមពិតជាត្រឹមត្រូវ។** ព្រោះគាត់ក្ដីពេញទៅដោយហេតុផល។ ជាធម្មតាបុរសនិងស្រីកាលណាបានប៉ះពាល់ខ្លួនគ្នាហើយគួរណាផ្សំផ្គុំគ្នា កុំឱ្យអសោចកេរ្ដិ៍ទៅថ្ងៃក្រោយ បងប្អូនជាអ្នកជួយសង្គ្រោះគ្នា ម្ដាយជាអ្នកប្រស់ជាអ្នកបង្កើត ចំណែកឪពុកជាអ្នកគន់គូផ្គត់ផ្គង់ពីជោគវាសនាដល់កូនៗទាំងឡាយ។

**៥. សង្ខេបអត្ថបទខាងលើ**

មានព្រះរាជកុមារ៤នាក់ បានចេញទៅរៀនសិល្បសាស្ត្រជាមួយតាឥសី។ ក្រោយពេលចេះសព្វគ្រប់ហើយក៏សុំលោកគ្រូវិលត្រឡប់មកនគរវិញ។ មកដល់ពាក់កណ្ដាលផ្លូវនាំគ្នាសម្រាកក្រោមដើមឈើក្បែរមាត់ទឹក បុរសទាំងបីសួរទៅបុរសជាហោរា បុរសជាហោរាថា ព្រឹកនេះនឹងមានសត្វឥន្ទ្រីយ៍ពាំបុត្រីស្ដេចឆ្លងកាត់ទីនេះ។ ពិតមែនបុរសចេះបាញ់ធ្នូបាញ់ត្រូវសត្វនោះធ្វើឱ្យនាងក្រមុំធ្លាក់ទៅមហាសាគរ បុរសចេះហែលទឹកបានមុជទៅយកនាង បុរសចេះប្រស់ក៏ប្រស់ឱ្យនាងរស់មកវិញ។ បន្ទាប់មកពួកគេទាំងបួន ចង់បាននាងមកធ្វើជាប្រពន្ធរៀងៗខ្លួន ហើយក៏បានទៅរកចៅក្រមជួយកាត់ក្ដី ចៅក្រមសម្រេចឱ្យបុរសចេះងូតទឹកបាននាង

ចំណែកបុរស ចេះទាយធ្វើជាឪពុក បុរសចេះប្រស់ធ្វើជាម្ដាយ ចំណែកបុរសចេះបាញ់ធ្នូធ្វើជាបង។

**៦. រកនាមការក៏ឱ្យបានបីមាន** : *អ្នកបាញ់ អ្នកទៅ អ្នកទាំងបី ។*

**៧. ទំនៀមទម្លាប់ ផ្កាស្លាបីបង្ហាញពីផ្នត់គំនិតខ្មែរដូចតទៅ ៖**

-ការសិក្សារៀនសូត្រ ពិធីមង្គលការ ដែលមានរៀបចំផ្កាស្លា ចំនួនបី ផ្កាស្លាបងសម្រាប់ឪពុក ផ្កាស្លាកណ្ដាលសម្រាប់ម្ដាយ ផ្កាស្លាពៅសម្រាប់បង។ បង្ហាញពីភារកិច្ចដែលមាននៅក្នុងគ្រួសារ ប្ដីប្រពន្ធអាចប៉ះពាល់គ្នាបាន បងប្អូនគ្រាន់ជាអ្នកជួយសង្គ្រោះ ម្ដាយជាអ្នកផ្ដល់កំណើត ចំណែកឪពុកគឺជាអ្នកផ្គត់ផ្គង់សម្បត្តិក្នុង ការរស់នៅ ។ ចំណែកឯគុណាគេរាប់ពីឪពុកមកបង ឪពុកគុណធំ ជាងម្ដាយ ម្ដាយគុណធំជាងបង។

# ការស្ដាប់ ទំនាស់

## សំណួរ

១. ចូរដាក់ចំណងជើងអត្ថបទឱ្យបានសមស្រប។

២. តើអត្ថបទនេះនិយាយពីអ្វីខ្លះ?

៣. តាមរយៈអត្ថបទខាងលើ តើមនុស្សទាំងអស់ចង់បានអ្វីខ្លះ?

៤. តើការចេះអត់ឱនគ្នាទៅវិញទៅមកអាចនាំមកនូវអ្វីខ្លះ?

៥. ដើម្បីរក្សាសន្តិភាពឱ្យស្ថិតស្ថេរ តើអ្នកមានគំនិតយ៉ាងណាខ្លះ?

# ការនិយាយ ចូលរួមពិភាក្សានិងបញ្ចេញមតិ

## សំណួរ

១. តើមេរោគអេដស៍ឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ដោយសារអ្វី?

២. តើអ្នកមានជំងឺអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍មានស្ថានភាពដូចគ្នាឬទេ?

៣. ចូរបង្ហាញពីវិធីការពារកុំឱ្យមានមេរោគអេដស៍។

៤. តាមរយៈអត្ថបទខាងលើ ចូរអ្នកស្រង់ឃ្លា ឬពាក្យដែលគិតថាជាភាសាបញ្ចុះបញ្ចូល។

៥. តើត្រូវប្រើជំនួសពាក្យបែបណាខ្លះ ដើម្បីបដិសេធចំពោះការអូសទាញរបស់មិត្តអាក្រក់ដែលនាំទៅរកភាពវិនាស?

## ចម្លើយ

១. មេរោគអេដស៍ឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ដោយសារ *ឈាមដែលមានផ្ទុកមេរោគអេដស៍។*

២. អ្នកមានជំងឺអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍មានស្ថានភាព មិនដូចគ្នាទេ។ព្រោះអ្នកផ្ទុកមេរោគអេដស៍ មិនទាន់ធ្លាក់ខ្លួនឈឺ ហើយពុំទាន់មានចេញរោគសញ្ញាណាមួយ ដែលបញ្ជាក់ពីអាសន្នដែរ ចំណែកអ្នកជំងឺអេដស៍ គឺជាអ្នកឈឺទ្រុឌទ្រោមមានរោគសញ្ញានៃជំងឺឱកាសនិយមមករាតត្បាតរាងកាយ។

៣. វិធីការពារកុំឱ្យមានមេរោគអេដស៍មាន ៖

-មិនត្រូវមានដៃគូរួមភេទច្រើន

-មិនត្រូវប៉ះពាល់ឈាមដែលមានផ្ទុកមេរោគអេដស៍

-មិនត្រូវប្រើវត្ថុមុតស្រួចរួមគ្នាដោយមិនបានសម្លាប់រោគ

-មុនពេលរៀបការ មានកូន សម្រាលកូន ត្រូវទៅពិនិត្យឈាម។

៤. ស្រង់ឃ្លា ឬពាក្យដែលគិតថាជាភាសាបញ្ចុះបញ្ចូលមាន " *ក្រុមខ្ញុំយល់ស្របនឹងចម្លើយនេះ។ ល្អណាស់ សូមអរគុណ។ ល្អណាស់ សូមអបអរសាទរ។ លើកពីវិធីបង្ការនេះបានត្រឹមត្រូវហើយ ខ្ញុំសូមបន្ថែមទៀត។ អរគុណណាស់ ចំពោះការពិភាក្សាដែលប្រកបអត្ថន័យយ៉ាងជ្រាលជ្រៅសម្រាប់យើងទាំងអស់គ្នា។*

៥. ដើម្បីបដិសេធចំពោះការអូសទាញរបស់មិត្តអាក្រក់ដែលនាំទៅរកភាពវិនាសគេប្រើប្រាស់ពាក្យដូចជា "ខ្ញុំអរគុណហើយ នូវបំណងល្អរបស់អ្នក ប៉ុន្តែពេលនេះខ្ញុំមិនបានទៅជាមួយអ្នកទេ ព្រោះ***ជាប់រវល់***។ អរគុណណាស់ បំណងអ្នកខ្ញុំទទួលហើយ ប៉ុន្តែខ្ញុំ***មិនអាចធ្វើបាន***...។ ***សុខភាពខ្ញុំខ្សោយ***ណាស់ ហើយ***គ្មានលុយទៀត***មិនអាចទៅបានទេ។"

# សំណេរ អត្ថបទបែបបញ្ចុះបញ្ចូល

## លំហាត់

១. ចូរសរសេរអត្ថបទ បញ្ចុះបញ្ចូលដោយរើសយកប្រធានបទខាងក្រោម៖

- ការបញ្ចុះបញ្ចូលឱ្យមិត្តភក្តិឱ្យខំប្រឹងសិក្សា
- ការបញ្ចុះបញ្ចូលមិត្តភក្តិឱ្យចេះសាមគ្គីគ្នា។

## ចម្លើយ

ប្រធានបទ : **ការបញ្ចុះបញ្ចូលមិត្តភក្តិឱ្យចេះសាមគ្គីគ្នា។**

សាមគ្គីភាពជា . អាវុធមួយដែលមិនងាយកាច់បំបាក់បានទេ។ ដូចនេះដើម្បីសម្រេចនូវការប្រកួតបាល់នេះ ក្រុមយើងត្រូវតែពួតជាធ្លុងមួយទើបទទួលជោគជ័យក្នុងការប្រកួតបាល់។

ជាការពិតណាស់ ការស៊ីចង្វាក់គ្នាគឺពិតជាមានតម្លៃ ព្រោះការប្រកួតគ្នានៅក្នុងវេទិការបាល់ទាត់ វាទាមទារខ្លាំងណាស់ នូវកម្លាំងសាមគ្គី។ មិនថាខ្សែប្រយុទ្ធ ខ្សែការពារ ឬ អ្នកយាមទីទេ បើសិនជាមិនចុះសម្រុងគ្នាទេច្បាស់ជាបរាជ័យ ដូចនេះមិត្តទាំងអស់គ្នាដឹងទេ ការប្រកួតនៅពេលនេះ វាសំខាន់ណាស់ ព្រោះជាមុខជាមាត់ជូនសាលាយើង ជាពិសេសគឺយើងក៏បានប្រាក់លើកទឹកចិត្តក៏មិនតិចដែរ។ ដល់ពេលហើយពួកយើង ស៊ូឡើងៗ! វាគ្មានអ្វីក្រៅពី

ការប្រឹងប្រែងរបស់ពួកយើងនោះទេ ដូចនេះសូមពួកយើងចាប់ដៃគ្នាមួយដើម្បីបញ្ជាក់ពីពន្លឺជោគជ័យយើងនៅថ្ងៃស្អែក។

ការសាមគ្គីវាមានសារៈសំខាន់ណាស់ចំពោះយើងជាយុវជនជាកីឡាដ៏ឆ្នើម ឬក៏មិនថាត្រឹមតែកីឡាទេការងារអ្វីក៏ត្រូវការ ការសាមគ្គីគ្នានេះដែរ។

ខ្ញុំយល់ថាប្រធាននេះពិតជាមានតម្លៃណាស់ សម្រាប់យុវជនដើម្បីសាងភាពថ្លៃថ្នូរ។ ដូចនេះយើងទាំងអស់គ្នាត្រូវតែចេះរួបរួមសាមគ្គីគ្នាកុំឱ្យសូន្យ ក្នុងគោលបំណងទទួលជោគជ័យលើការងារគ្រប់កាលៈទេសៈ។

# មេរៀនទី៨ ការកំណត់គោលដៅ

## បំណិន ន័យដូចនិងន័យផ្ទុយ

### លំហាត់

១. ចូររកពាក្យន័យដូចនឹងពាក្យ "ពិសា អធិកអធម មោទនភាព ឧស្សាហ៍ ឧត្តុង្គឧត្តម"។

២. ចូររកពាក្យន័យផ្ទុយនឹងពាក្យ មុខ ក្នុង យូរ ខ្លី ចាស់ ខ្ពស់។

៣. ចូរអានអត្ថបទដកស្រង់ខាងក្រោម រួចស្រង់ពាក្យ ពាក្យន័យដូច និងន័យផ្ទុយដែលមាននៅក្នុងអត្ថបទ។

### ចម្លើយ

១. ពាក្យន័យដូចនឹងពាក្យ៖

| ពាក្យ | ន័យដូច |
|---|---|
| ពិសា | ញ៉ាំ បរិភោគ ឆាន់ សោយ ...។ |
| អធិកអធម | គគ្រឹកគគ្រេង អ៊ូអរ ហ៊ឹកហ៊ាក់...។ |
| មោទនភាព | ភាពរីករាយ ត្រេកអរ អំនួត...។ |
| ឧស្សាហ៍ | ព្យាយាម ខិតខំ ប្រឹង សំភី...។ |
| ឧត្តុង្គឧត្តម | ប្រសើរ ខ្ពង់ខ្ពស់ ថ្លៃថ្នូរ...។ |

២. ពាក្យន័យផ្ទុយនឹងពាក្យ ៖

| ពាក្យ | ន័យផ្ទុយ |
| --- | --- |
| មុខ | ក្រោយ ខ្នង |
| ក្នុង | ក្រៅ |
| យូរ | ឆាប់ រហ័ស លឿន |
| ខ្លី | វែង |
| ចាស់ | ថ្មី |
| ខ្ពស់ | ទាប |

៣ ស្រង់ពាក្យ ពាក្យន័យដូចនិងន័យផ្ទុយដែលមាននៅក្នុងអត្ថបទ

| ពាក្យ | ន័យដូច |
| --- | --- |
| មើល | ទត ទស្សនា គយគន់ ...។ |
| ទៅ | យាង យាត្រា...។ |
| រុងរឿង | ថ្កើងថ្កាន ចំរើន លូតលាស់...។ |
| កសាង | ស្ថាបនា សាងសង់ ...។ |
| សុវណ្ណ | មាស។ |
| សរសេរ | ចារ កត់ត្រា។ |
| ផ្ចិតផ្ចង់ | ប្រិតប្រៀង សំរិតសំរាំង ប្រុងប្រយ័ត្ន...។ |

| ពាក្យ | ន័យផ្ទុយ |
| --- | --- |
| កណ្តាល | គៀន ចំហៀង ខាង...។ |
| ទៅ | មក ត្រឡប់ក្រោយ ។ |
| ស្រួច | ទាល |

| | |
|---|---|
| គ្រច:គ្រចង់ | អួរអាប់ |
| ច្រើន | តិច |
| រុងរឿង | អាប់ឱន អន់ថយ |
| ក្រោយ | មុខ |
| សរសើរ | បង្អាប់ |
| បុរាណ | សម័យ |
| ស្វិត | ស្រស់ |
| ផ្ចិតផ្ចង់ | ខ្ជះខ្ជាយ |

# អំណាន បណ្ដាំឪពុក

## សំណួរ

១. តើកំណាព្យខាងលើដកស្រង់មកពីឯកសារណា? ជាបទអ្វី?

២. តើអត្ថន័យនៃបទកំណាព្យខាងលើនេះមានន័យដូចម្ដេចខ្លះ?

៣. តើពាក្យថា "ដឹងកល ដឹងកិច្ច វាស់រួចសុំមគួរ កុំព្យុហ៍ មធូរ" មានអត្ថន័យដូចម្ដេច?

៤. ចូរពន្យល់អត្ថន័យក្នុងវគ្គ

| | | |
|---|---|---|
| សូរស្លាប់ទៅជា | កុំបង់ធម្មា | ឥរិយាសីលគាប់ |
| ឱ្យគិតជញ្ជីង | រំពឹងឱ្យសព្វ | ពាក្យស្លែងកុំស្អប់ |
| | ពាក្យគាប់ឱ្យយក។ | |

ចង់គង់ឱ្យទុក ចង់បានក្ដីសុខ ឱ្យស្វែងដើររក
ឃើញច្បាស់ធម៌អាថ៌ ឱ្យយកខ្លួនជ្រក ក្ដីសោកមមោក
ឱ្យចៀសចេញឆ្ងាយ។

៥. ចូរបង្ហាញចំណាប់ចូន ផ្ទួនរបស់អត្ថបទកាព្យខាងលើ។

៦. តើអត្ថបទកាព្យខាងលើមានគោលដៅអប់រំកូនចៅយ៉ាងដូចម្ដេចខ្លះ?

## ចម្លើយ

១. កំណាព្យខាងលើដកស្រង់មកពីឯកសារ "*ប្រជុំច្បាប់បណ្ដាំបិតា* ទំព័រទី១ដល់ទី៥ បោះពុម្ពឆ្នាំ១៩៨៧។ ជាបទកាកគតិ។

២. អត្ថន័យនៃបទកំណាព្យខាងលើនេះមានន័យដូចជា៖

- ត្រូវយកបណ្ដាំឪពុកនេះទៅទុកទៅដាក់ជាកេរមរត៌កសម្រាប់ទ្រទង់ជីវិត។

-កូនល្អ ឬកូនអាក្រក់ គឺអាស្រ័យទៅលើឪពុក។

-ចំណេះដឹងប្រៀបបីដូចជាមុខកាំបិត ត្រូវចេះប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ គិតរួចសិនចាំគូ។

-ត្រូវចេះដើរផ្លូវកណ្ដាល ការពារជីវិតខ្លួនទោះស្លាប់ទៅក៏នៅតែជាអ្នកជា។

-ត្រូវចេះស្តាប់ពាក្យល្អទៅឱ្យឆ្ងាយពីអំពើអាក្រក់ ព្យាយាមរកស៊ីដោយអាត្មា។ ត្រូវចេះរាប់អានជាមួយមនុស្សជិតខាង កុំក្អេងក្អាងធ្វើអ្វីហួសពីលទ្ធភាពនិងសមត្ថភាព។

៣. ពាក្យថា "ដឹងកល ដឹងកិច្ច វាស់រួចសុីមគួរ កុំព្យូហ៍ មធូរ" មានអត្ថន័យដូចតទៅ៖

ដឹងកល : ស្គាល់ច្បាស់ពីចរិកពិត។

ដឹងកិច្ច : ស្គាល់ច្បាស់ពីសារជាតិពិតរបស់កិច្ចការអ្វីមួយ។

វាស់រួចសុីមគួរ : គិតរួចសិនចាំធ្វើ។

កុំព្យូហ៍ : មិនឱ្យចេះប្រើកិច្ចកលបោកបញ្ឆោត។

មធូរ : មួរហ្មង។

៤. ពន្យល់អត្ថន័យក្នុងវគ្គ៖

| | | |
|---|---|---|
| សូរស្លាប់ទៅជា | កុំបង់ធម្មា | ឥរិយាសីលគាប់ |
| ឱ្យគិតជញ្ជឹង | រំពឹងឱ្យសព្វ | ពាក្យស្លែងកុំស្អប់ |
| | ពាក្យគាប់ឱ្យយក។ | |
| ចង់គង់ឱ្យទុក | ចង់បានក្តីសុខ | ឱ្យស្វែងដើរក |
| ឃើញច្បាស់ធម៌អាថ៌ | ឱ្យយកខ្លួនជ្រក | ក្តីសោកមមោក |
| | ឱ្យចៀសចេញឆ្ងាយ។ | |

**វគ្គទី១** : ក្នុងខ្លួនត្រូវមានធម៌កិរិយាល្អប្រសើរ ទោះស្លាប់ទៅទុកនូវកេរឈ្មោះល្អប្រពៃ ពាក្យល្អៗដែលគេជាសតៀនត្រូវទទួលយកដើម្បីរចនាជីវិតឱ្យប្រពៃ។

**វគ្គទី២** : បើចង់ថែរក្សាទ្រព្យមិនត្រូវខំខ្ជីខ្ជារ ហើយបើចង់មានសេចក្តីសុខត្រូវមានសេចក្តីស្ងប់ចិត្តដោយធម៌ ចៀសចេញពីរឿងសៅហ្មង។

៥. ចំណាប់ចួន ផ្ទួនរបស់អត្ថបទកាព្យខាងលើគឺ៖

*-ចំណាប់ចួន*

***ក.គំនូសតាងចំណាប់ចួន***

| | | |
|---|---|---|
| ហៃកូនពន្លក | ស្ងួនអើយមាសយក | បណ្តាំបិតា |
| ឪពុកនេះចាស់ | ឥតអ្វីឱ្យបា | ស្ងួនអើយរក្សា |
| | ពាក្យឪពុកនៅ។ | |
| ឱកូនកំសត់ | រៀនឱនរៀនអត់ | រៀនគិតក្នុងក្រៅ |
| រៀនឱនលំទោន | កុំឱ្យហ្មងសៅ | ដល់ខ្លួនកូនពៅ |
| | កេរ្តិ៍ដល់ឪពុក។ | |

| | | |
|---|---|---|
| ១២៣៤ | ១២៣៤ | ១២៣៤ |
| ១២៣៤ | ១២៣៤ | ១២៣៤ |
| | ១២៣៤។ | |
| ១២៣៤ | ១២៣៤ | ១២៣៤ |
| ១២៣៤ | ១២៣៤ | ១២៣៤ |
| | ១២៣៤។ | |

***+ចួនក្នុងវគ្គ***

-ព្យទី៤ ឃ្លាទី១ វគ្គទី១ ចួននឹង ព្យទី៤ ឃ្លាទី២ វគ្គទី១

-ព្យាង្គទី៤ ឃ្លាទី៣ វគ្គទី១ ចួននឹង ព្យាង្គទី៤ ឃ្លាទី៥ វគ្គទី១ចួននឹង ព្យាង្គទី៤ ឃ្លាទី៦ វគ្គទី១។

+*ចួនឆ្លងវគ្គ*

ព្យាង្គទី៤ ឃ្លាទី៧ វគ្គទី១ ចួននឹង ព្យទី៤ ឃ្លាទី៣ វគ្គទី២។

ខ.*ជួន*

ជួនពាក្យ *រៀន* (...រៀនឱនរៀនអត់ រៀនគិតក្នុងក្រៅ រៀនឱនលំទោន) ជួនពាក្យ *សួន*។

៦. អត្ថបទកាព្យខាងលើមានគោលដៅអប់រំកូនចៅដូចតទៅ៖

-កូនត្រូវតែសាងអំពើសុចរិត អំពើល្អ

-ត្រូវស្វែងរកចំណេះវិជ្ជាដាក់ខ្លួន មុននឹងធ្វើអ្វីត្រូវពិចារណាឱ្យបានម៉ត់ចត់

-ត្រូវដើរផ្លូវកណ្ដាលកុំតឹងពេកកុំធូរពេក ប្រកបរបររកស៊ីផ្លូវសុចរិត រាប់អានមិត្តភក្តិដែលមានចិត្តធម៌ ធ្វើជាទីជម្រកសម្រាប់អ្នកដទៃ កុំអួតក្អេងក្អាង ធ្វើអ្វីៗទៅតាមលទ្ធភាពនិងសមត្ថភាព។

# វេយ្យាករណ៍ កំណើតរបស់គុណនាម

## លំហាត់

១. ចូររកនាមដែលប្រើជាគុណនាមឱ្យបាន ៥ ពាក្យដោយបង្កើតជាល្បះបញ្ជាក់ផង។

២. ចូរបង្កើតគុណនាមដែលចេញពី នាម គុណនាម កិរិយាសព្ទឱ្យបាន ៥ល្បះ។

៣. ចូរបង្ហាញវិធីកកើតនៃគុណនាម ដូចជា កំពុក កំប៉ោង កំពៀច កញ្ចោត កម្ទិល។

## ចម្លើយ

១. នាមដែលប្រើជាគុណនាមឱ្យបាន ៥ ពាក្យ

-ខ្លាំង : ***មនុស្សចិត្តខ្លាំង***គឺឃោរឃៅខ្លាំងណាស់។

-ព្រៃ : ***មនុស្សព្រៃ***មានវប្បធម៌អន់ថយ។

-តំណាល : ***រឿងតំណាល***ជារឿងព្រេងបុរាណខ្មែរ។

-ស៊ុបទ្រុប : ***ឈើស៊ុបទ្រុប***ដុះជុំវិញបឹងទន្លេសាប។

-របឹប : ***ទ្រព្យរបឹប***ត្រូវទុកជាសម្បត្តិរដ្ឋ។

២. បង្កើតគុណនាមដែលចេញពី នាម គុណនាម កិរិយាសព្ទឱ្យបាន ៥ល្បះ៖

| នាម | គុណនាម | កិរិយាសព្ទ | គុណនាម |
|---|---|---|---|
| ធម៌ | | | ចិត្តធម៌ |

| | | | |
|---|---|---|---|
| | | តំណាល | រឿងតំណាល |
| | តឿ | | កន្ឿ |
| | ពុក | | កំពុក |
| | ខ្ចិល | | កម្ចិល |
| | ធាត់ | | កន្ធាត់ |

៣. វិធីកកើតនៃគុណនាមដូចជា : កំពុក កំប៉ោង កំពៀច កញ្ចោត កម្ចិលគឺកើតចេញពីគុណនាមទាំងអស់។

| គុណនាម | គុណនាម |
|---|---|
| ពុក | កំពុក |
| ប៉ោង | កំប៉ោង |
| ពៀច | កំពៀច |
| ចោត | កញ្ចោត |
| ខ្ចិល | កម្ចិល |

## អំណាន ការរុករករបស់លោក គ្រីស្តុប កូឡុំ

### សំណួរ

១. តើអត្ថបទខាងលើនិយាយពីអ្វី?

២. តើលោកគ្រីស្តុប កូឡុំមានការយល់ឃើញដូចម្តេចចំពោះលោកយើងនេះ?

៣. តើអ្នកយល់ថា ទស្សនៈរបស់គាត់ត្រឹមត្រូវដែរ ឬទេ?ព្រោះអ្វី?

៤. តើលោកគ្រីស្តុប កូឡុំមានគោលដៅដូចម្តេចចំពោះទស្សនៈរបស់លោក?

៥. ចូរពិនិត្យពាក្យមួយគូខាងក្រោមនេះ។ តើគូពាក្យណាមានន័យដូច គូពាក្យណាមានន័យផ្ទុយ?

- ចេញដំណើរ ត្រឡប់វិញ ។ ខាងលិច ខាងកើត
- មូល សំប៉ែត។ ធនធាន ទ្រព្យសម្បត្តិ។
- ឆ្លូត ជា។ ទំនុកបម្រុង ផ្គត់ផ្គង់។

៦. ចូរពន្យល់ពាក្យ "លោក" ក្នុងល្បះ លោកដែលយើងអាស្រ័យនៅទីនេះ មានសណ្ឋានសំប៉ែត "និងពាក្យ "មិនបានការ" ក្នុងល្បះ "ជនទាំងនោះនាំគ្នានិយាយ តិះដៀល កូឡុំថាជាមនុស្សឆ្កួតជាមនុស្សលីលាមិនបានការ"។

៧. ចូររកពាក្យន័យដូចនឹងពាក្យ លិខិត មើលនិងរកពាក្យន័យផ្ទុយនឹងពាក្យ ដំបូង ធំ សរសើរ ស្រឡាញ់ គោរព។

៨. ចូរបង្កើតគុណនាមដោយប្រើគុណនាម ឆ្កួត។

## ចម្លើយ

១. អត្ថបទខាងលើនិយាយពីទិសរបស់ដៅលោកគ្រីស្តុប កូឡុំ ក្នុងការរុករករបបគំហើញរបស់ផែនដី។

២. លោកគ្រីស្តុប កូឡុំមានការយល់ឃើញថាពិភពលោកដ៏មានវិសាលភាពទូលាយនេះ វាមានសណ្ឋានមូលដោយគាត់គិតថាបើ

ធ្វើដំណើរចេញពីទ្វីបអឺរ៉ុប ដោយបែរមុខឆ្ពោះទៅទិសខាងកើត ពេលត្រឡប់មកកាន់ទីដើមវិញ ពីទិសខាងលិច។ ក្នុងដំណើរដូចគ្នាដែរ បើធ្វើដំណើរឆ្ពោះទៅទិសលិច នៅទីបំផុតក៏មកកាន់ទីដើម ត្រឡប់មកកាន់ទី ពីដើមទិសខាងកើតវិញ។

៣. ទស្សនៈរបស់គាត់ពិតត្រឹមត្រូវ ព្រោះជាធម្មតាវត្ថុដែលមានរាងមូលវាដូចកង់រទេះ វិលទៅវិញទៅមក រកកន្លែងដើមវិញ។ ដូចជាការធ្វើដំណើររបស់លោកគ្រីស្តុប កូឡុំដែរ ដូចជាធ្វើដំណើរចេញទៅទិសកើត នៅពេលមកដល់ទីកន្លែងដើមវិញ គឺគាត់ចេញពីទិសខាងលិចវិញ។

៤. លោកគ្រីស្តុប កូឡុំមានគោលដៅចំពោះទស្សនៈរបស់លោកគឺត្រូវតែធ្វើការរុករកពិភពលោកនេះដើម្បីបញ្ជាក់ពីទ្រឹស្តីរបស់លោក ដែលយល់ថាផែនដីមានរាងមូល ហើយលោកព្យាយាមបានសម្រេចមែនជាពិសេសការរកឃើញទ្វីបអាមេរិច។

៥. គូពាក្យដែល មានន័យដូច គូពាក្យដែលមានន័យផ្ទុយ

**ពាក្យដែលមានន័យដូច**

- ធនធាន ទ្រព្យសម្បត្តិ។
- ទំនុកបម្រុង ផ្គត់ផ្គង់។

**គូពាក្យដែលមានន័យផ្ទុយ**

- ចេញដំណើរ ត្រឡប់វិញ ។
- ខាងលិច ខាងកើត ។

- មូល សំប៉ែត។

- ឆ្លូត ជា។

៦. ពន្យល់ពាក្យ *"លោក"* ក្នុងល្បះ លោកដែលយើងអាស្រ័យនៅទីនេះ មានសណ្ឋានសំប៉ែត។ លោក នៅទីនេះមិនសំដៅទៅលើ "មនុស្ស" ទេ តែគេសំដៅទៅលើ "ផែនដី"។

ពាក្យ *"មិនបានការ"* ក្នុងល្បះ "ជនទាំងនោះនាំគ្នានិយាយតិះដៀល កូទ្បុំថា ជាមនុស្សឆ្លូត ជាមនុស្សលីលាមិនបានការ"។ មិនសំដៅទៅលើមនុស្សដែលមិនបានរៀបអាពាហ៍ពិពាហ៍ទេ តែសំដៅទៅលើ "មនុស្សដែលគ្មានប្រយោជន៍"ទៅវិញ។

៧. *ពាក្យន័យដូចនឹងពាក្យ៖*

លិខិត=សំបុត្រ អក្ខរា ចុហ្មាយ ដីកា...។

មើល=គយគន់ ទស្សនា ទត...។

*រកពាក្យន័យផ្ទុយនឹងពាក្យ*: ដំបូង≠ចុងក្រោយ។ ធំ≠តូច។ សរសើរ≠បង្អាប់។ ស្រឡាញ់≠ស្អប់។ គោរព≠ក្រអើតក្រទម។

៨. បង្កើតគុណនាមដោយប្រើគុណនាម ឆ្លូត

| គុណនាម | គុណនាម |
|---|---|
| ឆ្លូត | ចង្កូត ឆ្កួតចិត្ត ឆ្កួតកាម... |

# អំណាន ទិសដៅនៃជីវិត

## សំណួរ

១. តើអត្ថខាងលើនិយាយពីអ្វី?

២. ចូរបង្ហាញគំនិតសំខាន់នៃអត្ថបទ។

៣. តើជីវិតដែលមានគោលដៅច្បាសលាស់ ជាជីវិតដូចម្ដេច?

៤. តើអ្នកដែលគ្មានគោលដៅច្បាស់លាស់សម្រាប់ជីវិតនឹងជួបផលវិបាកអ្វីខ្លះ?

៥. តើអ្នកត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីសម្រេចគោលដៅនោះ?

៦. តើអត្ថបទមានតម្លៃអប់រំដូចម្ដេច?

៧. តើអ្នកមានគោលដៅដូចម្ដេចខ្លះចំពោះជីវិតសិក្សារបស់អ្នក?

៨. ចូរអ្នកសង្ខេបអត្ថបទឡើងវិញ?

## ចម្លើយ

១. អត្ថខាងលើនិយាយពីផែនការផ្សេងៗដើម្បីកំណត់ពីគោលដៅជីវិតឱ្យបានល្អប្រសើរ។

២.គំនិតសំខាន់នៃអត្ថបទគឺការកំណត់គោលដៅនៃជីវិត។

៣. ជីវិតដែលមានគោលដៅច្បាសលាស់ ជាជីវិតដែលមានផែនការត្រឹមត្រូវដើម្បីជំនះឧបសគ្គ ទទួលយកភាពខ្ពង់ខ្ពស់ជាលំដាប់ មានឋានៈបុណ្យសក្តិ កិត្តិយស កេរ្តិ៍ឈ្មោះនិងប្រយោជន៍ដល់អ្នកដទៃនិងសង្គមជាតិ។

៤. ជីវិតដែលគ្មានគោលដៅច្បាស់លាស់សម្រាប់ជីវិតនឹងជួបផលវិបាកដូចជាតែលតោល ចាប់នេះចាប់នោះមិនឆ្ពោះត្រង់ណា ចុងបញ្ចប់មិនដឹងជាខ្លួនឯងបានធ្វើអ្វី ខ្លួនឯងស្រលាញ់អ្វី ចូលចិត្តអ្វីច្រើនប្រាស់ចាកប្រយោជន៍ ជួនកាលអាចបំផ្លាញខ្លួនឯងនិង អ្នកដទៃ សង្គមជាតិក៏ថាបាន។

៥. ដើម្បីសម្រេចគោលដៅច្បាស់លាស់ យើងត្រូវមានវត្ថុបីជាសំខាន់គឺលទ្ធភាព(លុយ) សមត្ថភាព(ចំណេះដឹង) និងការកំណត់ពេលវេលា(ការកំណត់រយៈពេល)។ មុននឹងអ្នកចង់ធ្វើអ្វីអ្នកត្រូវគិតកត្តាទាំងបីខាងលើនេះ ទើបអ្នកអាចទទួលបានផលសម្រេចដែលកើតចេញពីសេក្តីតស៊ូព្យាមរបស់អ្នកពិតប្រាកដ តែប្រសិនបើអ្នកមានវត្ថុទាំងបីនេះ ហើយការព្យាយាមមិនបកក្រោយហើយខិតខំស្វែងយល់ពីកត្តាផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងគោលដៅយ៉ាងពិតប្រាកដនោះ អ្នកនឹងទទួលបានជោគជ័យហើយ។

៦. អត្ថបទមានតម្លៃអប់រំដូចទៅ ៖

-មនុស្សត្រូវតែមានគោលដៅអ្វីមួយសម្រាប់ជីវិត ហើយត្រូវព្យាយាមធ្វើឱ្យបានសម្រេចនូវគោលដៅជីវិតរបស់ខ្លួនដើម្បីឱ្យជីវិតមានន័យមានទ្រព្យសម្បត្តិមានកេរ្តិ៍ឈ្មោះពីរោះផ្អែមពិសា។

៧. គោលដៅរបស់ខ្ញុំចំពោះជីវិតសិក្សាគឺខ្ញុំត្រូវព្យាយាមរៀនសូត្រឱ្យបានចប់ចុងចប់ដើមនូវសញ្ញាបត្រ បរិញ្ញាប័ត្រ អនុបណ្ឌិត ឱ្យទាល់តែបាន។

៨. សង្ខេបអត្ថបទឡើងវិញ

មនុស្សត្រូវមានទិសដៅឱ្យបានល្អប្រសើរ ដើម្បីទទួលបានជោគជ័យក្នុងជីវិ ហើយត្រូវចេះប្រព្រឹត្តឥរិយាល្អប្រពៃគាប់ភ្នែកពីអ្នកដទៃ។ក្នុងស្ថានការណ៍អ្វីក៏ដោយ មនុស្សតែងតែចង់ឈ្នះឧបសគ្គ ហើយស្រវារកឧត្តមភាពសម្រាប់ខ្លួន ប្រការនេះគឺទាល់តែយើងចេះកំណត់គោលដៅទុកជាមុនដែរ។ ន័យនៃជីវិតមិនមែនជាភាពសម្បូរសប្បាយទេ តែជាខ្លឹមសារដ៏សំខាន់ដែលទទួលបានពីសេក្តីព្យាយាមរបស់ខ្លួនក្នុងឆាកជីវិត។ គោលដៅគឺជាគ្រឿងនាំស្មារតីឱ្យដើរតាមអ្វីដែលយើងបានកំណត់ ហើយប្រព្រឹត្តទៅតាមផែនការស្វែងរកភាពជោគជ័យដល់ដំណាក់ចុងក្រោយទើបជាការប្រសើរ។

# ការស្លាប់ ច្បាប់អរិយសត្វា

## សំណួរ

១. តើអ្នកនិពន្ធតែងអត្ថបទកំណាព្យនេះ ជាបទអ្វី?

២. ចូរបង្ហាញគំនិតសំខាន់របស់កំណាព្យ។

៣. តើកំណាព្យមានតម្លៃអប់រំដូចម្ដេចខ្លះ?

៤. ចូរសង្ខេបគំនិតសំខាន់របស់កំណាព្យ។

# ការនិយាយ ការសូត្រកំណាព្យ

## សំណួរ

១. តើបទពំនោលមានកំណើតពីពេលណា?

២. តើបទពំនោលមានរង្វាស់កាព្យដូចម្តេច? ចំណាប់ចួនដូចម្តេច?

៣. តើគេសូត្រ ឬប្រើបទពំនោលសម្រាប់រៀបរាប់ពីអ្វីខ្លះ?

## ចម្លើយ

១. បទពំនោលមានកំណើតពីសម័យអង្គរ។

**២.ក. បទពំនោលមានរង្វាស់កាព្យ**

ក្នុងមួយវគ្គមានបីឃ្លា។

-ឃ្លាទី១ មាន៦ ព្យាង្គ។ឃ្លាទី២ មាន៤ ព្យាង្គ។ឃ្លាទី៣ មាន៦ ព្យាង្គ។

**ខ. ចំណាប់ចួន**

គំនូសតាងចំណាប់ចួន

១២៣៤៥៦ ១២៣៤ ១២៣៤៥៦។

១២៣៤៥៦ ១២៣៤ ១២៣៤៥៦។

*ឧទាហរណ៍:*

ពុំឆ្អែតពុំឆ្អន់នេត្រា ត្រេកសោមនស្សា ពុំស្កប់ពុំស្កល់ចិត្តឡើយ។

ចរចូលមៀងមើលរួចហើយ ពុំចង់ចេញឡើយ អាឡោះអាល័យពេកណា។

**ចួនក្នុងវគ្គ** : ព្យាង្គទី ៦ នៃឃ្លាទី ១ ចួននឹងព្យាង្គទី៤ នៃឃ្លាទី២។
**ចួនក្នុងវគ្គ** : ព្យាង្គទី ៦ នៃឃ្លាទី ៣នៃវគ្គទី១ ចួននឹងព្យាង្គទី៦ នៃឃ្លាទី១ ក្នុងវគ្គទី។

៣. គេសូត្រ ឬប្រើបទពំនោលសម្រាប់រៀបរាប់ពី *ភាពព្រួយ ក្រោធ* សង្ឃសន្ទាប់ គម្រាមគំហែង រៀបរាប់ពីមហិទ្ធិរិទ្ធរបស់អ្នកមានអំណាចខ្លាំង ឬពាក្យអង្វរករ ការភ័យក្លាយរបស់អ្នកទន់ខ្សោយ ជួនកាលរៀបរាប់ពីជំលោះចម្បាំង។ ពេលខ្លះគេយកទៅសូត្រក្នុងការសម្ដែងរបាំឱ្យសិល្បៈករធ្វើកាយវិការតាមទៀតផង។

# សំណេរ តែងកាព្យបទពំនោល

## លំហាត់

ចូរប្អូនតែងកំណាព្យបទពំនោលឱ្យបានយ៉ាងតិចចំនួន ៥វគ្គ ដែលមានខ្លឹមសារទាក់ទងនឹងប្រធានបទ "ការកំណត់គោលដៅក្នុងការសិក្សា"។

## ចម្លើយ(ការកំណត់គោលដៅក្នុងការសិក្សា)

ស្រស់ស្រាយសប្បាយសិក្សា ខ្ញុំសិស្សសាលា កំណត់ពីគោលដៅច្បាស់។
រាល់ថ្ងៃខិតខំរៀនណាស់ មិនដែលក្រឡាស់ រៀចវេរគេចពីសាលា។
ថ្ងៃក្រោយខ្ញុំចង់ធ្វើការ បុគ្គលិកអង្គការ អភិវឌ្ឍន៍ដល់ស្រុកស្រែ។
មិនយូរមិនច្រើនថ្ងៃខែ ចិត្តជាកូនខ្មែរ សំភីសម្រេចប្រាថ្នា។
បីប្អូមបាក់ឧបបរិញ្ញា បញ្ចប់កាលណា ការងារជូនម្ដាយ។

# មេរៀនទី៦ ស្មារតីទទួលខុសត្រូវ

## បំណិន លក្ខណៈសម្គាល់រឿងល្ខោន

### សំណួរ

១. តើអត្ថបទដកស្រង់រឿងតេជោយ៉តឆាកទី១ នេះនិយាយពីអ្វី?

២. តើអត្ថបទល្ខោនដកស្រង់រឿងចៅកែចិត្តចោរឆាកទី១ នេះនិយាយពីអ្វី?

៣. តើអត្ថបទល្ខោនដកស្រង់ខាងលើនេះមានតួអង្គណាខ្លះ?

៤. តើតួអង្គនីមួយៗមានឋានៈនិងតួនាទីអ្វីខ្លះក្នុងរឿង?

៥. តើគេអាចដឹងលក្ខណៈសម្គាល់រឿងល្ខោនតាមលក្ខណៈអ្វីខ្លះ?

### ចម្លើយ

១. អត្ថបទដកស្រង់រឿងតេជោយ៉តឆាកទី១ នេះនិយាយពី "*ការចេញដំណើររបស់តេជោយ៉ត និងតេជោមានទៅធ្វើសង្គ្រាមកំចាត់សត្រូវ*"។

២. អត្ថបទល្ខោនដកស្រង់រឿងចៅកែចិត្តចោរឆាកទី១ នេះនិយាយពី "*ការស្វែងរក និងការរងចាំរបស់ពូហាំដើម្បីជួបលោកចៅកែ*"។

៣. អត្ថបទល្ខោនដកស្រង់ខាងលើនេះមានតួអង្គ៖

**រឿងតេជោយ៉ត** ៖ តេជោយ៉ត តេជោមាស និងជំទាវស្រែន។

**រឿងចៅកែចិត្តចោរ** : មានតួអង្គផានិត និងហំ។

៤. តួអង្គនីមួយៗមានឋានៈនិងតួនាទីក្នុងរឿង៖

**+រឿងតេជោយ៉ត :**

-***តេជោមាស*** : ជាគ្រូរបស់តេជោយ៉ត ហើយជាប្តីរបស់ជំទាវស្រែន។ ជាឧកញ្ញាតេជោបរមរាជត្រួតខេត្តកំពង់ស្វាយ។

-***យ៉ត*** : ជាសិស្សរបស់តេជោមាស មានងារជាតេជោត្រួតខេត្តកំពង់ស្វាយ បន្ទាប់ពីតេជោមាសស្លាប់ទៅ។

-***ជំទាវស្រែន*** : ជាភរិយាតេជោមាសមានល្បិចអាចសម្លាប់ស្តេចសំរែ។ ជាប្រពន្ធរបស់តេជោយ៉ត បន្ទាប់ពីតេជោមាសស្លាប់។

**+រឿងចៅកែចិត្តចោរ**

-***ពូហំ*** : ជាប្តីនាងយ៉ាន និងមានតួនាទីជាអ្នកបើកឡានឱ្យចៅកែ

-***ផានិត*** : ជាសិស្សសាលា ជាអ្នកកាន់កាប់បញ្ជីក្នុងហាងឡាន។

៥. គេអាចដឹងលក្ខណៈសម្គាល់រឿងល្ខោនតាមលក្ខណៈដូចជា៖

-ចែកចេញជាឈុត និងឆាកដើម្បីសម្តែង

-មានបញ្ជីរាយនាមតួអង្គនៅខាងឆ្វេងនិងឋានៈឬប្រភពកំណើតតួអង្គ។

-សរសេរជាកាព្យ ឬពាក្យរាយនិងពាក្យពោល ឬការសន្ទនារបស់តួអង្គ។

# មេរៀន  វិធីបង្ហាញតួអង្គក្នុងរឿងល្ខោន

## សំណួរ

១. តើវិធីបង្ហាញតួអង្គក្នុងរឿងល្ខោនមានប៉ុន្មានបែប?ចូររៀបរាប់។

២. ចូរអានអត្ថបទល្ខោនខាងក្រោម រួចបញ្ជាក់ពីវិធីបង្ហាញតួអង្គនីមួយៗឱ្យបានត្រឹមត្រូវ។

## ចម្លើយ

១. វិធីបង្ហាញតួអង្គក្នុងរឿងល្ខោនមាន៤បែប។

-**បង្ហាញដោយអ្នកនិពន្ធ** : សរសេររាយនាមតួអង្គ មុខងារ ប្រភពកំណើតតួអង្គនីមួយៗនៅខាងដើមអត្ថបទ ក្នុងការសម្ដែងវិញ វិធីបង្ហាញតួអង្គដោយការប្រកាសឈ្មោះតួអង្គ នៅក្នុងរឿងនិងឈ្មោះតួសម្ដែងតំណាងនៅពេលចាប់សម្ដែងល្ខោន។

- **បង្ហាញតួអង្គដោយតួអង្គខ្លួនឯង** : តួអង្គរៀបរាប់ឈ្មោះដោយខ្លួនឯង។

-**វិធីបង្ហាញតួអង្គដោយតួអង្គដទៃ** : តួអង្គមួយជាអ្នកនិយាយបង្ហាញឈ្មោះតួអង្គផ្សេងទៀត។

-**ការបង្ហាញតួអង្គដោយដំណើររឿង ឬសកម្មភាពតួអង្គ** : ចេញមកដោយគ្មាននរណាហៅ។

២. បង្ហាញតួអង្គនីមួយៗមាន៖

-ការបង្ហាញតួអង្គដោយតួអង្គដទៃទៀត *ឧទាហរណ៍ :*

**និម្មិត** : បងសម្បត្តិ...បងរក្សា បងឈប់រក្សាសម្បត្តិ គិតរត់ឱ្យបាត់ចោលសម្បត្តិឈប់រក្សាសម្បត្តិទៀតហើយ។

-ការបង្ហាញតួអង្គដោយដំណើររឿង *ឧទាហរណ៍ :*

**សម្បត្តិ** : ស្អីទៀតហើយ ...រឿងវាយ៉ាងម៉េច?

**និម្មិត** : បងសម្បត្តិ...បងរក្សា បងឈប់រក្សាសម្បត្តិ គិតរត់ឱ្យបាត់ចោលសម្បត្តិឈប់រក្សាសម្បត្តិទៀតហើយ។(តួអង្គនិម្មិតចេញមកដោយគ្មាននរណាហៅ)។

# អំណាន កំហុសអ្នកណា

## សំណួរ

១. តើអត្ថបទនេះជាប្រភេទអត្ថបទអ្វី? ចូរបង្ហាញ។

២. ចូរប្រាប់ពីវិធីបង្ហាញតួអង្គនៅក្នុងអត្ថបទខាងលើនេះ។

៣. តើអត្ថបទខាងលើមានតួអង្គឈ្មោះអ្វីខ្លះ?

៤. ចូរបង្ហាញពីបុគ្គលិកលក្ខណៈរបស់តួអង្គព្រះសង្ឃឡូរិន។

៥. តើនរណាខ្លះទទួលខុសត្រូវចំពោះមរណភាពរបស់រ៉ូមេអូនិងស៊ុលីយែត?

៦. តើអត្ថបទដកស្រង់ខាងលើមានតម្លៃអប់រំដូចម្ដេចខ្លះ?

៧. ចូរនិយាយពី លក្ខណៈល្ខោននិយាយ។

## ចម្លើយ

១. អត្ថបទនេះជាប្រភេទអត្ថបទល្ខោន។

-មានរាំយឈ្មោះតួអង្គនៅខាងឆ្វេង

-តួអង្គសន្ទនាពីដើមដល់ចប់

-មានការបញ្ជាក់របស់អ្នកនិពន្ធ(ទាហាននាំព្រះសង្ឃឡូរិនចូលមក)។

-អាចចែកជាឆាក ឬជាឈុត។

២. វិធីបង្ហាញតួអង្គគឺ៖

-ការបង្ហាញតួអង្គដោយតួអង្គដទៃទៀត : *ឧទាហរណ៍*

**ព្រះអង្គម្ចាស់** :ម្ដេចក៏មានសម្រែកស្រែកហៅរន្ទឺពាសពេញដូច្នេះ?

**ជំទាវកាប់ពុយឡែត** : ពលរដ្ឋតាមផ្លូវស្រែកថា រ៉ូមេអូស៊ុលីយ៉ែត ប៉ារីស៍ហើយអ្នកទាំងអស់គ្នាស្លាំងស្លេករត់សំដៅចេតិយនេះ។

-ការបង្ហាញតួអង្គដោយដំណើររឿង៖

**ទាហានទី១** : ជាភស្តុតាងដ៏ធ្ងន់ធ្ងរតោងឃាតលោកសង្ឃនេះទុកដែរ។

**ព្រះអង្គម្ចាស់** :ម្ដេចក៏មានសម្រែកស្រែកហៅរន្ទឺពាសពេញដូច្នេះ? (ព្រះអង្គម្ចាស់ចេញមកដោយគ្មាននរណាហៅ)។

៣. អត្ថបទខាងលើមានតួអង្គឈ្មោះ *រ៉ូមេអូ ស៊ូលីយ៉េត ព្រះអង្គម្ចាស់ ជំទាវកាប់ពុយឡែត ម៉ុងតេហ្គុយ ឡូរិន បាល់ថេហ្សារ (ក្រុមទាហានទី១ ដល់ទី៣ ជាវ)។*

៤. បង្ហាញពីបុគ្គលិកលក្ខណៈ របស់តួអង្គព្រះសង្ឃឡូរិនមានដូចជា៖

**គុណសម្បត្តិ**

-ជាសង្ឃដ៏ល្អ ប្រកបទៅដោយធម៌មានសមត្ថភាពក្នុងការផលិតថ្នាំពិសេស។

- ជួយដោះទុក្ខរឿងស្នេហារ៉ូមេអូស៊ូលីយ៉េត

-ពេលដឹងថាការផ្ញើសំបុត្រមិនបានផលព្រះ អង្គមកជួយស៊ូលីយ៉េតដោយផ្ទាល់នៅកន្លែងកប់ខ្មោច

-ជាមនុស្សស្មោះត្រង់ សារភាពតែការពិតចំពោះព្រះអង្គម្ចាស់

**គុណវិបត្តិ**

-ជាអ្នករួមចំណែកក្នុងការធ្វើឱ្យស្លាប់ជីវិតមនុស្សដល់ទៅបីនាក់

-រៀបការឱ្យរ៉ូមេអូ និងសូលីយ៉េតដោយចិត្តឯងមិនប្រាប់ដល់អាណាព្យាបាលរបស់ពួតគេឱ្យដឹង។

៥. អ្នកដែលទទួលខុសត្រូវចំពោះមរណភាពរបស់រ៉ូមេអូនិងស៊ូលីយ៉េតគឺមេគ្រួសារទាំងពីរ ព្រោះគ្រួសារទាំងពីរនេះមានទំនាស់ចងគំនុំជាមួយគ្នាជាយូរមកហើយ ប្រការនេះបានរារាំងដល់រឿងស្នេហាស្មោះស្ម័គ្ររបស់ពួកគេមិនហ៊ានប្រឈមមុខជាមួយ

ឪពុកម្ដាយ កាលណាបើមានរឿងបែកបាក់ស្នេហាពួកគេទាំងពីរមានតែជ្រើសរើសផ្លូវស្លាប់ ដើម្បីរំលត់គំនុំគ្រួសារទាំងនេះ។

៦. អត្ថបទដកស្រង់ខាងលើមានតម្លៃអប់រំមានដូចជា៖

-គំនុំ ខឹងខុស ខឹងខាត ខឹងគឺជាភ្លើងដុតកំលោចទាំងខ្លួនឯងទាំងអ្នកដទៃ

-ការស្លាប់មិនមែនជាមធ្យោបាយដ៏ល្អប្រសើរ ក្នុងការដោះស្រាយបញ្ហានោះទេ។

-មនុស្សត្រូវដឹងកំហុសរបស់ខ្លួនផ្សះផ្សារស្វែងរកសន្តិភាពដើម្បីស្វែងរកសេចក្ដីសុខ

-ស្នេហាត្រូវតែមានឆាកបី ឆាកខាងប្រុស ឆាកខាងស្រី និងឆាកខាងឪពុកម្ដាយបើពុំនោះទេស្នេហាច្បាស់ជាជួបវិបត្តិសុភមង្គលជាមិនខាន។

៧. លក្ខណៈល្ខោននិយាយមាន៖

-មានឆាកមានឈុតជាផ្នែកៗដើម្បីសម្ដែង

-មានរាយឈ្មោះតួអង្គនៅខាងឆ្វេង

-មានការសន្ទនាតួអង្គតាំងពីដើមរហូតដល់ចប់

-ជាល្ខោនមួយដែលគេយកតែសម្ដែងគ្មានផ្ទាំងទស្សនីយភាព។

# វេយ្យាករណ៍ ពាក្យបន្ថែមដើមនិងបន្ថែមចុង

## លំហាត់

**ក. ចូរស្រង់ពាក្យបន្ថែមដើម និងពាក្យបន្ថែមចុង ដាក់ក្នុងតារាងខាងក្រោមឱ្យបានត្រឹមត្រូវ។**

អ្នកចម្រៀង សេចក្តីចម្រើន អ្នកចម្បាំង ភាពរីករាយ ការការពារ ដំណាំ សេចក្តីថ្លៃថ្នូរ អ្នកនេសាទ លំបាក ភារកិច្ច ប្រជាជន ជនជាតិ ភាសាវិទូ អាកាសយានិក កម្មការិនី និយោជិត ទឹកជំនន់ ពលកម្ម ទោសភាព កម្មករ ការអនុវត្ត អក្សរសិល្ប៍ សុភាវធម៌ ប្រទាញ ភាពជរា កិច្ចការ ពិធីការ។

| ពាក្យបន្ថែមដើម | ពាក្យន្ថែមចុង |
|---|---|
| អ្នកចម្រៀង...... | ភារកិច្ច......... |

**ខ. ចូររកពាក្យបន្ថែមដើមឱ្យបាន ២០និងពាក្យបន្ថែមចុងឱ្យបាន ២០។**

## ចម្លើយ

ក. ស្រង់ពាក្យបន្ថែមដើមនិងពាក្យបន្ថែមចុង

| ពាក្យបន្ថែមដើម | ពាក្យបន្ថែមចុង |
|---|---|
| អ្នកចម្រៀង សេចក្តីចម្រើន<br>អ្នកចម្បាំង ភាពរីករាយ | ភារកិច្ច ប្រជាជន ភាសាវិទូ<br>អាកាសយានិក |

| | |
|---|---|
| ការការពារ សេចក្តីថ្លៃថ្នូរ<br>អ្នកនេសាទ ការលំបាក<br>ការអនុវត្ត ភាពជរា | កម្មការិនី និយោជិត ពលកម្ម<br>ទេសភាព កម្មករ សុជីវធម៌<br>កិច្ចការ ពិធីការ |

**ខ. រកពាក្យបន្ថែមដើមឱ្យបាន២០និងពាក្យបន្ថែមចុងឱ្យបាន២០**

**-ពាក្យបន្ថែមដើមមាន :** អ្នកស្រែ អ្នកក្រុង អ្នកភូមិ អ្នកនេសាទ អ្នកជំនួញ អ្នកជក់ អ្នកលេង អ្នកចម្ការ ជនពិការ ជនអាណាថា ជនទុច្ចរិត ការអភិវឌ្ឍ ការការពារ ការអនុវត្ត ភាពក្រីក្រ ភាពជាអ្នកដឹកនាំ ភាពសុខសាន្ត ភាពកំសត់ សេក្តីថ្លៃថ្នូរ សេចក្តីលំបាក...។

**-ពាក្យបន្ថែមចុងមាន** : កសិកម្ម ចោរកម្ម ឃាតកម្ម ពលកម្ម ពលករ ឃាតករ កម្មករ កសិករ វាទ់ករ សិប្បករ អភិបាលកិច្ច សង្គមកិច្ច សេដ្ឋកិច្ច សមភាព ទេសភាព សកម្មភាព សមធម៌ សីលធម៌ សុជីវធម៌ ចារបុរស វីរបុរស ប្រជាជន សកម្មជន ភាសាវិទូ ។

## អំណាន ល្ខោនខ្មែរ
## ការស្តាប់ «រឿងតេជោយ៉ត

### សំណួរ

១. តើអត្ថបទនេះជាប្រភេទអត្ថបទអ្វី? ចូរពន្យល់។

២. តើរឿងនេះមានប៉ុន្មានឆាក? តើគេបែងចែកឆាកនីមួយៗយ៉ាងដូចម្តេច?

៣. ចូរបកស្រាយពីវិធីបង្ហាញតួអង្គក្នុងរឿង ដោយលើកអំណះអំណាងមកបញ្ជាក់។

៤. តើរឿងនេះមានតួអង្គប៉ុន្មាន? តើតួអង្គនីមួយៗ ធ្វើសកម្មភាពអ្វីខ្លះ?

៥. ចូរបង្ហាញបុគ្គលិកលក្ខណៈរបស់តួអង្គ តេរជាមាស តេជោយ៉ត ជំទាវស្រែន និងស្តេចសំរែ។

៦. តើរឿងនេះបង្កប់គំនិតសំខាន់ៗអ្វីខ្លះ?

## ការនិយាយ ការសម្តែងតួតាមអត្ថបទល្ខោន

### សំណួរ

១. តើគេអាចរៀបចំរឿងល្ខោនជាប៉ុន្មានបែប? ចូរប្រាប់ពីរបៀបសម្តែងតួតាមបែបនីមួយៗផង។

២. តើគេជ្រើសរើសតួអង្គបែបណាសម្រាប់សម្តែងលើឆាក?

៣. ពេលសម្តែងនៅលើឆាកឬតាមវិទ្យុ តើតួអង្គនីមួយៗត្រូវទទួលខុសត្រូវលើចំណុចអ្វីខ្លះ?

### ចម្លើយ

១. គេអាចរៀបចំរឿងល្ខោនជាបីបែប៖

ក.ការរៀបចំមុនសម្តែង :

-ជ្រើសរើសតួអង្គឱ្យសមទៅតាមឥរិយាបថសកម្មភាពដំណើររឿងប្រាប់ពី របៀបសម្ដែងតួតាមបែបនីមួយៗ

-រូបរាងកាយនិងសម្លេងរបស់តួអង្គ

-ការប្រមូលអារម្មណ៍លើសាច់រឿង

-របៀបសម្ដែងរបស់តួអង្គ

-ចលនានិងកាយវិការផ្សេងៗ ដែលត្រូវធ្វើនៅពេលសម្ដែង

**ខ.ការរៀបចំតុបតែងតួសម្ដែង(សម្ដែងលើឆាក)**

-រៀបចំសម្លៀកបំពាក់ឱ្យត្រូវតាមសម័យកាល

-ផាត់មុខ ជាក្មេង ចាស់ យក្ស អាក្រក់ ស្អាត ស្គមជ្រីញជ្រួញ ពាក់ពុកមាត់ ពុកចង្ការ...។

**គ.ការសម្ដែង**

-សម្ដែងសាកល្បង ដោយយកឯកសារកត់ត្រាសំដីតួនីមួយៗមកអាន

-សម្ដែងតួដោយប្រើសំដីផ្ទាល់ខ្លួន ទៅតាមដំណើររឿងដោយមិនប្រើឯកសារកត់ត្រាឡើយហើយនៅពេលសម្ដែងតួទាំងអស់ត្រូវ

+ចងចាំបទសន្ទនា ឬសំដីតួអង្គដែលអ្នកដើរតួ

+ដាក់អារម្មណ៍ទៅតាមស្ថានភាពតួអង្គនៅក្នុងរឿង

+ប្រើពាក្យពេចន៍ កាយវិការ ចរិតលក្ខណៈឱ្យសមតាមតួអង្គនីមួយៗក្នុងដំណើររឿង

+ប្រមាណពេលវេលាសម្ដែងឱ្យបានសមស្រប

-មិនគួរបញ្ចេញពាក្យពេចន៍ ឱ្យហួសពីសាច់រឿងខ្លាំងពេកឬប្រើពាក្យអសីលធម៌ឡើយ។

២. គេជ្រើសរើសតួអង្គសម្រាប់សម្ដែងលើឆាក តួអង្គត្រូវ៖

-រៀបចំសម្លៀកបំពាក់ឱ្យត្រូវដំណើររឿងសម័យកាល

-ជាត់មុខ ជាក្មេង ចាស់ យក្ស អាក្រក់ ស្អាត ស្ដមជ្រីញជ្រួញ ពាក់ពុកមាត់ ពុកចង្ការ...

៣. ពេលសម្ដែងនៅលើឆាកឬតាមវិទ្យុ តួអង្គនីមួយៗត្រូវទទួលខុសត្រូវលើចំណុចដូចជា៖

-សម្ដែងសាកល្បងដោយយកឯកសារកត់ត្រាសំដីតួនីមួយៗមកអាន

-សម្ដែងតួដោយប្រើសំដីផ្ទាល់ខ្លួនទៅតាមដំណើររឿង ដោយមិនប្រើឯកសារកត់ត្រាឡើយហើយនៅពេលសម្ដែងតួទាំងអស់ត្រូវ

+ចងចាំបទសន្ទនា ឬសំដីតួអង្គដែលអ្នកដើរតួ

+ដាក់អារម្មណ៍ទៅតាមស្ថានភាពតួអង្គនៅក្នុងរឿង

+ប្រើពាក្យពេចន៍ កាយវិការ ចរិតលក្ខណៈឱ្យសមតាមតួអង្គនីមួយៗក្នុងដំណើររឿង

+ប្រមាណពេលវេលាសម្ដែងឱ្យបានសមស្រប

-មិនគួរបញ្ចេញពាក្យពេចន៍ឱ្យហួសពីសាច់រឿងខ្លាំងពេកឬប្រើពាក្យអសីលធម៌ឡើយ។

# សំណេរ ការតែងរឿងល្ខោន

## សំណួរ

១. តើនរណាជាតួអង្គឯក? តួអង្គរង?
២. តើរឿងខ្លីនេះជាប្រភេទល្ខោនបែបណា?
៣. ចូរប្រាប់វិធីតែងរឿងខាងលើដោយលើកយកឧទាហរណ៍មកបញ្ជាក់ផង។
៤. តើរឿងនេះបានបញ្ចប់ដោយវិធីណា?
៥. តើរឿងនេះបានអប់រំដូចម្ដេចខ្លះ?

## ចម្លើយ

១. អ្នកដែលជាតួអង្គឯកគឺសុថា។ តួអង្គរងគឺម្ដាយសុថា រ៉ាវី និងបូណា។
២. រឿងខ្លីនេះជាប្រភេទល្ខោននិយាយ។
៣.ប្រាប់វិធីតែងរឿងខាងលើដោយលើមានដូចជា៖
-ចែកចេញជាឈុត(មានឈុតទី១ ឈុតទី២)
-រាយឈ្មោះតួអង្គនៅខាងឆ្វេង។
សុថា : ម្ដាយសុថា...
-មានការបញ្ជាក់របស់អ្នកនិពន្ធ (ដើរទៅងូតទឹក)។
-មានតែការសន្ទនារបស់តួអង្គពីដើមរហូតដល់ចប់។
ឧទាហរណ៍ ៖

សុថា : ទេមិនមែនខ្ញុំទេអារី! អារីទេ។

អារី : ឯងជាអ្នកគប់ត្រូវបងធី ។ ម៉េចមកចោទយើងវិញ។

៤. រឿងនេះបានបញ្ចប់ ដោយមានម្ដាយចូលធ្វើអន្តរាគមន៍ជួយដោះស្រាយដោយឱ្យសុថាទៅសារភាពពីកំហុសខ្លួន ហើយសុំទោស។

៥. រឿងនេះបានអប់រំមនុស្សឱ្យចេះភ្ញាក់រឭកដឹងកំហុស ទទួលកំហុស សារភាពហើយចេះសុំទោស។

### លំហាត់

ចូរជ្រើសរើសប្រធានបទមួយក្នុងចំណោមប្រធានរឿងខាងក្រោមមកតាក់តែងរឿងល្ខោនខ្លីតាមទម្រង់ខាងលើដែលទាក់ទងទៅនឹងការបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ ប្រឆាំងការប្រើប្រាស់ជួញដូរគ្រឿងញៀន ទប់ស្កាត់ការជួញដូរផ្លូវភេទ កសិករភ្ញាក់រឭក សិស្សពូកែ។

# មេរៀនទី៧ ការជឿជាក់

## វេយ្យាករណ៍ អំពីពាក្យក្លាយ

### សំណួរ

១. តើពាក្យក្លាយខុសពីពាក្យ ឫសត្រង់ណា?

២. តើថ្នាក់ពាក្យក្លាយទាំងពីរប្រភេទមានអ្វីខ្លះ? ចូររៀបរាប់។

### ចម្លើយ

១. ពាក្យក្លាយខុសពីពាក្យ ឫសត្រង់៖

-ផ្នែករូបសព្ទ(របៀបសរសេរ):ដើរ(ដ+ េី+រ)>ថ្មើរ (ថ+្ម+ េី+រ)

-ផ្នែកថ្នាក់ពាក្យ : ដើរ(កិ.) >ថ្មើរ(ន.)

-ផ្នែកអត្ថន័យ : *ដើរ*មានន័យថាប៉ាកជំហានឈានទៅមុខ។ *ថ្មើរ* មានន័យថា *អ្នកដើរ*។

-ផ្នែកសម្ព័ន្ធ ខ្ញុំ*ដើរ*ទៅផ្សារ។ *ថ្មើរ*ព្រដើរទៅផ្សារ។

២. ថ្នាក់ពាក្យក្លាយទាំងពីរប្រភេទមានកម្លាយដោយផ្នត់ដែកនិងកម្លាយដោយផ្នត់ដើម។ ថ្នាក់ពាក្យក្លាយមាន៖

-ថ្នាក់ពាក្យក្លាយជានាម

-ថ្នាក់ពាក្យក្លាយជាកិរិយាសព្ទ

-ថ្នាក់ពាក្យក្លាយជាគុណនាម

-ថ្នាក់ពាក្យក្លាយជាគុណកិរិយា។

## លំហាត់

១. ចូររកពាក្យក្លាយក្នុងចំណោមពាក្យមួយចំនួនខាងក្រោម៖

- ល្ងូន មេឃ ដី ប្រដឹក ដើរ ឆ្នាំ ឆ្មាត ដុំ ផ្តេក ចចឹក។

២. ចូរចែកពាក្យក្លាយ ដើម្បីរកពាក្យឫស និងផ្នត់នៃពាក្យខាងក្រោមដោយដាក់តាមប្រភេទ៖

- ខ្មើយ គម្រប សន្សើម ច្បង ជម្រើស កង្វល់ ល្បាក់កំបាក់ កញ្ជែរ។

៣. ចូររកពាក្យក្លាយពីពាក្យឫស "កើត" ដោយប្រាប់ផ្នត់ ពាក្យក្លាយ ទម្រង់ ថ្នាក់ពាក្យ និងន័យរបស់ពាក្យក្លាយនីមួយៗ។

៤. ចូរជ្រើសរើសពាក្យក្លាយដែលមាននៅក្នុងអត្ថបទខាងក្រោម៖

បើយើងបានដាំដើមឈើមួយដើមមុនពេលអនិច្ចកម្ម ទង្វើបែបនេះពិតជាពុំឥតប្រយោជន៍ឡើយ ព្រោះយើងបានបន្សល់ឈើមួយដើមដល់មនុស្សជាតិ។ ដើមឈើនោះនឹងផ្តល់ផ្លែផ្កា ឬយ៉ាងហោចណាស់ក៏បានជាម្លប់ត្រជាក់ត្រជុំ សម្រាប់មនុស្សជំនាន់ក្រោយដែរ។ រុក្ខជាតិមួយដើម ឧបករណ៍មួយ សៀវភៅមួយ បដិមាមួយ ផ្ទាំងគំនូរវិចិត្រមួយ តក្កកម្មវិទ្យាសាស្ត្រមួយ សុទ្ធតែជារបស់យើងម្នាក់ៗ ដែលយើងអាចមានលទ្ធភាពបង្កើតបានដើម្បីបញ្ចូលជាសម្បត្តិរួមរបស់មនុស្សជាតិ។

ដូច្នេះ យើងម្នាក់គប្បីខំប្រឹងឱ្យអស់សមត្ថភាពដើម្បីឱ្យកូនចៅជំនាន់ក្រោយរបស់យើងបាន ទទួលសេចក្ដីសុខក្សេមក្សាន្តជាងយើងសព្វថ្ងៃ។

## ចម្លើយ

១. ពាក្យក្លាយក្នុងចំណោមពាក្យមួយចំនួនខាងក្រោម៖

- លួន ប្រដឹក ឆ្នាំ ផ្ដេក ចចឹក។

២. ចែកពាក្យក្លាយ ដើម្បីរកពាក្យឫស និងផ្នត់នៃពាក្យខាងក្រោមដោយដាក់តាមប្រភេទ៖

+ពាក្យក្លាយជានាម

ផ្នត់ដែក[-ន-] [-អំម/ម-]សម្គាល់គ្រឿងឧបករណ៍

- កើយ>ខ្នើយ -គ្រប>គម្រប

ផ្នត់ដើម [សន់-]សម្គាល់

-សើម >សន្សើម

ផ្នត់ដែក[-ម-][-អង់-] សម្គាល់ភាពធ្វើឱ្យ។

-ជ្រើស>ជម្រើស -ខ្វល់>កង្វល់

ផ្នត់ដើម[ល-] សម្គាល់វត្ថុ

-បាក់>ល្បាក់

+ពាក្យក្លាយជាគុណនាម

ផ្នត់ដើម [ច-]

-បង>ច្បង

ផ្នត់ដើម[កំ-][កញ់-]សម្គាល់ភាពបង្អាប់

-បាក់>កំបាក់ -ឆែវ>កញ្ឆែវ

៣. ពាក្យក្លាយពីពាក្យឫស "កើត" ដោយប្រាប់ផ្នត់ ពាក្យក្លាយ ទម្រង់ ថ្នាក់ពាក្យ និងន័យរបស់ពាក្យក្លាយនីមួយៗ៖

កើត > បង្កើត ថ្នាក់ជា (កិ.) ផ្នត់ដើមទម្រង់"ពសព-" ន័យធ្វើឱ្យកើតឡើង។

កើត > កំណើត ថ្នាក់ជា (ន.) ផ្នត់ដែក[-អំម/ណ-]ទម្រង់ "-ពស/ព-"ន័យជាតិ ដំណើរដែលកើត ការចាប់កើតឡើង, កើតជាប្រយោជន៍។

កើត > ខ្នើត ថ្នាក់ជា(ន.) ផ្នត់ដែក[-ន-] ទម្រង់ "-ព-" ន័យ : ភាពចាំងចែងពន្លឺ។

កើត > ខ្មើត ថ្នាក់ជា(ន.) ផ្នត់ដែក [-ម-] ទម្រង់ "-ព-" ន័យ : អ្នកកើត។

៤. ជ្រើសរើសពាក្យក្លាយដែលមាននៅក្នុងអត្ថបទខាងក្រោម :

*ទង្វើ បន្សល់ ផ្តល់ ម្លប់ សម្រាប់ បង្កើត បញ្ចូល។*

## សំណាក     អត្ថបទឃោសនា

### សំណួរ

១. តើអ្វីទៅហៅថាការឃោសនា?

២. ចូររកសំនួនពាក្យដែលបញ្ជាក់ពីការបញ្ចើចបញ្ចើឱ្យបានពីឃ្លា និងការពិតឱ្យបានពីឃ្លាសម្រាប់ការឃោសនា។

៣. តើការឃោសនាមានសារសំខាន់ដូចម្ដេចខ្លះ? បើអ្នកជាពាណិជ្ជករធំ តើអ្នកប្រើការឃោសនាដែរឬទេ? ព្រោះអ្វី?

៤. តើអត្ថបទព័ត៌មានខុសពីអត្ថបទឃោសនាត្រង់ចំណុចណា?

៥. តើយើងអាចដឹងទេថា ការឃោសនាបែបណាដែលល្អ ការឃោសនាបែបណាដែលមិនល្អ?

៦. តើអត្ថបទឃោសនាខាងលើមានតម្លៃអប់រំដូចម្ដេចខ្លះ?

### ចម្លើយ

១. ការឃោសនាគឺជាការប្រកាសផ្សាយដំណឹង ឱ្យសាធារណជនដឹងឮសព្វសាយពីកម្មវត្ថុណាមួយ។

២. សំនួនពាក្យដែលបញ្ជាក់ពីការបញ្ចើចបញ្ចើរមាន : *អញ្ជើញជាវចុះមិនខុសបំណងឡើយ។ ដាក់បច្ច័យច្រើនបានបុណ្យច្រើន។*

សំនួនពាក្យដែលបញ្ជាក់ពីការពិតមាន : *ទិញមួយថែមមួយ។ ស្មោះត្រង់មួយទល់នឹងមួយមិនព្រួយខ្លាយឆ្លងជំងឺអេដស៍។*

៣. ការឃោសនាមានសារសំខាន់ដូចជា៖

-បង្ហាញពីព័ត៌មានផ្សេងៗ ពីវត្ថុដែលយើងចង់ប្រាប់ពីអ្នកដទៃឱ្យបានដឹង។

-អាចទាក់ទាញអតិថិជនអ្នកទស្សនាអ្នកស្តាប់ ឱ្យជឿមកលើយើង។

បើខ្ញុំជាពាណិជ្ជករធំ ខ្ញុំក៏ប្រើការឃោសនាដែរ ព្រោះសង្គមសាកលភាវូបនីយកម្ម សេដ្ឋកិច្ចមានការប្រកួតប្រជែងគ្នាខ្លាំងណាស់ បើខ្ញុំមិនធ្វើការផ្សព្វផ្សាយឱ្យគេជឿទុកចិត្តមកលើក្រុមហ៊ុនខ្ញុំនោះទេក្រុមហ៊ុនយើងខ្ញុំច្បាស់ជាក្ស័យធនជាមិនខាន។

៤. អត្ថបទព័ត៌មានខុសពីអត្ថបទឃោសនាត្រង់៖

អត្ថបទព័ត៌មានជាអត្ថបទមួយ ដែលរៀបរាប់ពីសច្ចៈភាពមួយរយភាគរយ ចំណែកអត្ថបទឃោសនាជាអត្ថបទមួយដែលច្រើនតែជាការលើកជើងលើកដៃដល់អតិថិជនដូចនេះ ភាពពិតរបស់វាមិនពេញបរិបូណ៌ទេ។

៥. យើងអាចដឹងថា ការឃោសនាដែលល្អ គឺការឃោសនាដែលអ្នកឃោសនាមិនបានបំផ្លើសហួសពីការពិត គិតប្រយោជន៍រួមជាធំច្រើនជាការឃោសនាពី ការសិក្សា និងកិច្ចការសង្គមផ្សេងៗ។ ចំណែក ការឃោសនាដែលមិនល្អគឺជាការឃោនាដែលប្រើពាក្យទាក់ទាញ គេងប្រវ័ញ្ចផលចំណេញ គិតតែពីប្រយោជន៍ផ្ទាល់ខ្លួន។

៦. អត្ថបទឃោសនាខាងលើមានតម្លៃអប់រំដូចជា៖

-ឱ្យយើងស្គាល់ពីអ្វីជាអត្ថបទឃោសនា ។

-ឱ្យយើងចេះប្រើប្រាស់អត្ថបទឃោសនា ដើម្បីបង្ហាញពីវត្ថុបំណងរបស់ខ្លួន។

-ឱ្យយើងចេះលៃលកស្វែងយល់ វិភាគលើអត្ថបទឃោសនាមួយវិញទៀតក្នុងការឃោសនា មនុស្សគួរតែមានក្រមសីលធម៌ត្រូវតែគិតប្រយោជន៍រួមជាធំ ចៀសវាងការប្រើប្រាស់អត្ថបទឃោសនាជាអត្ថបទបុគ្គលបង្កមហន្តរាយដល់មនុស្សជាតិ។ ពោលគឺត្រូវមានក្រមសីលធម៌ក្នុងការឃោសនា។

## អំណាន ជីវិតគឺជាការតស៊ូ

### សំណួរ

១. ចូរស្រង់គំនិតសំខាន់និងសេចក្តីលំអិតរបស់អត្ថបទ។

២. តើមានតឹកតាងអ្វីខ្លះដែលបញ្ជាក់ថាបងស្រីជាមនុស្សតស៊ូក្នុងជីវិត?

៣. តើអត្ថបទខាងលើមានតម្លៃអប់រំដូចម្តេចខ្លះ?

៤. ចូរសង្ខេបអត្ថបទឡើងវិញ។

៥. ចូររកពាក្យក្លាយផ្នត់ទម្រង់និងន័យសេចក្តីនៃពាក្យឫស "ដើរ"។

### ចម្លើយ

១. គំនិតសំខាន់របស់អត្ថបទគឺ *ជីវិតជាការតស៊ូ*។ សេចក្តីលំអិត ៖

-បងស្រីនាំកូនកាប់គាស់រានដីនោះដើម្បីដាំដំណាំដោះស្រាយជីវភាព។

-គាត់ត្រូវធ្វើការនៅឆ្ងាយពីផ្ទះដើម្បីយកអង្ករមកផ្គត់ផ្គង់គ្រួសារ គាត់ប្រឹងដាំដំណាំនៅជុំវិញផ្ទះ។

-ពេលណាគ្មានអង្ករគាត់គាស់ដំឡូងដែលដាំនៅក្បែរផ្ទះ ស្ងោរឱ្យកូនបរិភោគជំនួសបាយ ហើយនាំកូនសម្រាក។

-គាត់ឆ្លៀតដាំដំណាំបន្ថែម។

២. មានតឹកតាងដែលបញ្ជាក់ថាបងស្រីជាមនុស្សតស៊ូក្នុងជីវិតគឺគាត់ចិញ្ចឹមកូនចំនួន៥នាក់។

-គាត់អាចចេញទៅធ្វើការលើកដីដើម្បីប្តូរយកអង្ករ ដែលមានចម្ងាយ៥គីឡូម៉ែត្រ។

-គាត់ឆ្លៀតដាំបន្លែជុំវិញផ្ទះ។

-ទោះបីជាគាត់លំបាកយ៉ាងណា ក៏គាត់អាចរកអាហារមកផ្គត់ផ្គង់កូនៗរបស់គាត់រហូតមានសាច់ទ្រលុកទ្រលន់។

-បងស្រីគាត់បាននិយាយថា ៉ទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនដើរសុំទានគេដែរ ខ្ញុំសុខចិត្តប្រើកម្លាំងដ៏ស្អួចស្តើងរបស់ខ្ញុំ កាប់គាស់ដាំដំណាំយកផលចិញ្ចឹមកូនវិញ។

៣. អត្ថបទខាងលើមានតម្លៃអប់រំដូចជា៖

-មនុស្សមានដៃមានជើងត្រូវតែតស៊ូមិនត្រូវទៅដើរសុំទានគេទេ

-ក្នុងនាមជាម្តាយត្រូវតែចេះផ្គត់ផ្គង់ថែរក្សា ហើយនឹងអប់រំកូន

-អប់រំមនុស្សមិនឱ្យរើសអើងការងារ

៤. សង្ខេបអត្ថបទឡើងវិញ៖

ជីវិតជាការតស៊ូ ក្រោយពេលប្ដីលាចាកលោកទៅ លោកបានបន្សល់ទុកកូនចំនួន៥នាក់ បងស្រីរស់នៅដោយវេទនានាំកូនកាប់ឆ្ការដីព្រៃដើម្បីដាំដំណាំ ដោយពិបាកពេកគាត់បញ្ជូនកូនស្រីពីរនាក់ទៅឱ្យបងប្អូននៅភ្នំពេញដើម្បីជួយចិញ្ចឹម ដោយទុកតែបីនាក់។ ក្រៅពីដាំដុះ គាត់ឆ្លៀតទៅធ្វើការឱ្យគេថែមទៀត ជាអ្នកកាប់គាស់រែកដី ដើម្បីប្ដូរយកអង្ករ ទុកកូនតូចៗបីនាក់ឱ្យនៅចាំផ្ទះ។ ពេលអត់ខ្លាំង គាត់ស៊ូនាំកូនហូបដំឡូងជំនួសបាយតែគាត់នៅតែមានភាពរឹងប៉ឹង ហើយនិយាយថា *«ទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនដើរសុំទានគេដែរ ខ្ញុំសុខចិត្តប្រើកម្លាំងដ៏ស្លូតស្ដើងរបស់ខ្ញុំ កាប់គាស់ដាំដំណាំយកផលចិញ្ចឹមកូនវិញ»*។ នេះបញ្ជាក់ថាគាត់ជានារីដែលមានស្មារតីតស៊ូយ៉ាងថ្លៃថ្នូរគួរឱ្យគោរពសរសើរ។ ជាពិសេសកូនស្រីទាំងបីរបស់គាត់ មានសាច់ឈាមទ្រលុកត្រលុនបញ្ជាក់ថាពួកគេបរិភោគអាហារមានជីវភាពគ្រប់គ្រាន់។

៥. ពាក្យក្លាយ ផ្នត់ ទម្រង់ និងន័យសេចក្ដី នៃពាក្យឫស "ដើរ"

-ដើរ > ដំណើរ ផ្នត់ជែក [-អំម/ណ-] ទម្រង់ "-សព/ព-"ន័យសេចក្ដី : ការឈានជើងទៅមុខ ឬឥរិយាបថ។

-ដើរ > បណ្ដើរ ផ្នត់ដើម [បណ់-] ទម្រង់ "ពសព-"ន័យសេចក្ដី : ឥរិយាដើរជាគូជាគ្នា ដើរជាគូត្រសង។

-ដើរ > ថ្មើរ ផ្នត់ជែក [-ម-] ទម្រង់ "ព-"ន័យសេចក្ដី : អ្នកដើរ។

# អំណាន តម្លៃនៃការជឿទុកចិត្ត

## សំណួរ

១. តើអត្ថបទខាងលើនិយាយពីអ្វី?

២. ចូរបង្ហាញខ្លឹមសារនៃអត្ថបទ?

៣. តើអ្វីទៅតម្លៃនៃការជឿជាក់?

៤. ហេតុអ្វីបានជាប្រធានក្រុមហ៊ុនហ៊ានទម្លាយការសម្ងាត់របស់ក្រុមហ៊ុនប្រាប់ដល់និយោជិតរបស់គាត់? តើការសម្ងាត់នោះជាអ្វី?

៥. ប្រសិនបើអ្នកជាប្រធានក្រុមហ៊ុនឬប្រធានអង្គភាពមួយ ,តើអ្នកត្រូវធ្វើដូចម្តេច ដើម្បីឱ្យបុគ្គលិកឬ មន្ត្រីក្រោមឱវាទមានទំនុកចិត្ត និងមានការជឿជាក់មកលើខ្លួន?

៦. តាមរយៈអត្ថបទ តើបទពិសោធន៍អ្វីដែលប្រធានក្រុមហ៊ុនទទួលបានពីបុគ្គលិករបស់គាត់នឹងធ្វើឱ្យគាត់មានការជឿជាក់?

៧. ចូរសង្ខេបអត្ថបទឡើងវិញ។

## ចម្លើយ

១.អត្ថបទខាងលើនិយាយពីការប្រជុំរបស់ក្រុមហ៊ុនMATSUSHITA ដែលស្តែងអំពី *ការទម្លាយការសម្ងាត់របស់ក្រុមហ៊ុនទៅដល់បុគ្គលិកទាំងអស់ឱ្យទទួលខុសត្រូវ*។

២. បង្ហាញខ្លឹមសារនៃអត្ថបទគឺ *តម្លៃនៃការជឿទុកចិត្តគ្នារវាងសមាជិកទាំងអស់ដែលធ្វើការនៅក្នុងក្រុមហ៊ុនអគ្គីសនី។ ប្រធាន*

*ក្រុមហ៊ុន បានបើកកកាយអាថ៌កំបាំងក្រុមហ៊ុនប្រាប់ទៅដល់សមាជិក រឿងនេះប្រឈមមុខទៅនឹងការប្រថុយប្រថាន តែគាត់នៅតែធ្វើ ព្រោះគាត់មានការជឿជាក់ខ្លាំងណាស់ទៅលើអត្តចរិករបស់បុគ្គលិកគាត់។*

៣.តម្លៃនៃការជឿជាក់គឺ(ភាពស្មោះត្រង់) *ការទុកចិត្តដោយឥតសង្ស័យរវាងបុគ្គលនិងបុគ្គល ឬក្រុមនិងក្រុមក្នុងន័យសហការគ្នាដើរក្នុងផ្លូវតែមួយលើកិច្ចប្រតិបត្តិដោយឥតមន្ទិលសង្ស័យគ្នា។*

៤. បានជាប្រធានក្រុមហ៊ុនហ៊ានទម្លាយការសម្ងាត់របស់ក្រុមហ៊ុនប្រាប់ដល់និយោជិតរបស់គាត់ ព្រោះដោយសារតែការងាររបស់គាត់កាន់តែរីកដុះដាលឡើង ធ្វើឱ្យក្រុមគ្រួសាររបស់គាត់មិនអាចគ្រប់គ្រងតែឯងបាន ម្យ៉ាងទៀតគាត់មានការជឿទុកចិត្តឥតសង្ស័យ ទៅលើបុគ្គលិកទាំងអស់របស់គាត់គ្មានចន្លោះណាម្នាក់។ ការសម្ងាត់នោះគឺ***រូបមន្តផលិតកម្ម ផលិតសម្ភារៈប្រើប្រាស់ក្នុងផ្ទះដើរដោយចរន្តអគ្គីសនី***ដលមានឈ្មោះថា *ឆ្នាំបចរន្ត*។

៥. ប្រសិនបើខ្ញុំជាប្រធានក្រុមហ៊ុន ឬប្រធានអង្គភាពមួយ ដើម្បីឱ្យបុគ្គលិក ឬមន្ត្រីក្រោមឱវាទមានទំនុកចិត្ត និងមានការជឿជាក់មកលើខ្លួនខ្ញុំត្រូវស្គាល់ខ្លួនឯងឱ្យបានច្បាស់ បន្ទាប់មកស្វែងយល់ពីបុគ្គលិកទាំងអស់។ ត្រូវមានភាពស្មោះត្រង់ចំពោះខ្លួនឯងបង្កើតច្បាប់សម្រាប់ក្រុមហ៊ុន ហើយអនុវត្តច្បាប់ធ្វើជាគម្រូដល់ពួកគេ។

៦. តាមរយៈអត្ថបទ បទពិសោធន៍ដែលប្រធានក្រុមហ៊ុនទទួលបានពីបុគ្គលិករបស់គាត់ និងធ្វើឱ្យគាត់មានការជឿជាក់គឺ : *ដោយសារតែគាត់គិតថាការរក្សាទុកនៃអាថ៌កំបាំងមិនមានភាពរីកចម្រើនទេ ម្យ៉ាងទៀតគាត់បានមើលទៅលើជំហរការងារ អត្តចរិកល្អ ឬមិនល្អរបស់បុគ្គលិក។ ការបង្រៀនការសម្ងាត់ដល់បុគ្គលិកនៅក្នុងក្រុមហ៊ុន គាត់គិតថាវាមិនមែនជាការបង្រៀនដល់អ្នកក្រៅទេ គឺបង្រៀនអ្នកដែលធ្វើការជាមួយគាត់។ ក្នុងករណីនេះប្រសិនក្រុមហ៊ុនមានការខាតបង់ បុគ្គលិកទាំងអស់នៅក្នុងក្រុមហ៊ុនក៏មានការខាតបង់ដែរ។ ពោលគឺភាពជឿជាក់គ្នាទៅវិញទៅមកទើបធ្វើឱ្យក្រុមហ៊ុនមានការរីកចម្រើន។*

៧. សង្ខេបអត្ថបទ៖

អាថ៌កំបាំងរបស់ក្រុមហ៊ុនត្រូវបានលាក់ជាយូរមកហើយ មានតែប្រធានក្រុមហ៊ុនក្រុម គ្រួសារ និងអ្នកនៅរោងចក្រពីបីនាក់តែប៉ុណ្ណោះដែលដឹង។ ក្រោយពីបានធ្វើការពិចារណាយ៉ាងល្អិតល្អន់គាត់បានសម្រេចចិត្ត ទម្លាយអាថ៌កំបាំងនេះទៅដល់បុគ្គលិកទាំងអស់នៅក្នុងក្រុមហ៊ុនឱ្យបានដឹង។ អាថ៌កំបាំងនោះគឺរូបមន្តនៃការផលិត ឧបករណ៍ប្រើប្រាស់នៅក្នុងផ្ទះដោយប្រើចរន្តអគ្គីសនី។ ដំបូងឡើយមានគេជាស់តឿនគាត់ជាច្រើន ថាគាត់ធ្វើការទាំងប្រថុយប្រថាន គាត់បានថ្លែងអំណរគុណទៅដល់អ្នកដាស់តឿនគាត់ តែគាត់គិតថាការទុកអាថ៌កំបាំងនេះវាមិនបានធ្វើឱ្យមានផល

ចំណេញទេ គាត់ត្រូវតែបើកទូលាយនូវអាថ៌កំបាំងនេះទៅដល់បុគ្គលិកទោះបីបុគ្គលិកមកធ្វើការនៅថ្ងៃនេះក៏ដោយ។ ការជឿជាក់លើគ្នាវាជាទំនុកចិត្តដ៏សំខាន់ទើបធ្វើឱ្យក្រុមហ៊ុនមានការរីកចម្រើន ព្រោះការខាតបង់និងផលចំណេញក៏ជាការទទួលខុសត្រូវរួមដែរ។

# ការស្តាប់ អ្នកនិយាយទូរទស្សន៍

## សំណួរ

១. តើអត្ថបទនេះនិយាយពីអ្វី?

២. តើអ្នកនិយាយតាមទូរទស្សន៍ជាមនុស្សដូចម្តេច?

៣. តើមុនពេលផ្សាយនិងកំពុងផ្សាយតាមទូរទស្សន៍ អ្នកនិយាយតាមទូរទស្សន៍ត្រូវធ្វើដូចម្តេចខ្លះ?

៤. តើអ្នកនិយាយតាមទូរទស្សន៍ និងទស្សនិកជនមានភាពស្និទ្ធស្នាលគ្នាដូចម្តេច?

៥. ចូរសង្ខេបអត្ថបទឡើងវិញ។

## សំណេរ បំពេញទម្រង់បែបបទប្រើប្រាស់ប្រចាំថ្ងៃ

### សំណួរ

១. តើសំណេរពាក្យសុំចុះឈ្មោះជាបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិចំណោះទូទៅខាងលើនេះរៀបរាប់ពីអ្វីខ្លះ?

២. តើអ្នកត្រូវបំពេញសំណេរពាក្យសុំនេះយ៉ាងដូចម្ដេច ដើម្បីចៀសវាងការខុសឆ្គង?

៣. តើចំណុចសំខាន់ៗដែលត្រូវបំពេញមានអ្វីខ្លះ?

### ចម្លើយ

១. សំណេរពាក្យសុំចុះឈ្មោះជាបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិចំណោះទូទៅខាងលើនេះរៀបរាប់ពី*ជីវប្រវត្តិសង្ខេប សេចក្ដីស្នើសុំ កិច្ចសន្យារបស់បុគ្គល ព្រមទាំងសេចក្ដីណែនាំមួយចំនួនដែលមានចុះថ្ងៃ ខែ ហត្ថលេខា នៅខាងស្ដាំ។*

២. ខ្ញុំត្រូវបំពេញសំណេរពាក្យសុំនេះ ដើម្បីចៀសវាងការខុសឆ្គងគឺត្រូវអានសេចក្ដីណែនាំជាមុនសិន ដែលមាននៅផ្នែកខាងក្រោម យកល្អយើងគួរតែសរសេរព្រៀងជាមុនរួចចម្លងចូល ឱ្យចំគោលដៅដែលគេចង់បាន។

៣. ចំណុចសំខាន់ៗដែលត្រូវបំពេញមានដូចជា ៖

-ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ជនជាតិ សញ្ជាតិ ភេទ

-ជាសិស្សថ្នាក់ទីប៉ុន្មាន?( នៃវិទ្យាល័យ ឬអនុវិទ្យាល័យណា)

-បំពេញគ្រង់ចំណុចស្នើសុំឱ្យបានអស់ ព្រោះជាកិច្ចស្នើសុំទៅដល់ក្រសួង

-ចំណុចចុងក្រោយត្រូវតែមានហត្ថលេខានិងឈ្មោះ។

# សំណេរ តែងសេចក្ដី

## សំណួរ

១. តើសំណេរខាងលើនេះនិយាយពីអ្វី? តើមានផ្នែកសំខាន់ៗអ្វីខ្លះ?

២. តើកថាខណ្ឌទី១ របស់សំណេរបង្ហាញពីអ្វី?

៣. តើក្នុងតួសេចក្ដីមានប៉ុន្មានកថាខណ្ឌ? កថាខណ្ឌនីមួយៗនិយាយពីអ្វី?

៤. តើសេចក្ដីបញ្ចប់និយាយពីអ្វី?

## ចម្លើយ

១. សំណេរខាងលើនេះនិយាយពីសេចក្ដីថ្លៃថ្នូររបស់ចៅចិត្រដែលនាំទៅរកភាពឧត្ដុង្គឧត្ដមនៅទីបញ្ចប់។ ផ្នែកសំខាន់ៗបី គឺសេចក្ដីផ្ដើម តួសេចក្ដី និងសេចក្ដីបញ្ចប់។

២.កថាខណ្ឌទី១ របស់សំណេរបង្ហាញពីសេចក្ដីផ្ដើម ដែលមានលំនាំ ចំណូល ចំណោទៈហើយទាក់ទងទៅនឹង *"ចៅចិត្រក្នុងរឿងក្លាហប់ប៉ិលិនជាយុវជនថ្លៃថ្នូរ"*។

៣. ក្នុងតួសេចក្ដីមាន៦កថាខណ្ឌ។

កថាខណ្ឌនីមួយៗនិយាយពី៖

-ទី១ : ឃ្លាភ្ជាប់សេចក្តី និងពន្យល់ពាក្យ "យុវជនថ្ងៃថ្នូរ"។

-ទី២ :ការសិក្សា និងភាពកត្តញ្ញូរបស់ចៅចិត្ត។

ទី៣ :ចៅចិត្តពឹងផ្អែកលើខ្លួនឯងក្រោយពេលឪពុកស្លាប់ទៅ។

ទី៤ :ការមិនប្រកាន់ ការងារធ្វើរបស់ចៅចិត្ត(ធ្វើជាកម្មករ)។

ទី៥ :ការទទួលជោគជ័យក្នុងរឿងស្នេហារបស់ចៅចិត្ត។

ទី៦ :ការសរុបសេចក្តីដែលបានរៀបរាប់ខាងលើ។

៤. សេចក្តីបញ្ចប់និយាយពី ការវាយតម្លៃទៅលើប្រធានបទនិងមតិផ្ទាល់ខ្លួន។

## លំហាត់

ចូរប្អូនជ្រើសរើសប្រធានបទណាមួយក្នុងចំណោមប្រធានបទខាងក្រោមដែលប្អូនពេញចិត្តដើម្បីបកស្រាយ។

- សុភាសិតខ្មែរមួយចែងថា "ដឹងឆ្លើយត្បិតដង កូនសោតរំលងឆ្លងត្បិតតែឪពុក"។
- គេតែងនិយាយថា "យុវជនជាទំពាំងស្នងឫស្សី"។ តើមតិនេះមានអត្ថន័យយ៉ាងណា?
- សុភាសិតមួយឃ្លាពោលថា "ជួយខ្លួនឯងបានទើបទេវតាជួយជាក្រោយ"។ តើសុភាសិតនេះមានន័យដូចម្តេច?

# មេរៀនទី៨ សេក្ដីព្យាយាម

## វេយ្យាករណ៍ ពាក្យផ្សំ

### សំណួរ

១. ដូចម្ដេចហៅថាពាក្យ?

២. ដូចម្ដេចហៅថាពាក្យផ្សំ?

៣. តើពាក្យផ្សំមានប៉ុន្មានបែប? ចូរបង្ហាញ និងលើកឧទាហរណ៍?

### ចម្លើយ

១. ហៅថាពាក្យគឺជាឯកតារបស់ឈ្មោះដែលវាធំជាងព្យាង្គ វាតូចជាងកន្សោមពាក្យ ហើយវាមានន័យ។

២. ហៅថាពាក្យផ្សំគឺជាពាក្យដែលកើតឡើងដោយការយកពាក្យពីរ ឬច្រើនដាក់បន្តគ្នា ហើយពាក្យដែលកើតថ្មីនោះមានន័យផ្សេងពីពាក្យឫសដើមនិ ងពាក្យបន្ថែមដើម ឬពាក្យបន្ថែមចុង។

៣. ពាក្យផ្សំមាន២បែបៈ

**+បែបទី១**

**-ពាក្យបន្ថែមដើម**(សេចក្ដីព្យាយាម ការសិក្សា អ្នកស្រែ ជនកំហូច)។

**-ពាក្យបន្ថែមចុង**(វាទកម្ម ភារកិច្ច មិត្តភាព វប្បធម៌ កម្មករ វីរនារី)

**+បែបទី២**

-នាម+នាម(ជើងគោ)

-នាម+គុណនាម(ឈើទាល)

-នាម+កិរិយា(ត្បាលកិន)

-គុណនាម+នាម(ក្តៅចិត្ត)

-កិរិយា+នាម(ទាញព្រ័ត្រ)

## អំណាន ឧត្តមគតិបុគ្គលសំខាន់

### សំណួរ

១. តាមរយៈអត្ថបទនេះ តើមានបុគ្គលសំខាន់ៗណាខ្លះ?

២. ចូរបង្ហាញពីឧត្តមគតិរបស់ព្រះនាងឥន្ទ្រទេវីតាមរយៈអត្ថបទនេះ?

៣. តើអតីតព្រះមហាក្សត្រខ្មែររាជវង្សស្រីមារៈ មានឧត្តមគតិដូចម្តេចខ្លះ?

៤. ចូរពន្យល់ "មនុស្សរឹងរូសវិនាសយស" ឱ្យបានក្បោះក្បាយ។

### ចម្លើយ

១. តាមរយៈអត្ថបទនេះ មានបុគ្គលសំខាន់ៗគឺសម្តេចសង្ឃរាជជួនណាត ព្រះនាងឥន្ទ្រទេវី បណ្ឌិតប៉ាំងខាត់ លោកម៉ាទិនទ្យូធីរ លោកត្បុកអះ វេល្លិងត័ន កោស៊ីវ៉លទ័រស្គត់ លោករូប៊ឹតស័ននិងលោករ៉ុលទែ។

២. ឧត្តមគតិរបស់ព្រះនាងឥន្ទ្រទេវី គឺជាគតិព្រឹទ្ធបណ្ឌិតនារីទី១ក្នុងសម័យអង្គរ ដែលបានជំរុញប្រទេសជាតិឱ្យមានការរីកចម្រើនដល់កំពូលលើវិស័យសិល្បៈអក្សរសាស្ត្រ វប្បធម៌ ព្រះនាងបានបង្កើតសាលាបាលីជាន់ខ្ពស់ ជាសកលវិទ្យាធិការ ជាសាស្ត្រាចារ្យបង្រៀនស្ត្រីខ្មែររាជបរិពារអំពីព្រះពុទ្ធសាសនា។ ព្រះនាងក៏ជាអ្នកនិពន្ធកំណាព្យភាសាសំស្ក្រឹតជាច្រើននិងចូលរួមផ្នែកសង្គមកិច្ចដូចជាការបង្កើតមន្ទីរពេទ្យ ផ្គត់ផ្គង់ក្មេងកំព្រា ស្ត្រីគ្មានទីពឹង ការធ្វើទាន និងសាងរូបបដិមាជាដើម។

៣. អតីតព្រះមហាក្សត្រខ្មែររាជវង្សស្រីមារៈ មានឧត្តមគតិដូចតទៅ : ជាក្សត្រមួយអង្គព្រះថ្លានិងព្រះពុទ្ធសាសនា មានចិត្តធម៌ចំពោះរាស្ត្រ ដូចនៅលើផ្ទាំងសិលាចរិករបស់ព្រះអង្គបាននិយាយថា "កាលបើកូនខ្ញុំក្ដី បងប្អូនខ្ញុំក្ដី មិនមែនអ្នកកន្ទៀតទេបានសម្រេចបំណងខ្លួនហើយបានសោយរាជ្យទៅ" ខ្ញុំឱ្យយកសម្បត្តិខ្ញុំទាំងអស់ប្រាក់មាស សង្ហារិមក្ដី អសង្ហារិមក្ដីទៅប្រើជាវត្ថុជាទីរីករាយនិងជាប្រយោជន៍ដល់សត្វលោកទាំងឡាយ។ នេះជាសេក្ដីបញ្ញារបស់ខ្ញុំ។ សូមព្រះរាជាទាំងឡាយ នៅក្នុងអនាគតប្រតិបត្តិតាមព្រះបញ្ញាខ្ញុំកុំបីខាន។ ហើយចូរប្រឹក្សាជាមួយសេវៈកាមាត្រឈ្មោះវីៈ...របស់ខ្ញុំ។

៤. ពន្យល់ "មនុស្សរឹងរូសវិនាសយស"

ដើមកំណើតនៃសេចក្ដីមហន្តរាយ តែងតែមានមូលហេតុរបស់វាយ៉ាងពិតប្រាកដ។ ដូច្នេះហើយគេពោលថា "មនុស្សរឹងរូសវិនាសយស"។ តើកន្សោមនេះមានន័យយ៉ាងណា?

យស សំដៅទៅលើកេរ្តិ៍ឈ្មោះឋានៈតួនាទី។ ការជាស់តឿនមានន័យថា គេយកចិត្តទុកដាក់ គេស្រឡាញ់មកលើយើង ភាគច្រើននៃអ្នកដាស់តឿនគឺជាមនុស្សចាស់ ធ្លាប់មានបទពិសោធពីបញ្ហារាក់ជ្រៅ ដូច្នេះប្រសិនបើយើងបដិសេធចោលហើយវិនាសក្រាញគំនិតមិនព្រមស្ដាប់មតិរបស់អ្នកដទៃគង់តែអន្តរាយអស់នូវលាភយសជាមិនខាន។ដូចនៅក្នុងរឿងធនញ្ជ័យជាដើម ស្ដេចតែងខ្លាចនិងច្រណែនទៅលើធនញ្ជ័យ យកលេសមិនប្រើអ្នកប្រាជ្ញ មិនព្រមស្ដាប់ធនញ្ជ័យទើបត្រូវបរទេសមើលងាយទ្រង់ ហើយសូម្បីធមញ្ជ័យក៏មើលងាយដែរ ដោយចំពិតគួរដាក់ជាដើម។ចំណែករឿងកូលាបប៉ៃលិនលោកបាល័ដ្ឋរឹងរូសមិនស្ដាប់ពាក្យអ្នកដទៃចូលចាប់និងប្លន់នាងឃុននារីទើបធ្វើឱ្យបង់កេរ្តិ៍ឈ្មោះនិងជីវិត ដែលផ្ទុយពីចៅចិត្រដែលស្ដាប់ដំបូន្មានតាចឹម *អត្តាហិ អត្តានោនាថោ* ទើបធ្វើឱ្យគាត់បានរីកចម្រើនទាំងកេរ្តិ៍ឈ្មោះនិងកិត្តិយស។

រួមសេចក្ដីមកការវិនាសរឹងរូស ជាគ្រឿងដុតបំផ្លាញកេរ្តិ៍ឈ្មោះកិត្តិយសនៃជីវិត។

ឆ្លងតាមករបង្ហាញខាងលើប្រធានពិតជាមានតម្លៃអប់រំល្អ អប់រំមនុស្សឱ្យលះបង់នូវសេចក្ដីរឹងរូស ចាប់យកនូវកេរ្តិ៍ឈ្មោះ។ ក្នុង

នាមយើងជាសិស្សត្រូវស្តាប់ដំបូន្មានគ្រូបាអាចារ្យ ឪពុកម្តាយដើម្បីទទួលបាននូវកេរ្តិ៍ឈ្មោះរុងរឿង។

# អំណាន អាលីយូស្សា

## សំណួរ

១. តើអាលីយូស្សាបានធ្វើអ្វី ទើបទទួលបានសៀវភៅ? តើអាលីយូស្សាមានអារម្មណ៍ដូចម្តេចចំពោះសៀវភៅនោះ?

២. ហេតុអ្វីបានជាគេធ្វើទារុណកម្មក្មេងនេះ? តើអ្នកយល់ដូចម្តេចចំពោះទារុណកម្មបែបនេះ? ចូររកអំណះអំណាងគាំទ្រគំនិតរបស់អ្នក។

៣. តើនៅទីបញ្ចប់អាលីយូស្សាបានទទួលលទ្ធផលដូចម្តេចខ្លះ?

៤. ចូរអ្នកបង្ហាញតម្លៃអប់រំរបស់អត្ថបទ។

៥. តើល្បះខាងក្រោមនេះបង្ហាញអារម្មណ៍របស់តួអង្គអាលីយូស្សាដូចម្តេចខ្លះ? "មួយសន្ទុះក្រោយមកស្រាប់តែឮសូរផ្ទុះយ៉ាងខ្លាំងខុសធម្មតា។ អាលីយូស្សាស្ទុះប្រញាប់ប្រញាល់ទៅផ្ទះបាយ។ **កុមារភិតភ័យយ៉ាងខ្លាំង ដោយឃើញកំសៀវទឹកផ្ទុះខូច**"។

## ចម្លើយ

១. អាលីយូស្សាបាននាំកុមារទៅជូនម្តាយនាងវិញ ដោយរៀបប្រាប់ពីដំណើររឿង ទើបម្តាយកុមារនោះឱ្យអាលីយូស្សាខ្ចីសៀវភៅ។ អាលីយូស្សាមានអារម្មណ៍សប្បាយចិត្តណាស់ ហើយចាប់ផ្តើម

ទំព័រអានភ្លាមឃើញ *"ផ្ទះសំបែងក៏ដូចជាមនុស្ស អ្វីៗក៏មានសភាពខាងក្រៅផ្សេងរបស់វា"* ល្បះនេះត្រូវណាស់ធ្វើឱ្យអលីយូស្សាភាំងស្មារតី។

២. បានជាគេធ្វើទារុណកម្មក្មេងនេះ ព្រោះអាលីយូស្សាវល់មើលសៀវភៅភ្លេច ធ្វើឱ្យកំសៀវទឹកផ្ទុះ។ ខ្ញុំយល់ថាចំពោះទារុណកម្មបែបនេះមិនត្រឹមត្រូវទេ ហើយឃោរឃៅខ្លាំងណាស់ពោះកុមារដែលគ្មានៅក្មេងតែងតែធ្វេសប្រហែស។ កុមារគឺជាវ័យមួយដែលគេត្រូវឱ្យរៀនសូត្រមិនត្រូវដាក់កំហិត ឱ្យកុមារធ្វើការពលកម្មព្រោះវាខុសច្បាប់ពលកម្មកុមារ។ ការវាយដុំកុមារគឺជាអំពើដែលប្រឆាំងទៅលើច្បាប់ពលកម្មកុមារ ពោលអំពើនេះបំបិទសិទ្ធិកុមារទាំងស្រុង។

៣. នៅទីបញ្ចប់អាលីយូស្សាបានក្លាយជាអ្នកនិពន្ធដ៏ល្បីល្បាញនៅលើពិភពលោកដែលមានឈ្មោះថា *ម៉ាកស៊ីមគ័រគី។*

៤. តម្លៃអប់រំរបស់អត្ថបទ

-អប់រំឱ្យតស៊ូរៀនសូត្រ

-អប់រំឱ្យចេះជួយគ្នាក្នុងគ្រាមានអាសន្ន

-អប់រំកុំឱ្យធ្វើបាបក្មេង

-អប់រំឱ្យចេះអត់ធ្មត់ស៊ូទ្រាំ ដឹងគុណចំពោះអ្នកផ្តល់ជំរក

-អប់រំឱ្យមនុស្សចេះទទួលកំហុស ហើយចេះកែខ្លួននៅថ្ងៃក្រោយ

-ស្រឡាញ់ការតស៊ូរៀនសូត្រអនាគតជាអ្នកប្រាជ្ញ។
៥.អារម្មណ៍របស់តួអង្គអាលីយូស្សាគឺ*ក្នុងខណៈ ពេលកំពុងអានសៀវភៅជក់ចិត្តអារម្មណ៍ ស្រាប់តែឮសម្លេងផ្ទះឡើង អាលីយូស្សាគិតថាប្រហែលជាបែកកំសៀវ ឬក៏អាខូចខាតអ្វីផ្សេងទៀត ឬក៏ឆេះផ្ទះក៏អាច។ ក្នុងចិត្តគិតថា ម្ចាស់ផ្ទះប្រាកដជាខឹងនិងធ្វើទារុណកម្មយ៉ាងណាទេ ឬមួយគេឱ្យបង់ជាប្រាក់មិនដឹង។ក្នុងអារម្មណ៍ក្មេងញ័រញាក់សព្វអស់ជើងដៃ ជូនអីម្ចាស់ផ្ទះក៏មកដល់ទៀត អាលីយូស្សារិតតែភ័យគ្មានអ្វីប្រៀបផ្ទឹមបានឥតទីផុត។*

# ការស្ដាប់ ការមិនលះបង់សេចក្ដីព្យាយាម

## សំណួរ

១. តើអត្ថបទនេះនិយាយពីអ្វី?

២. ហេតុអ្វីត្រូវមានសេចក្ដីព្យាយាម?

៣. តើសេចក្ដីព្យាយាមមានប្រយោជន៍អ្វីខ្លះដល់មនុស្ស?

៤. តើការមិនលះបង់សេចក្ដីព្យាយាមបានណែនាំឱ្យអ្នកឱ្យធ្វើអ្វីខ្លះ? មិនឱ្យធ្វើអ្វីខ្លះ?

៥. តើអ្នកអាចវាយតម្លៃលើភាពច្បាស់លាស់នៃអត្ថបទបានយ៉ាងដូចម្ដេច?

៦. ចូរអ្នកឡើងបង្ហាញដោយសង្ខេបនូវអត្ថន័យនៃឯកតាបទណែនាំដែលអ្នកបានស្ដាប់ដោយប្រើប្រាស់សំឡេងនិងល្បឿនក្នុងការនិយាយបានត្រឹមត្រូវ។

## ការនិយាយ ការបង្ហាញពីការណែនាំមួយ

### សំណួរ

១. តើគេច្រើនលេងល្បែងប្រជាប្រិយនេះនៅវេលាណា?

២. តើគេត្រូវការមនុស្សប៉ុន្មាននាក់ក្នុងការលេងល្បែងនេះ?

៣. ចូរបង្ហាញពីរបៀបលេងល្បែងគ្រូបមាន់នេះ។

៤. តើគេកំណត់ការឈ្នះនិងចាញ់ដូចម្ដេចខ្លះ ក្នុងការលេងល្បែងគ្របមាន់?

៥. តើបុព្វបុរសខ្មែរបង្កើតល្បែងនេះឡើងមានគុណប្រយោជន៍ដូចម្ដេចខ្លះ?

៦. តើគេបង្ហាញចំណុចអ្វីខ្លះ ក្នុងការលេងល្បែងគ្របមាន់ខាងលើ?

### ចម្លើយ

១.គេច្រើនលេងល្បែងប្រជាប្រិយនេះ រនៅវេលាទំនេរពីការងារជាពិសេសនៅក្នុងពិធីបុណ្យទានធំៗ ដូចជា បុណ្យចូលឆ្នាំ ភ្ជុំបិណ្ឌ និងបុណ្យផ្សេងៗទៀត។

២. គេត្រូវការមនុស្ស១០នាក់ក្នុងការលេងល្បែងនេះ។

៣. របៀបលេងល្បែងគ្របមាន់នេះគឺៈ

-ដំបូងគេរើសមនុស្ស១០នាក់ខាងស្រី៥នាក់ ខាងប្រុស៥នាក់ ។ បន្ទាប់មកគេជ្រើសរើសមនុស្សប្រុសម្នាក់ស្រីម្នាក់ ដើម្បីធ្វើមាន់ ហើយគេឱ្យមាន់ទាំងពីរក្រាបក្បាលរកគ្នា រួចយកកំណាត់សម្ពត់មកគ្រប់ឱ្យជិត ចំណែកសមាជិកដទៃទៀតសំងំលាក់ខ្លួននៅជិតនោះ បន្ទាប់មកទៀតខាងប្រុសចាត់មនុស្សម្នាក់គោះខ្នងខាងស្រីឱ្យរងាវ។ មាន់ខាងស្រីរងាវខំធ្វើសម្លេងឱ្យខុសពីធម្មតាចៀសវាងកុំឱ្យខាងប្រុសទាយត្រូវ។ ករណីអ្នកគោះខ្នងមាន់ស្តាប់សម្លេងមាន់មិនទាន់បានគេអនុញ្ញាតិឱ្យគោះខ្នងម្តងទៀត ប៉ុន្តែបានតែបីដងតែប៉ុណ្ណោះ។ ចំណែកក្រុមស្រីៗក៏ធ្វើដូចក្រុមប្រុសៗដែរ កាលណាគេទាយតាមសម្លេងចំឈ្មោះមនុស្សប្រុស ឬស្រីដែលគេស្គាល់បានត្រឹមត្រូវ គេត្រូវយកមាន់នោះទុកជារបស់ក្រុមគេ។ ប៉ុន្តែបើក្រុមម្ខាងទាយត្រូវវិញនោះគេអាចសងមាន់នោះ មកក្រុមដើមវិញ គេធ្វើរបៀបនេះអស់មាន់ទាំងសងខាង ឬការទទួលបានមាន់ច្រើន ឬក៏អស់មាន់ពីក្រុមខ្លួន។

៤. គេកំណត់ការឈ្នះនិងចាញ់ ក្នុងការលេងល្បែងគ្របមាន់ដោយក្រុមណាទាយត្រូវច្រើនគេបានមាន់ច្រើននឹងត្រូវចាត់ជាអ្នកឈ្នះ។

៥. បុព្វបុរសខ្មែរបង្កើតល្បែងនេះឡើងមានគុណប្រយោជន៍ដូចជា

-បង្កើនពុទ្ធិ

-បង្កើតបរិយាកាសសប្បាយរីករាយ បង្កើតភាពវ៉យឆ្លាត

-ឱ្យចេះសាមគ្គីគ្នាកាន់តែជិតស្និទ្ធ

ជាពិសេសកម្មវត្ថុពិតប្រាកដរបស់វា បង្កើតទំនាក់ទំនងជិតស្និទ្ធរវាងកំលោះ និងក្រមុំព្រោះពីបុរាណកំលោះ ក្រមុំ កម្រមានឱកាសនៅជិតគ្នា និយាយគ្នា ឬបានប៉ះពាល់សាច់គ្នាណាស់ កាលណាបានលេងល្បែងនេះហើយ មិនយូរមិនឆាប់នឹងឮសម្លេងភ្លេងការរពុយៗ។

៦.ការលេងល្បែងគ្របមាន់ខាងលើគេបង្ហាញចំណុចដូចជា៖

-ស្ថានភាពនិងពេលវេលា

-របៀបលេង

-ការកំណត់ឈ្នះ ឬចាញ់

-អត្ថប្រយោជន៍។

# មេរៀនទី៩ ជោគជ័យនៃជីវិត

## បំណិន កំណាព្យបទភុជង្គលីលា

### សំណួរ

១. តើអត្ថបទកាព្យនេះនិយាយពីអ្វី?

២. តើអត្ថបទកាព្យនេះ និពន្ធដោយនរណា? ជាបទអ្វី?

### ចម្លើយ

១. អត្ថបទកាព្យនេះនិយាយពី៖

-បទទី១ : និយាយអំពីការអប់រំមនុស្សស្រី ឱ្យខិតខំធ្វើការខ្លួន មិនទាន់មានប្ដីនិងមានកូន។

-បទទី២ : និយាយពីការរៀបរាប់ពីធម្មជាតិ បក្សាបក្សី ដើម្បីលួងលោមចិត្តនាងកាកីឱ្យលង់លក់។

២. អត្ថបទកាព្យទី១ និពន្ធដោយ*បណ្ឌិតម៉ីនរ៉េ*។ កាព្យទី២ និពន្ធដោយ *ព្រះអង្គឌួង*។ បទទាំងពីរនេះជាបទភុជង្គលីលា។

### លំហាត់

១. តើបទភុជង្គលីលាមានរង្វាស់កាព្យ ចំណាប់ចុងចួន និងការលើកដាក់សំឡេងដូចម្ដេចខ្លះ?

២. ចូរប្អូនសាកល្បងតែងកំណាព្យបទ ភុជង្គលីលា ឱ្យបាន យ៉ាងតិច ៣ វគ្គដែលមានអត្ថន័យទាក់ទងនឹងការព្យាយាម។

**ចម្លើយ**

១. បទភុជង្គលីលា

+***មានរង្វាស់កាព្យ***

ក្នុង១វគ្គមាន៣ឃ្លា ឃ្លាទី១មាន៦ព្យាង្គ ឃ្លាទី២និងទី៣ មាន៤ព្យាង្គ។

+***ចំណាប់ចុងចួន***

*គំនូសតាងចំណាប់ចួន*

១២៣៤៥៦ ១២៣៤ ១២៣៤។

១២៣៤៥៦ ១២៣៤ ១២៣៤។

*សញ្ញាចាប់ចុងចួន*

**ចួនក្នុងវគ្គ**

-ព្យាង្គទី៦ នៃឃ្លាទី១វគ្គទី១ ⟷ ព្យាង្គទី៤ឃ្លាទី២វគ្គទី១ ⟷ ព្យាង្គទី២ នៃឃ្លាទី៣វគ្គទី១។

**ចួនឆ្លងវគ្គ**

-ព្យាង្គទី៤ នៃឃ្លាទី៣វគ្គទី១ ⟷ ព្យាង្គទី៦ នៃឃ្លាទី១វគ្គទី២។

+***សម្រាយចំណាប់ជួន***

**ចួនក្នុងវគ្គ** : ព្យាង្គទី៦ នៃឃ្លាទី១វគ្គទី១ចួននឹង ព្យាង្គទី៤នៃឃ្លាទី២វគ្គទី១ចួននឹងព្យាង្គទី២ នៃឃ្លាទី៣វគ្គទី១។

**ចួនឆ្លងវគ្គ**

-ព្យាង្គទី៤ នៃឃ្លាទី៣វគ្គទី១ ចួននឹងព្យាង្គទី៦ នៃឃ្លាទី១វគ្គទី២

***ចង្វាក់*** : ការលើកដាក់សំឡេងត្រង់ព្យាង្គទី២និងទី៤ទាំងអស់។

២. តែងកំណាព្យបទ ភុជង្គលីលា៣វគ្គដែលមានអត្ថន័យទាក់ទងនឹងការព្យាយាម៖

-ពេលថ្ងៃរៀននៅសាលា ពេលយប់កាលណា ឧស្សាហ៍គំនិត។
-រៀនអានរៀនគូររៀនគិត រៀនមួយជីវិត ផលិតស្នាដៃ។
-ប្រឹងប្រែងមិនយូរយប់ថ្ងៃ សាងភាពល្បាញល្បី ដូចស្រីឥន្ទ្រ(ទេវី)។

## អំណាន វិជ្ជាជាទ្រព្យ

### សំណួរ

១. តើអត្ថបទកាព្យខាងលើនេះនិយាយពីអ្វី?

២. តើអត្ថបទកាព្យខាងលើនេះ និពន្ធឡើងជាបទអ្វី? ជាស្នាដៃរបស់នរណា?

៣. ចូរគូសគំនូសតាងចំណាប់ចុងចួន ក្នុងវគ្គទី ១ ដល់ទី៣។

៤. ចូររកគំនិតសំខាន់របស់អត្ថបទកាព្យខាងលើ។

៥. តើអត្ថបទកាព្យខាងលើនេះមានតម្លៃអប់រំដូចម្ដេច?

## ចម្លើយ

១. អត្ថបទកាព្យខាងលើនេះនិយាយពី ការខិតខំរៀនសូត្រ និង ជំរះនូវភាពមន្ទិលសៅហ្មងទាំងឡាយដែលកើតចេញពីអវិជ្ជា។ វិជ្ជានាំឱ្យបានកេរ្តិ៍ឈ្មោះបុណ្យសក្តិ ឋានៈតួនាទី ដែលនាំឱ្យជីវិតសុខសាន្ត។

២. អត្ថបទកាព្យខាងលើនេះ និពន្ធឡើងជា*បទភុជង្គលីលា*។ ជាស្នាដៃរបស់លោក*រពេជ្រទុំក្រវិល*។

៣. គូសគំនូសតាងចំណាប់ចុងចួន ក្នុងវគ្គទី ១ ដល់ទី៣៖

***គំនូសតាងចំណាប់ចួន***

១២៣៤៥៦ ១២៣៤ ១២៣៤។
១២៣៤៥៦ ១២៣៤ ១២៣៤។
១២៣៤៥៦ ១២៣៤ ១២៣៤។

៤. គំនិតសំខាន់របស់អត្ថបទកាព្យខាងលើគឺ*ចំណេះវិជ្ជាជាទ្រព្យជាសម្បត្តិ នាំឱ្យជីវិតសុខសាន្ត*។

៥. អត្ថបទកាព្យខាងលើនេះមានតម្លៃអប់រំដូចតទៅ៖

-អប់រំឱ្យយើងចេះស្រឡាញ់វិជ្ជា ស្វែងរកវិជ្ជាមកទុកក្នុងខ្លួន ដើម្បីបំភ្លឺនូវជីវិត មានកេរ្តិ៍ឈ្មោះសុសសាយ។

-ត្រូវឧស្សាហ៍ព្យាយាមរៀនសូត្រ ហើយយកទៅប្រើការឱ្យបានសមស្រប។

-កូនចៅត្រូវតែយកច្បាប់នេះទុកជាទ្រព្យសម្រាប់អប់រំផ្លូវចិត្ត។

# វេយ្យាករណ៍ អំពីឈ្មោះផ្សំ

## លំហាត់

១. ដូចម្ដេចដែលហៅថាឈ្មោះផ្សំ?

២. តើឈ្មោះផ្សំមានធាតុសំណង់សំខាន់ៗអ្វីខ្លះ?

៣. ចូរគូសគំនូសតាងឈ្មោះជាមែកធាង និងជាប្រអប់ដូចខាងក្រោម៖

- ជារាសង្ឃឹមថា គេនឹងប្រឡងជាប់នៅឆ្នាំនេះ។
- យើងគោរពលោកគ្រូ អ្នកគ្រូ ដែលប្រៀបដូចឪពុកម្ដាយទី២របស់យើង។
- ប្រជាពលរដ្ឋយើងខិតខំធ្វើការ ដើម្បីប្រទេសជាតិរីកចម្រើន។

## ចម្លើយ

១. ដែលហៅថាឈ្មោះផ្សំគឺជា *ឈ្មោះដែលកើតឡើងពីការពង្រីកឈ្មោះទោលដែលមានធាតុសំណង់ណាមួយនៃឈ្មោះ ជាឃ្លា ឬជាឈ្មោះសម្រាប់ពង្រីកឈ្មោះដើម។*

២. ឈ្មោះផ្សំមានធាតុសំណង់សំខាន់ៗពីរគឺ *ឃ្លាច្បង និងឃ្លារណប ដែលឃ្លារណបជាឃ្លានាម ឃ្លាគុណនាម និងឃ្លាទេសកាល។*

៣. គូសគំនូសតាងឈ្មោះជាមែកធាង និងជាប្រអប់ដូចខាងក្រោម

- ជារាសង្ឃឹមថា គេនឹងប្រឡងជាប់នៅឆ្នាំនេះ។


ល
កន
កកិ
កមធ
ន
កិ
ឈ
យ
ជារា សង្ឃឹម ថា គេនឹងប្រឡងជាប់នៅឆ្នាំនេះ


ល
កន
កកិ
ជារា
សង្ឃឹម
ថា
គេនឹងប្រឡងជាប់នៅឆ្នាំនេះ
ន
កិ
ឈ
យ(ន.)


ល
កន
កកិ
កិ
កន
ស
កន
យ(គុ)
យើង គោរព លោកគ្រូអ្នកគ្រូ ដែលប្រៀបដូចឪពុកម្តាយទី២ របស់យើង


ល
កន
កកិ
យើង
គោរព
លោកគ្រូអ្នកគ្រូ
ដែលប្រៀបដូចឪពុកម្តាយទី២ របស់យើង
ន
កិ
កន
យ(គុ)


ល
កន
កកិ
កិ
ន
កមធ(ឈ)
ឈ
យ
ប្រជាពលរដ្ឋយើង ខិតខំធ្វើ ការ ដើម្បី ប្រទេសជាតិរីកចម្រើន


ល
កន
កកិ
ល
ប្រជាពលរដ្ឋយើង
ខិតខំធ្វើ
ការ
ដើម្បី
ប្រទេសជាតិរីកចម្រើន
កិ
ន
កមធ
យ

# អំណាន ជ័យជំនះរបស់លោកគូប៊ែតាំង

## សំណួរ

១. តើអត្ថបទនេះនិយាយអំពីអ្វី?
២. តើហេតុអ្វីបានជាលោកគូប៊ែតាំងចង់ឱ្យយុវជនក្នុងពិភពលោកធ្វើកីឡា?
៣. តើលោកគូប៊ែតាំងបានបង្កើតល្បែងកីឡាតាំងពីពេលណាមក?
៤. តើលោកគូបែតាំងបានសម្រេចជោគជ័យក្នុងការបង្កើតល្បែងកីឡាអូឡាំពិកយ៉ាងដូចម្ដេចខ្លះ?
៥. តើអត្ថបទនេះមានតម្លៃអប់រំដូចម្ដេចខ្លះ?
៦. ចូរបង្ហាញមូលន័យនៃអត្ថបទ?
៧. ចូរស្រង់ល្បះផ្សំដែលមានក្នុងអត្ថបទឱ្យបាន ១ឬ២ល្បះ។

## ចម្លើយ

១. អត្ថបទនេះនិយាយអំពី *លោកគូប៊ែតាំងជាអ្នកផ្ដល់កំណើតទី២ដល់កីឡាអូឡាំពិចឱ្យមានជីវិតឡើងវិញបន្តរហូតដល់បច្ចុប្បន្ន។*
២. បានជាលោកគូប៊ែតាំងចង់ឱ្យយុវជនក្នុងពិភពលោកធ្វើកីឡាព្រោះ៖

-ចង់ផ្ដល់ជីវិតកីឡានេះឱ្យរស់ឡើងវិញ
-ចង់អប់រំកាយដល់យុវជនឱ្យមានសុខភាពល្អ
-បង្កើតភាពស្និទ្ធស្នាលដល់យុវជននៅលើពិភពលោក

៣. លោកគូប៉ែតាំងបានបង្កើតល្បែងកីឡាតាំងពីឆ្នាំ១៨៩៤។
៤. លោកគូប៉ែតាំងបានសម្រេចជោគជ័យ ក្នុងការបង្កើតល្បែងកីឡាអូឡាំពិកដូចជា៖

-ឆ្នាំ១៨៩៤លោកបានប្រមូលអ្នកតំណាងបាន១៤ប្រទេសឱ្យចូលរួមសមាជដើម្បី រៀបចំល្បែងអូឡាំពិចនិងសម្រេចបំណងដ៏ស្រួចស្រាលរបស់គាត់។

-ឆ្នាំ១៨៩៦អវត្តមានប្រទេសក្រិច ដូចនេះសល់១៣ប្រទេសបានចុះឈ្មោះហើយអត្តពលករមាន២៨៥នាក់ចូលរួមប្រកួតក្នុងវិញ្ញាសាកីឡា៩។ តែក្រោយៗមកទៀតនៅឆ្នាំ១៨៦៤នៅតូក្យូ និងឆ្នាំ១៩៦៨នៅម៉ិចសិច កីឡានេះបានទទួលជោគជ័យយ៉ាងខ្លាំង។

៥. អត្ថបទនេះមានតម្លៃអប់រំដូចជា ៖

-ឱ្យយើងចេះថែរក្សាសម្បត្តិពីបុរាណកាលទុកជាដំណែល

-អប់រំឱ្យមនុស្សចេះស្រឡាញ់សុខភាព ដូចនេះមានតែការអប់រំកាយតែប៉ុណ្ណោះដែលធ្វើឱ្យមានសុខភាពល្អ

-កីឡាគឺជាសិល្បៈមួយប្រភេទដែលបង្កើតសាមគ្គីភាព ភាតរភាព បំបាត់ជំលោះនៅក្នុងសង្គម ស្វែងរកសន្តិភាពជូនពិភពលោក។

៦. មូលន័យនៃអត្ថបទនេះគឺ *កីឡានាំមកនូវ សុខភាព ឯកភាព បំណិនប្រសប់ ភាតរភាព។*

៧. ស្រង់ល្បះផ្សំដែលមានក្នុងអត្ថបទឱ្យបាន ១ឬ២ល្បះ៖

-អ្នកតំណាង១៤ប្រទេសមកចូលរួមក្នុងសមាច *ដើម្បីរៀបចំល្បែងអុឡាំពិក*។

-លោកគូប៊ែតាំង *ដែលធ្វើឱ្យល្បែងអុឡាំពិចកើតឡើងវិញ*។

## បំណិន កំណាព្យបទបន្ទោលកាក

### លំហាត់

១. តើបទបន្ទោលកាក មានរង្វាស់កាព្យ ចំណាប់ចួន និងចង្វាក់ដូចម្តេច?

២. ចូរអានអត្ថបទកាព្យ ហើយឆ្លើយសំណួរដូចខាងក្រោម៖

ជុចថាអើម្ល៉េះ កម្លាំងប៉ុណ្ណេះទេណា
អ្នូតឯងបំពារ ទំលុះទម្លាយមិញតើ។
ត្រីថាម្ចាស់ថ្លៃ ពាក្យខ្ញុំនេះនែបញ្ចើ
ឥឡូវនេះតើ អ្នកមានឫទ្ធីក្រាស់ក្រៃ។
ជុចថាឫទ្ធី តេជះបារមីអ្វីនៃ
ឯងកុំចេះស្តី ចំអកចំអន់ឱ្យគ្នា។
ត្រីថាម្ចាស់ថ្លៃ អស់ពាក្យនេះនៃខ្ញុំថា
ជាល្បែងទៅណា អ្នកម្ចាស់កុំយកទោសឡើយ។
ជុចថាល្បែងៗ ឯងអ្នូតក្រេងស្រេចហើយ
ពិតកុំលង់ឡើយ ឯងស្ទុះបំពារតេជដៃ។
ត្រីថាខ្ញុំម្ចាស់ សេចក្តីខ្ញុំសមមែននៃ

អ្នកជុចម្ចាស់ថ្លៃ ម្ចាស់អើយលែងខ្ញុំទៅវ៉ា។

- តើអត្ថបទកាព្យខាងលើនេះនិយាយពីអ្វី?
- តើអត្ថបទកាព្យខាងលើនេះតែងឡើងជាបទអ្វី?
- ចូរគូសចំណាប់ចួន នៅវគ្គទី១និងទី២។

៣. ចូរតែងបទបន្ទោលកាក ទាក់ទងនិងភាពជោគជ័យឱ្យបានយ៉ាងតិច ៤វគ្គ។

## ចម្លើយ

១. បទបន្ទោលកាក មានរង្វាស់កាព្យ ចំណាប់ចួន និងចង្វាក់ដូចតទៅ៖

**ក.រង្វាស់កាព្យ**

-ក្នុង១វគ្គ មាន៤ឃ្លា។ ឃ្លាទី១ មាន៤ព្យាង្គ។ ឃ្លាទី២ មាន៦ព្យាង្គ។ ឃ្លាទី៣ មាន៤ព្យាង្គ។ ឃ្លាទី៤ មាន៦ព្យាង្គ។

**ខ.ចំណាប់ចួន**

-ព្យាង្គទី ៤នៃឃ្លាទី១ ចួននឹងព្យាង្គទី៤ នៃឃ្លាទី២គ្រប់ៗវគ្គ

-ព្យាង្គទី ៦នៃឃ្លាទី២ ចួននឹងព្យាង្គទី ៤នៃឃ្លាទី៣ ហើយចួននឹងព្យាង្គទី២ ឬព្យាង្គទី ៤នៃឃ្លាទី៤

-ព្យាង្គទី ៦នៃឃ្លាទី៤ ចួននឹងព្យាង្គទី ៦នៃឃ្លាទី២ ហើយចួននឹងព្យាង្គទី៤នៃឃ្លាទី៣ចួននឹងព្យាង្គទី២ឬទី៤នៃឃ្លាទី៤នៃវគ្គទី២។

*+គំនូសតាង*

១២៣៤ ១២៣៤៥៦

១២៣៤ ១២៣៤៥៦។(វគ្គទី១)

១២៣៤ ១២៣៤៥៦

១២៣៤ ១២៣៤៥៦។(វគ្គទី២)

*+សញ្ញាចាប់ចុងចួន*

-ព្យាង្គទី៤ នៃឃ្លាទី១ ⟝ ព្យាង្គទី៤ នៃឃ្លាទី២ គ្រប់វគ្គ

-ព្យាង្គទី៦ នៃឃ្លាទី២ ⟝ ព្យាង្គទី៤ នៃឃ្លាទី៣ ⟝ ព្យាង្គទី២ឬទី៤ នៃឃ្លាទី៤

-ព្យាង្គទី៦ នៃឃ្លាទី៤វគ្គទី១ ⟝ ព្យាង្គទី៦នៃឃ្លាទី២⟝ព្យាង្គទី៤ នៃឃ្លាទី៣ ⟝ ព្យាង្គទី២ឬទី៤ នៃវគ្គទី២ ឬវគ្គបន្ត។

**គ.ចង្វាក់**

បទបន្ទោលកាក ត្រូវសូត្រ និងមានការសង្កត់សំឡេងត្រង់ :

-ឃ្លាទី១និងឃ្លាទី៣ : ត្រូវសង្កត់សំឡេងលើព្យាង្គទី២

-ឃ្លាទី២ និងឃ្លាទី៤ : ត្រូវសង្កត់សំឡេង លើព្យាង្គទី២ និងទី៤

**២.អត្ថបទកាព្យ**

-អត្ថបទកាព្យខាងលើនេះនិយាយពី : *ការសន្ទនារវាងជុចនិងត្រីអួតពីកម្លាំងតែរៀងៗខ្លួន តែចុងបញ្ចប់ត្រីបរាជ័យ។*

-អត្ថបទកាព្យខាងលើនេះតែងឡើងជាបទ ***បន្ទោលកាក។***

-គូសចំណាប់ចួន នៅវគ្គទី១និងទី២៖

ដុចថាអើម្លេះ កម្លាំងប៉ុណ្ណេះទេណា
អ្នកឯងបំពារ ទំលុះទម្លាយមិញតើ។
ត្រីថាម្ចាស់ថ្លៃ ពាក្យខ្ញុំនេះនៃបញ្ញើ
ឥឡូវនេះតើ អ្នកមានឫទ្ធីក្រាស់ក្រៃ។

៣. ចូរតែងបទបន្ទោលកាក ទាក់ទងនិងភាពជោគជ័យឱ្យបាន យ៉ាងតិច ៤វគ្គ៖

*សំណាងណាស់បុត្រ មិនបាច់គក់ស្លុតទៅច្បាំង*
*ខ្មែរយើងពិតខ្លាំង ដេញខ្មាំងចេញពីបព៌ត។*
*រឿងព្រះវិហារ ខ្មែរយើងចាំជាប្រវត្តិ*
*ទន្ទេញចាំមាត់ មិនភ្លាត់ថាខ្មែរឈ្នះថៃ។*
*មហាជ័យជោគ ដែលខ្មែរបានមកដល់ដៃ*
*ក្សត្រខ្មែរថ្លាថ្លៃ មាត់ប្រែនៅឆ្នាំ៦២។*
*ឆ្នាំ២០០៨ ជម្លោះព្រំដីវក់វី*
*ការចុះបញ្ជី ព្រះវិហារ(១)ក៏ខ្មែរបានជ័យ។*

# អំណាន កាព្យផ្តោះផ្តង

## សំណួរ

១. តើអត្ថបទកាព្យនេះតែងឡើងជាបទអ្វី? និពន្ធដោយនរណា?
២. តើអត្ថបទកាព្យខាងលើនេះនិយាយឆ្លើយឆ្លងគ្នាពីអ្វី?
៣. តើអត្ថន័យនៃកំណាព្យខាងលើមានន័យដូចម្ដេច?
៤. ចូរបង្ហាញពីចំណាប់ចុងចួននិងវង្វាស់កាព្យក្នុងវគ្គទី១និងទី២។
៥. តើចង្វាក់និងការលើកដាក់សំឡេងក្នុងអត្ថបទកាព្យខាងលើស្ថិតនៅត្រង់ណា? ចូរបង្ហាញ។
៦. ចូររកតម្លៃអប់រំក្នុងអត្ថបទកាព្យខាងលើ។

## ចម្លើយ

១. អត្ថបទកាព្យនេះតែងឡើងជាបទ *បន្ទោលកាក*។ និពន្ធដោយលោក *ម៉ុក សំឌិក*។

២. អត្ថបទកាព្យខាងលើនេះនិយាយឆ្លើយឆ្លងគ្នាអំពី *កិច្ចការរបស់ពួកគេទាំងពីរ* ពោលគឺ *កិច្ចការរាជការ និង កិច្ចការជាកសិករគឺសុទ្ធតែល្អ កាលណារួមគ្នាទៅនឹងរីកចម្រើន*។

៣. អត្ថន័យនៃកំណាព្យខាងលើមានន័យ *កិច្ចការអ្វីក៏ដោយគឺសុទ្ធតែមានតម្លៃ កាលណាយើងព្យាយាមទៅ វាធ្វើអោយយើងរស់នៅស្រួលដូចតែគ្នា មិនថាជាការងាររាជការ ឬជាកសិករនោះទេ កុំឱ្យតែការងារនោះ ជាការខុសច្បាប់*។

៤.ចំណាប់ចុងចួននិងរង្វាស់កាព្យក្នុងវគ្គទី១និងទី២៖

**ខ.ចំណាប់ចួន**

-ព្យាង្គទី ៤នៃឃ្លាទី១ ចួននឹងព្យាង្គទី៤ នៃឃ្លាទី២វគ្គទី១។

-ព្យាង្គទី ៦នៃឃ្លាទី២ ចួននឹងព្យាង្គទី ៤នៃឃ្លាទី៣ ហើយចួននឹងព្យាង្គទី២នៃឃ្លាទី៤វគ្គទី១។

-ព្យាង្គទី ៤នៃឃ្លាទី១ ចួននឹងព្យាង្គទី៤ នៃឃ្លាទី២វគ្គទី២។

-ព្យាង្គទី ៦នៃឃ្លាទី៤វគ្គទី១ ចួននឹងព្យាង្គទី ៦នៃឃ្លាទី២ ហើយចួននឹងព្យាង្គទី៤នៃឃ្លាទី៣នៃវគ្គទី ២។

*+គំនូសតាង*

១២៣៤ ១២៣៤៥៦
១២៣៤ ១២៣៤៥៦។(វគ្គទី១)
១២៣៤ ១២៣៤៥៦
១២៣៤ ១២៣៤៥៦។(វគ្គទី២)

*+សញ្ញាចាប់ចុងចួន*

-ព្យាង្គទី៤ នៃឃ្លាទី១ ⟷ ព្យាង្គទី៤ នៃឃ្លាទី២វគ្គ១

-ព្យាង្គទី៦ នៃឃ្លាទី២ ⟷ ព្យាង្គទី៤ នៃឃ្លាទី៣ ⟷ ព្យាង្គទី២នៃឃ្លាទី៤

-ព្យាង្គទី៦ នៃឃ្លាទី៤វគ្គទី១ ⟷ ព្យាង្គទី៦នៃឃ្លាទី២⟷ព្យាង្គទី៤ នៃឃ្លាទី៣ ⟷ ព្យាង្គទី២នៃវគ្គទី២ ឬវគ្គបន្ត។

៥. ចង្វាក់និងការលើកដាក់សំឡេងក្នុងអត្ថបទកាព្យខាងលើ៖

-ឃ្លាទី១និងឃ្លាទី៣ : ត្រូវសង្កត់សំឡេងលើព្យាង្គទី២

-ឃ្លាទី២ និងឃ្លាទី៤ : ត្រូវសង្កត់សំឡេង លើព្យាង្គទី២ និងទី៤

៦.តម្លៃអប់រំក្នុងអត្ថបទកាព្យ៖

-មនុស្សមិនត្រូវប្រកាន់ការងារ រើសអើងការងារនោះទេ

-អប់រំឱ្យស្រឡាញ់ការងារជាកសិករ

-អប់រំឱ្យចេះសាមគ្គីគ្នារវាងអ្នកធ្វើការទាំងឡាយដើម្បីអភិវឌ្ឍប្រទេសឱ្យរីកចម្រើន។

# ការស្ដាប់ ល្បើក ជុច និងត្រី

## សំណួរ

១. តើអត្ថបទនេះដកស្រង់ពីណា? សូត្រជាបទអ្វី? អ្នកណាជាអ្នកនិពន្ធ?

២. តើអត្ថន័យនៃបទកំណាព្យនិយាយពីអ្វី?

៣. តើទង្វើរបស់ជុច និងត្រីជាទង្វើដូចម្ដេច?

៤. តើត្រីជាតួអង្គដូចម្ដេច? ជុចជាតួអង្គដូចម្ដេច?

៥. ចូរបង្ហាញគំនិតសំខាន់បង្កប់និងគំនិតសំខាន់បង្ហាញត្រង់ក្នុងអត្ថបទកាព្យខាងលើ?

៦. តើអត្ថបទកាព្យដកស្រង់ខាងលើនេះមានតម្លៃអប់រំអ្វីខ្លះ?

ការនិយាយ ការសូត្រកំណាព្យ

សំណេរ អត្ថបទកំណាព្យបទភុជង្គលីលានិងបទ

បន្ទោលកាក

## លំហាត់

ចូរប្អូនជ្រើសរើសប្រធានបទណាមួយក៏បានមកតាក់តែងជាបទភុជង្គលីលា ឬបទកាកគតិតាមការពេញចិត្ត។

## ចម្លើយ

### ការព្យាយាម (បទកាកគតិ)

ទឹកភ្នំហូរស្រក់ សម្លេងតក់ៗ ទម្លុះថ្មដា
កណ្ដាបកណ្ដៀរ ស្រមោចសង្ការ សុទ្ធសឹងឧស្សាហ៍
ក្នុងការជីវិត។

កូនរកវិជ្ជា ទុកដាក់ជាគ្នា សាងសង់គំនិត
ពីតិចទៅច្រើន ពេញមួយជីវិត រឿងឆ្ងាយបែរជិត
ងងឹតបែរភ្លឺ។

# មេរៀនទី១០ ពលរដ្ឋល្អ

## បំណិន ប្រលោមលោកទំនើប

### សំណួរ

១. ដូចម្ដេចហៅថា ប្រលោមលោកទំនើប? តើរឿងប្រលោមលោកទំនើបបានចាប់ផ្ដើមពីពេលណា?

២. តើរឿងប្រលោមលោកទំនើប មានធាតុសំខាន់ៗអ្វីខ្លះ?

### ចម្លើយ

១.ប្រលោមលោកទំនើបគឺជា អក្សរសិល្ប៍ដែលកើតឡើងនៅក្នុងសម័យថ្មី វាផ្ដាច់ខ្លួនចេញពីលទ្ធិរបស់សាសនាហើយឈានទៅរកសច្ចភាពក្នុងសង្គម មាននិន្នាការជាតិនិយម និងមនោគមវិជ្ជាជាដើម ដែលវាមានលក្ខណៈជឿនលឿន តាមបែបវិទ្យាសាស្ត្រ។

រឿងប្រលោមលោកទំនើបបានចាប់ផ្ដើមចាប់តាំងពីក្រោយសង្គ្រាមលើកទី២មកម្ល៉េះ។

២. រឿងប្រលោមលោកទំនើប មានធាតុសំខាន់ៗដូចជា៖

**អ្នកនិពន្ធប្រើសិល្បវិធីតែងដូចជា :**

**ក. ផ្នែកអត្ថន័យ** : ដែលជាបញ្ហាចោទ ហើយនិងដំណោះស្រាយ។

ខ. ផ្នែកអត្ថរូប ៖

- អារម្ភកថា

-សេចក្ដីផ្ដើម

-តួរឿង ឬដំណើររឿងដែលអ្នកនិពន្ធប្រើវិធីផ្សេងៗ ដូចជា វចនវិធី សន្ទេហវិធី។

-បញ្ចប់រឿង អ្នកនិពន្ធបញ្ចប់ប្លែកៗពីគ្នា។

គ. ផ្នែកអត្ថរស ៖ ដែលមានបញ្ចោករស វិសេសរស និងសព្វរស

## លំហាត់

១. ក្នុងចំណោមរឿងខាងក្រោម តើរឿងណាខ្លះជាប្រលោមលោកទំនើប?

- រឿងផ្កាស្រពោន
- រឿងថៅកែចិត្តចោរ
- រឿងស្មានិងទីទុយនិងអណ្ដើក
- រឿងកុលាបប៉ៃលិន
- រឿងទីក្រុងភ្នំពេញ
- រឿងប្រាសាទតាព្រហ្ម
- រឿងសូផាត
- រឿងស៊ឹមបរឡាន
- រឿងចចក

- រឿងប្រាសាទភ្នំបាយ៉ង់កោរ
- រឿងតេជោយ៉ត
- រឿងសង្គ្រាមរវាងគីង្គក់និងតាព្រហ្ម។

២. ចូរអ្នករករឿងប្រលោមលោកទំនើបខ្មែរនិងបរទេសឱ្យបានយ៉ាងតិចពីររឿង រួចបង្ហាញមូលហេតុដែលអ្នកចាត់ទុករឿងទាំងនោះជាប្រលោមលោកទំនើប។

## ចម្លើយ

១. ក្នុងចំណោមរឿងខាងក្រោម រឿងជាប្រលោមលោកទំនើបមាន
- រឿងផ្កាស្រពោន
- រឿងថៅកែចិត្តចោរ
- រឿងកុលាបប៉ៃលិន
- រឿងសូផាត
- រឿងស៊ឹមបរទ្បាន

២.រឿងប្រលោមលោកទំនើបខ្មែរ៖

**អត្ថន័យ**

**ក.ប្រធានរឿង** : និយាយពីការតស៊ូព្យាយាមរបស់កម្មករម្នាក់ចាប់ពីចំនុចសូន្យរហូតដល់បានក្លាយជា កូនប្រសាររបស់ថៅកែត្បូងពេជ្រ(***អត្តហិ អត្តនោ នាថោ***)។

**ខ.មូលបញ្ហា** :បញ្ហាក្រីក្រតែស្រលាញ់ចៅហ្វាយនាយស្រីដែលមានឋានៈ ខ្ពស់ជាងខ្លួន។

**គ.បញ្ហាទំនាស់** :ការប្រជែងគ្នាដណ្ដើមនាងយុននារីធ្វើជាម្ចាស់ បេះដូង។

**ឃ.តួអង្គទំនាស់** :យុននារី,ហ្លួងរតនៈសម្បត្តិ,ចៅចិត្រ ជាមួយលោកបាឡាត់,ចៅកែជាន់។

**ង.ដំណោះស្រាយ** : នាងយុននារីបានទៅចៅចិត្រលោបាឡាត់ និងចៅកែជាន់ស្លាប់។

**អត្ថរូប**

១.និពន្ធរូប :មានសេចក្ដីផ្ដើម តួសេចក្ដី និងសេចក្ដីបញ្ចប់តាមបែបប្រលោកលោកសម័ទំនើប ចលនាខេមរនិយម។

២.បច្ចេករូប

ក.ភេទរូប :ជាប្រលោមលោកទំនើប។

ខ.និទានរូប :និទានចែកជា៦វគ្គ :

-វគ្គទី១ :បណ្ដាំឪពុក

-វគ្គទី២ :ការធ្វើដំណើរទៅបប៉ៃលិន...

២.វចនាវិធី

ឧបមានវិធី : ជាវិធីដែលអ្នកនិពន្ធប្រើពាក្យទំហៀបន័យ។

ឧទាហរណ៍ : ...សំលេងស្រួយស្រស់ដូចស្វូរគាំប្រាក់។ ...មុខមូលក្រឡង់ដូចវង់ចន្ទ្រា...។

សំវាទវិធី : ការសន្ទនាគ្នារបស់តួអង្គ។ ឧទាហរណ៍ :

-នារី : ខ្ញុំគ្មានម៉ែទេចិត្រ។

-ចៅចិត្រ : អេះ! ចំឡែកដែរ បើឃុនគ្មានម្តាយ ចុះឃុនកើតមកម្តេចបាន?....

**អត្ថរស**

១.ប្រលោមរស :ជាស្នាដៃប្រលោមលោកបែបមនោសញ្ចេតនាធ្វើឲ្យអ្នកអានរំភើបញាប់ញ័រ កើតនូវការកំសត់ ឬសប្បាយព្រួយបាម្មណ៍ជាមួយនឹងតួអង្គមានលក្ខណៈអណ្តែតអណ្តូង ។ ជាក់ស្តែងដំណើរជីវិតចៅចិត្រមានការលំបាកវេទនា ទីបញ្ចប់សុខសាន្តព្រមទាំងបាននាងឃុន នារីជាគូជីវិត។

២.កុសល្យរស :ជាតំការអប់រំ។

ដំណើររឿងបានផ្តល់ជាតំលៃអប់រំដូចជា ឲ្យមនុស្សមានការតស៊ូក្នុងឆាកជីវិត។ ប្រាសចាកការលួចឆក់ប្លន់គេ។

៣.វីរសស :ជាតម្លៃដែលចេញពីតួអង្គវីរជន។....

# អំណាន ភ្នាក់រឭក

## សំណួរ

១. តើអត្ថបទនេះដកស្រង់ចេញពីរឿងអ្វី?និពន្ធនៅឆ្នាំណា? អ្នកនិពន្ធឈ្មោះអ្វី?

២. ចូរបង្ហាញកាលអាកាសនៃអត្ថបទខាងលើ?

៣. រឿងនេះជារឿងប្រភេទណា? ព្រោះអ្វី?

៤. ស៊ឹមបានឆ្លើយសំណួរពូសនថា ខ្ញុំមើល "ទំនៀមទម្លាប់និងច្បាប់ខ្មែរ"។ តាមចម្លើយនេះតើស៊ឹមជាពលរដ្ឋបែបណា?

៥. ចំណងជើងអត្ថបទគឺ "ភ្ញាក់រឭក"។ តើតួអង្គណាមួយដែលភ្ញាក់រឭក? ហេតុអ្វី?

៦. តើអ្នកនិពន្ធបានបញ្ចប់រឿងដោយវិធីណា?

៧. តើអត្ថបទនេះមានតម្លៃអប់រំដូចម្ដេចខ្លះ?

## ចម្លើយ

១. អត្ថបទនេះដកស្រង់ចេញពីរឿង "*ស៊ឹមអ្នកបរឡាន*"។និពន្ធនៅឆ្នាំ១៩៥៦-១៩៥៩។ អ្នកនិពន្ធឈ្មោះ " *លោក អ៊ឹម ធុក*"។

២. កាលអាកាសនៃអត្ថបទមាន៖

*-កាល* : ថ្ងៃរសៀលម៉ោង៣ ពេលដែលពូសនបើកឡានទៅដល់មន្ទីរ( ថ្ងៃនេះ ថ្ងៃសម្រាកអាទិត្យ ថ្ងៃក្រោយ។ )

*-អាកាស* ៖ មន្ទីរធ្វើការ(លើអាស៊ីបកញ្ចាស់ តែប ទឹកឈូ ផ្ទះស៊ីម ផ្ទះចៅហ្វាយ ផ្ទះតៀមចិន ។)

៣. រឿងនេះជារឿងអក្សរសិល្ប៍ទំនើបបែបខេមរនិយម។ ព្រោះវាកើតនៅក្រោយសង្គ្រាមលោកលើកទី២ វាផ្ដាច់ចេញពីឥទ្ធិពលសាសនា លើកនិងយកបញ្ហាមកចោទនិងដោះស្រាយតាមបែបទំនើប សង្កត់ធ្ងន់ទៅលើលទ្ធិប្រជាធិបតេយ្យ នេះជា*ផ្នែកអត្ថន័យ*។ ចំណែក*ផ្នែកអត្ថរូបវិ*ញអ្នកនិពន្ធបានប្រើសិល្ប៍វិធីផ្សេងៗដូចជា សំភាទវិធី ពណ៌នាវិធីជាដើម។ ចំពោះការ*បញ្ចប់រឿង*អ្នកនិពន្ធបង្កើតក្ដីសង្ឃឹមថ្មីទៅរកលទ្ធិប្រជាធិបតេ-យ្យ។ រីឯផ្នែកអត្ថរស សង្កត់ធ្ងន់ ទៅលើសង្គមរស និងមនុស្សរស នៃសម័យថ្មី។

៤. ស៊ីមបានឆ្លើយសំណួរពូសនថា ខ្ញុំមើល "ទំនៀមទម្លាប់និងច្បាប់ខ្មែរ"។ តាមចម្លើយនេះស៊ីមជាពលរដ្ឋដែលស្រឡាញ់ការសិក្សារៀនសូត្រទៅលើផ្នែកច្បាប់និងវប្បធម៌ ដើម្បីលើកតម្កើងលទ្ធិប្រជាធិបតេយ្យក្នុងប្រទេស។

៥. ចំណងជើងអត្ថបទគឺ "ភ្ញាក់រឭក"។ តួអង្គដែលភ្ញាក់រឭកគឺ*ពូសន* ព្រោះគាត់មិនដែលអានសៀវភៅកាសែត គាត់ត្រូវចៅហ្វាយនាយជិះជាន់ នៅពេលដែលជួបមិត្តដែលបើកឡានដូចគ្នាតែងបបួលគ្នាផឹកស៊ី តែនៅពេលដែលបានជួបស៊ីម គាត់បានដឹងខ្លួនឡើងចង់រៀនឱ្យចេះដឹងដូចស៊ីម។

៦. អ្នកនិពន្ធបានបញ្ចប់រឿងដោយផ្ដល់ពន្លឺលទ្ធិប្រជាធិបតេយ្យ ដែលមានដូចជា ស៊ីមថែមទាំងបានពន្យល់ពូសនឲ្យខិតខំអានសៀវភៅ មើលការសែតឲ្យបានច្រើន។ពូសនបានផ្លាស់ប្ដូរចរិតចាស់របស់គាត់ហើយបានខ្ចីសៀវភៅស៊ីមមកអាន។ ចំណែកឯស៊ីមនៅថ្ងៃឈប់សម្រាកស៊ីមមានពេលវេលាគ្រប់គ្រាន់ក្នុងការថែទាំគ្រួសារ។

៧. អត្ថបទនេះមានតម្លៃអប់រំដូចជា៖

-ឱ្យមនុស្សភ្ញាក់រឭក ខិតខំប្រឹងប្រែងរៀនសូត្រ យល់ដឹងពីលទ្ធិប្រជាធិបតេយ្យ ក្រោកឈរឡើងប្រឆាំងនឹងការជិះជាន់ដើម្បីអភិវឌ្ឍប្រទេសជាតិឱ្យបានរីកចម្រើន។

# វេយ្យាករណ៍ ល្បះក្រង

## លំហាត់

១. ចូរអ្នកអានល្បះខាងក្រោមដោយប្រាប់ថា តើល្បះនីមួយៗកើតឡើងដូចម្ដេច?

- គាត់មើលសិល្បះ ឬដើរកំសាន្តតាមមាត់ទន្លេ។

- វាខ្ជិលរៀនសូត្រ តែវាចង់បានការងារធ្វើ។

- អំពើល្អទទួលបានផលល្អ អំពើអាក្រក់ទទួលបានផលអាក្រក់។

- គ្រូពន្យល់មេរៀន សិស្សខ្លះស្តាប់ សិស្សខ្លះជជែកគ្នា សិស្សខ្លះខំកត់ត្រា។

២. ចូរអ្នកបង្កើតល្បះក្រុងពីរដោយប្រើឈ្នាប់ចងនិងល្បះក្រុងពីរទៀតដោយប្រើល្បះក្រុងដាក់បន្តគ្នា។

## ចម្លើយ

១. ល្បះនីមួយៗកើតឡើងដូច

- <u>គាត់មើលសិល្បះ</u> <u>*ឬ*</u> <u>ដើរកំសាន្តតាមមាត់ទន្លេ</u>។

*ល្បះរងទី១ ឈ្នាប់ចង ល្បះរងទី២*

*ល្បះក្រុងនេះកើតឡើងដោយល្បះរងទី១និងល្បះរងទី២ភ្ជាប់គ្នាដោយសារឈ្នាប់ចង "ឬ"។*

- <u>វាខ្ជិលរៀនសូត្រ</u> <u>តែ</u> <u>វាចង់បានការងារធ្វើ</u>។

*ល្បះរងទី១ ឈ្នាប់ចង ល្បះរងទី២*

*ល្បះក្រុងនេះកើតឡើងដោយល្បះរងទី១និងល្បះរងទី២ភ្ជាប់គ្នាដោយសារឈ្នាប់ចង "តែ"។*

<u>អំពើល្អទទួលបានផលល្អ</u> <u>អំពើអាក្រក់ទទួលបានផលអាក្រក់</u>

*ល្បះរងទី១ ល្បះរងទី២*

*ល្បះក្រុងនេះកើតឡើងពីល្បះរងទាំងពីរដាក់បន្តគ្នាដោយមិនប្រើឈ្នាប់ចង។*

- <u>គ្រូពន្យល់មេរៀន</u> <u>សិស្សខ្លះស្តាប់</u> <u>សិស្សខ្លះជជែកគ្នា</u>

*ល្បះរងទី១ ល្បះរងទី២ ល្បះរងទី៣*

. <u>សិស្សខ្លះខំកត់ត្រា។</u>

*ល្បះរងទី៤*

*ល្បះក្រុងនេះកើតឡើងដោយសារដំណាក់ឃ្លារាំងល្បះរង ទាំង៤ដាក់បន្តគ្នាដោយមិនប្រើចំណងឈ្នាប់ឡើយ។*

២. បង្កើតល្បះក្រុងពីរដោយប្រើឈ្នាប់ចងនិងល្បះក្រុងពីរទៀត ដោយប្រើល្បះក្រុងដាក់បន្តគ្នាគឺ៖

- វាចង់បានការងារខ្ពស់ *តែ* វាមិនខិតខំរៀនសូត្រ។

- កូនល្អខិតខំប្រឹងប្រែងរៀនសូត្រ *និង* យកចិត្តទុកដាក់ស្តាប់គ្រូពន្យល់។

-មនុស្សធ្វើល្អបានល្អ មនុស្សធ្វើអាក្រក់បានអាក្រក់។

-មាសលុតដោយភ្លើង មនុស្សលុតដោយឧបសគ្គ។

# អំណាន មហាចោរនៅទល់ដែន

## សំណួរ

១. តើអត្ថបទនេះដកស្រង់ចេញពីរឿងណា? និពន្ធនៅឆ្នាំណា? ស្ថិតក្នុងសង្គមបរិយាកាសដូចម្តេច?

២. តើតួអង្គណាដែលត្រូវនឹងចំណងជើងអត្ថបទ? តួអង្គនោះជាមនុស្សដូចម្តេច? ចូររកភស្តុតាងបញ្ជាក់។

៣. ហេតុអ្វីបានជានាយអគ្គីពេញចិត្ត នឹងស្លាប់នៅចំពោះមុខសត្រូវ?

៤. តាមរយៈសំដីនាយអគ្គីថា កូនក្រមុំមេកងខាងខ្មាំងមកដើលេង គាត់។ តើខ្មាំងនោះជាពួកអ្នកណា? តើនាងធ្វើបែបនេះ ត្រឹមត្រូវដែរ ឬទេ? ព្រោះអ្វី?

៥. រឿងនេះជារឿងប្រភេទណា? ព្រោះអ្វី?

៦. ក្នុងនាមជាពលរដ្ឋម្នាក់ ប្រសិនបើជួបអំពើរំលោភឈ្លានពានពីសំណាក់សត្រូវមកលើសង្គម តើអ្នកមានគំនិតដោះស្រាយបែបណា?

## ចម្លើយ

១. អត្ថបទនេះដកស្រង់ចេញពីរឿង*មហាចោរទល់ដែន*។ និពន្ធនៅឆ្នាំ១៩៥៥។ ស្ថិតក្នុងសង្គមបរិយាកាសមួយដែលមានការឈ្លានពានពី សៀម ប្រទេសកើតអសន្តិសុខដោយសារមានការឈ្លានពានពីថៃ មានចោរកម្ម កើតឡើងនៅតាមព្រំដែនជាដើម។

២. តួអង្គដែលត្រូវនឹងចំណងជើងអត្ថបទគឺ***តួអង្គមានឡា***។ តួអង្គនោះជាមនុស្សដែលគិតប្រយោជន៍ជាតិ ស្នេហាជាតិ ស្រឡាញ់ទឹកដី ជាតិនិយម ។ អំណះអំណាងគឺគាត់បានក្បត់ឪពុកត្រូវគេចោទជាចោរព្រោះតែចង់ការពារទឹកដីខ្មែរ។ កាត់បានចាប់ដៃនាយអគ្គីយ៉ាងខ្លាំងជាសញ្ញាប្តូរជីវិតជាមួយគ្នា។ បុរសបន្តទៅទៀតដូចតទៅ **"ទុច្ចយើងជាទុច្ចខ្មែរទាំងអស់គ្នា"**...។

៣. បានជានាយអគ្គីពេញចិត្តនឹងស្លាប់នៅចំពោះមុខសត្រូវព្រោះអគ្គីជាមនុស្សស្នេហាជាតិមាតុភូមិនិងជនជាតិខ្មែរពិតៗ។

៤. តាមរយៈសំដីនាយអគ្គីថា កូនក្រមុំមេកងខាងខ្មាំងមកដោះលែងគាត់។ ខ្មាំងនោះជាពួកថៃនិងខ្មែរអាយ៉ងថៃ នាងធ្វើបែបនេះត្រឹមត្រូវណាស់ ព្រោះនាងក៏ជាខ្មែរ ការដោះលែងខ្មែរគ្នាឯងដើម្បីឱ្យគេបន្តការទាមទារទឹកដីរបស់ពួកគេគឺពិតជាត្រឹមត្រូវ។

៥. រឿងនេះជារឿងប្រភេទប្រលោមលោកទំនើបបែបប្រវត្តិសាស្ត្រ ព្រោះរឿងនេះនិពន្ធឡើងក្រោយសង្គ្រាមលោកលើកទី២ សាច់រឿងផ្ដោតចេញពីបញ្ហាមនុស្សនៅក្នុងសម័យថ្មី ដូចជាការតស៊ូ ការពារជាតិ មាតុភូមិជាដើម។

៦. ក្នុងនាមជាពលរដ្ឋម្នាក់ ប្រសិនបើជួបអំពើរំលោភឈ្លានពានពីសំណាក់សត្រូវមកលើសង្គម អ្នកមានគំនិតដោះស្រាយដោយវិធី

-ប្រើកម្លាំងនៃការចរចារទ្វេរភាគី

-ការចរចារដោយមានប្រទេសផ្សេងទៀតជាសក្ខីភាព

-អាចប្ដឹងទៅឱ្យតុលាការអន្តរជាតិដោះស្រាយ ឬទៅឱ្យប្រទេសមហាអំណាចអព្យាក្រឹត្យណាមួយជួយដោះស្រាយ

-បញ្ជូនកម្លាំងយោធា។

## អំណាន ភារកិច្ចរបស់ពលរដ្ឋចំពោះមាតុភូមិ

### សំណួរ

១. តើអត្ថបទនេះជាប្រភេទអត្ថបទបែបណា?

២. តើអត្ថបទនេះមានអត្ថន័យយ៉ាងដូចម្ដេច? ចូរពន្យល់។

៣. តើការស្គាល់ភារកិច្ចរបស់ខ្លួនចំពោះមាតុភូមិជាឧត្ដមភាពមួយដ៏ប្រសើរឬទេ? ព្រោះអ្វី?

៤. ចូររកគំនិតឬទស្សនៈរបស់អ្នកនិពន្ធ។

៥. ចូរអ្នករកល្បះ ជាទម្រង់ល្បះក្រងឱ្យបានពីរ ដែលប្រើឈ្នាប់ចង និងល្បះបន្តក្នុងអត្ថបទខាងលើ។

៦. ចំពោះអ្នកវិញ តើអ្នកមានបំណងធ្វើអ្វីខ្លះដើម្បីឱ្យមានប្រយោជន៍ដល់ប្រទេសជាតិ?

### ចម្លើយ

១. អត្ថបទនេះជាប្រភេទអត្ថបទពាក្យរាយធម្មតា ឬជាសារកថា។

២. អត្ថបទនេះមានអត្ថន័យថា *ភាតព្វកិច្ចរបស់ពលរដ្ឋម្នាក់ៗដែលត្រូវបំពេញ ដើម្បីជាតិមាតុភូមិ ដូចជាតួនាទីរបស់សង្ឃជួយអប់រំលើកតម្កើងសាសនា ។ អាជីវករត្រូវមានភាពស្មោះត្រង់។ កុលបុត្រត្រូវខំរៀនសូត្រជាដើម។*

៣. ការស្គាល់ភារកិច្ចរបស់ខ្លួនចំពោះមាតុភូមិជាឧត្ដមភាពមួយដ៏ប្រសើរ ព្រោះការកើតនៅក្នុងទឹកដីណា ហូបបាយនៅទីណា

គឺត្រូវតែបម្រើនៅទីនោះ ត្រូវតែដឹងគុណ ពីប្រភពដែលផ្តល់កំណើត និងពីប្រភពកន្លែងបន្ទោរបង់ និងទីជំរកដ៏សុខសាន្ត។

៥. គំនិត ឬទស្សនៈរបស់អ្នកនិពន្ធគឺ *ប្រជាជនគ្រប់រូបគ្រប់ស្រទាប់វណ្ណៈ គ្រប់ជាតិសាសន៍ត្រូវតែមានកាតព្វកិច្ចមួយបូជាដើម្បីជាតិមាតុភូមិ។*

៥. ទម្រង់ល្បះក្រងឱ្យបានពីរ ដែលប្រើឈ្នាប់ចងនិងល្បះបន្តក្នុងអត្ថបទខាងលើគឺ៖

- អ្នកមិនត្រូវផលិតទំនិញខ្វះអនាម័យ ខ្វះគុណភាព ***និង***មិនត្រូវគេចវេះពីការបង់ពន្ធជូនរដ្ឋឡើយ។

-អ្នកត្រូវនាំគ្នាទៅសាលារៀន ស្តាប់ការទូន្មានរបស់គ្រូបាធ្យាយរៀនឱ្យពូកែដើម្បីសមជា(ទំពាំងស្នងឫស្សី)។

៦. អាស្រ័យលើសិស្ស។

## ការនិយាយ ការសម្ភាសតួសម្តែងក្នុងរឿងមហាចោរនៅចល់ដែន

### សំណួរ

១. តើអ្នកដែលត្រូវគេសម្ភាសតំណាងឱ្យតួអង្គណា?

២. តើសុខរីបានប្រើពាក្យសំដីបែបណាខ្លះទាក់ទងនឹងការសម្ភាសតួអង្គ? ចូរលើកឃ្លានោះមកបញ្ជាក់។

៣. តើល្បះ ឬឃ្លាត្រង់ណាដែលបង្ហាញថា អ្នកត្រូវគេសម្លាសដែលជាមនុស្សមានការទទួលខុសត្រូវខ្ពស់?

៤. តើអ្នកយល់យ៉ាងណាចំពោះទស្សនៈរបស់អ្នកត្រូវគេសម្លាសដែលបានបង្ហាញនៅកថាខណ្ឌចុងក្រោយ?

**ចម្លើយ**

១. អ្នកដែលត្រូវគេសម្លាសតំណាងឱ្យតួអង្គ ***មានទ្ធ***។

២. សុខរីបានប្រើពាក្យសំដីខ្លះទាក់ទងនឹងការសម្លាសមានដូចជា *ជំរាបសួរ...។ សូមទោស.....។ ចាស អរគុណ! ...។ អរគុណលោក...។ សូមទោស!....។ ក្នុងនាមមិត្តស្លាប់ សូមអរគុណលោកជានីម្តងទៀត*។

៣. ល្បះ ឬឃ្លាដែលបង្ហាញថា អ្នកត្រូវគេសម្លាសដែលជាមនុស្សមានការទទួលខុសត្រូវខ្ពស់គឺ៖

- *សកម្មភាពតួអង្គបានជំរុញទឹកចិត្ត កាយវាចាររបស់ខ្ញុំឱ្យមានឆន្ទៈមុតមាំ ទើបពេលសម្តែងពុំសូវមានការខុសឆ្គងឡើយ*។

៤. ចំពោះទស្សនៈរបស់អ្នកត្រូវគេសម្លាសដែលបានបង្ហាញនៅកថាខណ្ឌចុងក្រោយខ្ញុំយល់ថា *មនុស្សនេះពិតជាមានសីលធម៌ខ្ពស់ យកចិត្តទុកដាក់ខ្លាំងទៅលើវិស័យវប្បធម៌សិល្បៈ*។

## សំណោរ សំបុត្របែបប្រឌិត

### សំណួរ

១. តាមរយៈខ្លឹមសារសំបុត្រនេះ នាងទេវីជាតួអង្គបែបណា?

២: តើនាងទេវីមានទុក្ខដោយសារអ្វី? ទុក្ខរបស់មានន្ទគឺអ្វី?ចូរពន្យល់?

៣. ចូរបង្ហាញអារម្មណ៍តួអង្គមានន្ទពេលអានុ និងក្រោយពេលអានលិខិតនេះ។

៤. ចូរបង្ហាញពីទម្រង់សំបុត្រខាងលើនេះ(ក្បាលសំបុត្រ តួសំបុត្របញ្ចប់សំបុត្រ)។

### ចម្លើយ

១. តាមរយៈខ្លឹមសារសំបុត្រនេះ នាងទេវីជាតួអង្គដែលស្មោះស្ម័គ្រចំពោះស្នេហា។

២. នាងទេវីមានទុក្ខដោយសារស្នេហាត្រូវគេចោទប្រកាន់ថាក្បត់នឹងស្វាមី ទុក្ខដោយសារព្រាត់ប្រាស់ប្តីជាទីស្រឡាញ់។ទុក្ខរបស់មានន្ទគឺព្រោះស្នេហាដែរ ព្រោះខឹងប្រពន្ធដែលផិតក្បត់នឹងខ្លួនត្រូវព្រាត់ប្រាស់ពីប្រពន្ធនិងកូន ទំរាំដឹងការពិតប្រពន្ធត្រូវស្លាប់ចោលទៀត។

៣. បង្ហាញអារម្មណ៍តួអង្គមានន្ទពេលអាន និងក្រោយពេលអានលិខិតនេះគឺ *ពេលកំពុងអានលិខិតនេះមានន្ទមានវប្បដិសារី*

*អាណិតអាសូរទៅដល់ប្រពន្ធដែលស្លាប់ដោយសារខ្លួនឥតទីពុត។ តែនៅពេលក្រោយអានសំបុត្រចប់មាននូវខ្លោចផ្សាយក្នុងចិត្តអស់ទីពឹងនឹងអស់ក្តីសង្ឃឹម ហើយស្អប់ខ្លួនឯងមិនអាចលើកលែងឱ្យបាន។*

៤. ទម្រង់សំបុត្រខាងលើនេះ(ក្បាលសំបុត្រ តួសំបុត្រ បញ្ចប់សំបុត្រ)

-ក្បាលសំបុត្រ ផ្តើម ចុះកាលបរិច្ឆេទ មានទីកន្លែង បន្ទាប់មកគឺចំណងជើង។

-តួសំបុត្រ គេចែកចេញជាផ្តើមបន្តិច រួចចូលន័យសេចក្តីខ្លឹមសារតែម្តង។

-បញ្ចប់ បង្ហាញពីការគោរព និងឈ្មោះអ្នកសរសេរ។

**-ចប់-**